សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law Economic

# សារណាបញ្ចប់ការសិក្សា

# ការទទួលខុសត្រូវរបស់អនីតិជន

ស្រាវជ្រាវពីថ្ងៃ ០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **លីម យ៉ាមីណា**

កញ្ញា **លី ស្រីពេជ្រ**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយបណ្ឌិត **ផុំ រិទ្ធី**



ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៣

ចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **លីម យ៉ាមីណា** សូមឱនកាយថ្វាយបង្គំ អភិវន្ទនកិច្ច និងសម្តែងនូវកតញ្ញូតាធម៌ ចំពោះលោកឪពុកឈ្មោះ **ហ៊ីម ហាលីម** និងអ្នកម្តាយឈ្មោះ **ស៊ុំ នរយ៉ាណាស់** អ្នកដ៏មានគុណទាំងទ្វេ រកអ្វីប្រៀបផ្ទឹមពុំបាន ដែលលោកទាំងទ្វេបានខិតខំចិញ្ចឹមបីបាច់ថែរក្សាតាំងពីតូចរហូតមកដល់ពេលបច្ចុប្បន្ន។ ជាពិសេសលោកទាំងពីរបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយ កម្លាំងចិត្ត ក្នុងការផ្គត់ផ្គង់ដើម្បីឲ្យនាងខ្ញុំ បាន សិក្សារៀនសូត្រ ចាប់តាំងពីថ្នាក់បឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ រហូតមកដល់ថ្នាក់មហាវិទ្យាល័យ ក្នុង ពេលបច្ចុប្បន្ននេះទៀត។ គុណូបការៈលោកអ្នកដ៏មានគុណទាំងពីរពិតជាមិនអាចកាត់ថ្លៃបាន។ កូនសូមគោរព ថ្លែងអំណរគុណ ចំពោះលោកទាំងពីរយ៉ាងជ្រាលជ្រៅបំផុតដែលរកអ្វីក្នុងលោកនេះមកប្រៀបផ្ទឹមបានឡើយ។

នាងខ្ញុំឈ្មោះ **លី ស្រីពេជ្រ** ជាកូនសូមគោរពប្រណិបត្តិដោយសេចក្តីកតញ្ញូតាធម៌ ចំពោះ លោក ឪពុកឈ្មោះ **ជុំ ដា** និងអ្នកម្តាយ **ឈឹម ថុន** លោកទាំងទ្វេបានផ្តល់កំណើតដល់រូបកូន។ លោកទាំងទ្វេជា អ្នកមានគុណយ៉ាងច្រើនលើសលប់ គ្មានអ្វីប្រៀបបានមកលើរូបកូន ព្រមទាំងបានខិតខំយកចិត្តទុកដាក់ចិញ្ចឹម បីបាច់ថែរក្សាផ្តល់ដំបូន្មាន ផ្តល់ភាពកក់ក្តៅជំនះរាល់ការលំបាកគ្រប់បែបយ៉ាងពិសេសទំនុកបម្រុងឲ្យខ្ញុំបាន សិក្សារៀនសូត្រតាំងពីថ្នាក់បឋមសិក្សា រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រនៅមហាវិទ្យាល័យ។

សូមគោរពថ្លែងអំណរគុណចំពោះ គណៈគ្រប់គ្រង សាស្ត្រាចារ្យ និងបុគ្គល មន្ត្រីរាជការទាំងអស់នៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានយកចិត្តទុកដាក់ក្នុងការ គ្រប់គ្រង និងបង្រៀនដល់សិស្សនិស្សិតទាំងអស់ដោយសេចក្តីស្រលាញ់ពេញចិត្ត។

ជាពិសេស សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះ **លោកសាស្ត្រាចារ្យជំនួយ បណ្ឌិត ព្រុំ រិទ្ធី** ដែលបានខិតខំទាំងកម្លាំងកាយចិត្ត និងប្រាជ្ញាស្មារតីដោយមិនខ្លាចនឿយហត់ក្នុងការផ្តល់នូវ គំនិតល្អៗ ណែនាំ និងផ្តល់យោបល់ដ៏មានសារៈសំខាន់ឲ្យយើងចងក្រងបានសារណាបញ្ចប់ការសិក្សាថ្នាក់ បរិញ្ញាបត្រនេះ។

ជាថ្មីម្តងទៀត ក្រុមខ្ញុំសូមគោរពជូនពរដល់ លោកអ្នកមានគុណទាំងពីររបស់ពួកខ្ញុំ ព្រមទាំងគណៈ គ្រប់គ្រង សាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិកនៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យា សាស្ត្រសេដ្ឋកិច្ច** និង ជាពិសេសសូមគោរពថ្លែងអំណរគុណចំពោះ **លោកសាស្ត្រាចារ្យជំនួយបណ្ឌិត ព្រុំ រិទ្ធី** សូមជូនពរឲ្យជួបប្រទះតែនឹងពរទាំងឡាយ ៥ប្រការ៖ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ព្រមទាំងទទួលបានភាពជោគជ័យគ្រប់ភារកិច្ច។

# អារម្ភកថា

ក្រោយពីបានបន្តការសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចអស់រយៈពេលប្រមាណជា៤ឆ្នាំមកនេះ។នាងខ្ញុំទាំងពីរបានសិក្សាស្រាវជ្រាវនូវមុខវិជ្ជាជាច្រើនទាំងផ្នែក ឯកជន និងសាធារណៈ ហើយ ដើម្បីឲ្យស្របតាមកម្មវិធីសិក្សារបស់សាកលវិទ្យាល័យនាងខ្ញុំបានធ្វើការសម្រេចចិត្តសរសេរសារណាសម្រាប់បញ្ចប់ការសិក្សាដោយជ្រើសរើសយកប្រធានបទមួយដែលស្តីពី"**ការទទួលខុសត្រូវរបស់អនីតិជន**"។

ការសិក្សាស្រាវជ្រាវនេះក្នុងគោលបំណង ដើម្បីយល់ដឹងកាន់តែស៊ីជម្រៅថែមទៀត អំពីបទដ្ឋានគតិយុត្ត ទាក់ទងទៅនឹង ការទទួលខុសត្រូវរបស់អនីតិជន ដែលក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា របស់យើងបានផ្តល់ឲ្យកាន់តែច្បាស់។ ហើយដើម្បីទទួលបានគតិយកមកអប់រំដល់ខ្លួនឯង និងអ្នកដទៃសម្រាប់ធ្វើការស្វែងយល់ធ្វើយ៉ាងណាឲ្យសង្គមមួយនេះសម្បូរ ទៅដោយប្រជាពលរដ្ឋដែលមានលក្ខណៈសម្បត្តិជាអ្នកដឹកនាំ និងជាអ្នកមានចំណេះដឹង ប្រកបដោយសីលធម៌ គុណធម៌ និងសុជីវធម៌ ដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់បំផុតរបស់មនុស្សក៏ដូចជាខ្លឹមសារស្នូលនៃសង្គមជាតិទាំងមូល ក្នុងការដឹងនាំសង្គមជាតិមួយនេះឆ្ពោះទៅកាន់វឌ្ឍនភាព និងជានិរន្តរភាព។

ថ្វីត្បិតតែសារណាមួយនេះបានបញ្ចប់ក៏ពិតមែន ប៉ុន្តែនៅចំណុចខ្លះ មិនអាចធ្វើការវិភាគឲ្យបានគ្រប់ជ្រុងជ្រោយ ជាពិសេសទាក់ទងទៅនឹងច្បាប់ ក៏ដូចជានីតិវិធីនៃការអនុវត្តផងដែរ។ ហេតុដូច្នេះ នាងខ្ញុំទាំងពីរនាក់នឹងធ្វើការសិក្សាបន្ថែមទៀតអំពីប្រធានបទមួយនេះ និងធ្វើការកែតម្រូវនូវចំណុចខ្វះខាតដែលកើតមាននៅក្នុងអត្ថបទមួយនេះ។

នាងខ្ញុំទាំងពីរសង្ឃឹមថា សារណាមួយនេះនឹងបានចូលរួមជាគំនិតខ្លះៗ ដល់និស្សិតជំនាន់ក្រោយក្នុងការសិក្សាស្រាវជ្រាវ និងចូលរួមចំណែកមួយផ្នែកជាទ្រឹស្តី ទាក់ទងនឹងអនីតិជន ក្នុងការយល់ដឹងពេញលេញឲ្យមានភាពល្អប្រសើរឡើង និងក្លាយទៅជាពលរដ្ឋល្អ កូនល្អ សិស្សល្អ ដែលជាទំពាំងស្នងឬស្សី នៅក្នុងសង្គមគ្រួសារ និងសង្គមជាតិទាំងមូលឲ្យសាកសមទៅនឹងអច្ឆរិយៈប្រទេសមួយនេះ។

ជាទីបញ្ចប់នាងខ្ញុំទាំងពីររង់ចាំជានិច្ចចំពោះមតិរិះគន់ក្នុងគោលបំណងស្ថាបនា ដែលជាកញ្ចក់ឆ្លុះបញ្ចាំងពីភាពអវិជ្ជមានណាមួយ ដើម្បីធ្វើការសិក្សាស្រាវជ្រាវបន្ថែមបង្កើនការយល់ដឹង និងពង្រីកចំណេះដឹងថែមទៀតពីសំណាក់ លោក លោកស្រី សាស្ត្រាចារ្យ មិត្តនិស្សិត សិស្សច្បង អ្នកវិជ្ជាជីវៈ ព្រមទាំងពីសំណាក់មិត្តអ្នកអានទាំងអស់ជាទីគោរព និងរាប់អានដ៏ជ្រាលជ្រៅបំផុត។

# មាតិកា

**សេចក្តីផ្តើម** ........ ១

## ជំពូកទី១

## សញ្ញាណទូទៅ

**១.១ លក្ខណៈនៃអនីតិជន** ........ ៥

**១.២ គោលការណ៍មូលដ្ឋាន** ........ ៧

## ជំពូកទី២

## ការទទួលខុសត្រូវរបស់អនីតិជនក្នុងកិច្ចសន្យា និងការទទួលខុសត្រូវរបស់អនីតិជនក្នុងអំពើអនីត្យានុកូល

**២.១ ទំនាក់ទំនងអនីតិជនក្នុងកិច្ចសន្យា** ........ ១២

២.១.១ ការព្រមព្រៀង ........ ១២

២.១.២ សមត្ថភាពក្នុងការចុះកិច្ចសន្យា ........ ១៣

២.១.៣ ការទទួលខុសត្រូវអនីតិជនក្នុងកិច្ចសន្យា ........ ១៤

**២.២ ទំនាក់ទំនងអនីតិជនក្នុងអំពើអនីត្យានុកូល** ........ ១៨

២.២.១ កំហុស ........ ១៨

២.២.២ ការខូចខាត ........ ១៩

២.២.៣ ទំនាក់ទំនងហេតុ និងផល ........ ១៩

## ជំពូកទី៣

## ការទទួលខុសត្រូវអនីតិជននៅក្នុងនីតិព្រហ្មទណ្ឌ

**៣.១ កាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជន** ........ ២២

៣.១.១ កាលៈទេសៈនៃបទល្មើស ........ ២២

៣.១.២ បុគ្គលិកលក្ខណៈរបស់អនីតិជន ........ ២៤

**៣.២ ការកំណត់អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌ** ........ ២៤

៣.២.១ អនីតិជនដែលមានអាយុក្រោម១៤ឆ្នាំ ........ ២៥

៣.២.២ អនីតិជនដែលមានអាយុចាប់ពី១៤ឆ្នាំ ដល់ក្រោម១៨ឆ្នាំ ........ ២៧

**៣.៣ ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ និងស្ថានសម្រាលទោសចំពោះអនីតិជន** ......... ៣៣

៣.៣.១ ការរួចពីការទទួលខុសត្រូវព្រហ្មទណ្ឌ......... ៣៣

៣.៣.២ ស្ថានសម្រាលទោសចំពោះអនីតិជន......... ៣៥

**សេចក្តីសន្និដ្ឋាន**......... ៣៨

**អនុសាសន៍**......... ៣៩

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ដោយសារការផ្លាស់ប្តូររបបនយោបាយជាច្រើនសន្ទឹកសន្ទាប់ និងការជួបប្រទះសង្គ្រាមស៊ីវិលជាច្រើន ព្រះរាជាណាចក្រកម្ពុជាបានបាត់បង់នូវរចនាសម្ព័ន្ធសឹងតែទាំងអស់។ ក្រោយពីទទួលបានសន្តិភាពពេញលេញ ការសិក្សាវិភាគទៅលើច្បាប់ត្រូវបានធ្វើភ្លាមៗទៅតាមវិវត្តន៍នៃសង្គមដើម្បី ជាគោលការណ៍នៃការកំណត់នូវសិទ្ធិ និងសេរីភាពដល់ប្រជាពលរដ្ឋ។ ក្រមរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា បានអនុម័ត នៅឆ្នាំ២០០៧ ក្នុងគោលបំណងដើម្បីដោះស្រាយនូវបញ្ហាឯកជននានា ដោយមាន៩គន្ថី ចាប់ពីបទបញ្ញត្តិទូទៅរហូតទៅដល់គន្ថីស្តីពីអវសានប្បញ្ញត្តិ។ ការសិក្សាទៅលើបញ្ញត្តិនីមួយៗ មានការលំបាក ដូចនេះទើប ក្រសួងយុត្តិធម៌បានបង្កើតនូវសេចក្តីកំណត់ និងសេចក្តីពន្យល់ក្រមរដ្ឋប្បវេណីថែមទៀត។ ក្នុងនោះដែរ ឃើញមានសិទ្ធិដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីភាគច្រើន គឺសំដៅទៅលើនីតិជន។ ការចាត់ទុកជាជនស្ថិតក្រោមការកម្រិតសមត្ថភាព គឺមានភាពខុសគ្នាពីនីតិជន ត្រូវបានបញ្ញត្តិជាលក្ខណៈទូទៅ។ ការកម្រិតសមត្ថភាពរបស់អនីតិជននេះ គឺធ្វើឡើងក្នុងគោលបំណងដើម្បីការពារអនីតិជន ដោយហេតុ អនីតិជនគឺ ស្ថិតនៅក្នុងស្ថានភាពក្មេងខ្ចីងាយស្រួលក្នុងការបញ្ចុះបញ្ចូលពុំទាន់មានបទពិសោធន៍គ្រប់គ្រាន់ក្នុងការធ្វើសកម្មភាពសំខាន់ៗ ដែលសកម្មភាពទាំងនោះអាចជាកាតព្វកិច្ច ឬជាសកម្មភាពដែលធ្វើឲ្យខូចខាតប្រយោជន៍របស់អនីតិជននោះ។

នៅក្នុងបញ្ញត្តិនៃក្រមរដ្ឋប្បវេណី យើងឃើញថា បញ្ញត្តិស្តីពីអនីតិជន គឺស្ថិតនៅក្នុង កថាភាគទី១ ផ្នែកទី៤ ជំពូក១ គន្ថីទី២ ដែលមានពីមាត្រា១៧ ដល់មាត្រា២៣ សរុបទៅគឺចំនួន ៧ មាត្រា។ ប៉ុន្តែ បញ្ញត្តិដែលទាក់ទងទៅនឹងអនីតិជនមានលើសពីអ្វីដែលបានចែងនៅក្នុងកថាភាគនេះ ដូចនេះធ្វើឲ្យការយល់ដឹងពីអនីតិជនមានភាពស៊ាំញ៉ាំតម្រូវឲ្យមានការពិនិត្យ និងសិក្សាដិតដល់។

ដើម្បីដោះស្រាយបញ្ហាខាងលើសំណេរសារណានេះបានផ្តោតទៅលើផ្នែកសំខាន់ៗដូចជា ករណីទង្វើរបស់អនីតិជនន ក៏ប៉ុន្តែក្នុងសារណានេះក៏បានបន្ថែមជំពូកដែលមានទាក់ទងផ្នែកព្រហ្មទណ្ឌផងដែរ ដូចជា ការទទួលខុសត្រូវអនីតិជននៅក្នុងនីតិព្រហ្មទណ្ឌដែលក្រមព្រហ្មទណ្ឌបានកំណត់ឡើង ដោយរួមផ្សំនឹងការសិក្សាស្រាវជ្រាវនូវទិន្នន័យពាក់ព័ន្ធផ្សេងៗទៀត ដើម្បីឲ្យវិសាលភាពនៃការយល់ដឹងពីអនីតិជនមានភាពច្បាស់លាស់ និងជំរុញវិស័យច្បាប់ឲ្យកាន់តែប្រសើរឡើង។

## ២.ចំណោទបញ្ហានៃការដោះស្រាយ

ដូចដែលបានលើកឡើងជាទូទៅខាងលើ អនីតិជន មានអាយុក្រោម១៨ឆ្នាំ ដែលពុំមានសមត្ថភាពក្នុងការវិនិច្ឆ័យទៅលើសកម្មភាពរបស់ខ្លួន នឹងត្រូវបានការពារដោយច្បាប់។ ដូចនេះហើយទើបនាំឲ្យមានការលើកឡើងជាចំណោទបញ្ហានៃប្រធានបទនេះថា តើអនីតិជនគ្រប់រូបត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់អាណាព្យាល

បានដែរ ឬទេ? ហើយបើសកម្មភាពមួយត្រូវបានកម្រិត តើអនីតិជនត្រូវមានទំនួលខុសត្រូវដូចម្តេច? តើអនីតិជនត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលដែរ ឬទេ? ម្យ៉ាងទៀតនោះ តើអនីតិជនអាចត្រូវមានការកំណត់អាយុសំរាប់ទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដែរ ឬទេ?

## ៣.គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាអំពី អនីតិជនតាមការកំណត់ក្នុងក្រមរដ្ឋប្បវេណី និងព្រហ្មទណ្ឌ គឺមានគោលបំណងបកស្រាយនូវលក្ខខណ្ឌ និងអានុភាពនានា ដែលទាក់ទងទៅនឹងសកម្មភាពរបស់អនីតិជន ពីព្រោះអនីតិជន ក៏ដូចជាប្រជាពលរដ្ឋដែលមានសិទ្ធិ និងសេរីភាពដែរ។ លើសពីនេះ ការសិក្សាស្រាវជ្រាវមានគោលដៅ ផ្តល់ជាសំណេរមួយដល់និស្សិតជំនាន់ក្រោយឲ្យទទួលបាននូវភាពងាយស្រួលក្នុងការសិក្សាយល់ដឹងពីទង្វើ និងការទទួលខុសត្រូវរបស់អនីតិជន ដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី នឹងក្រមព្រហ្មទណ្ឌ។

## ៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

សំណេរសារណានេះ មានគោលបំណងក្នុងការរៀបរាប់ឲ្យបានច្បាស់លាស់អំពី អនីតិជនដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី និងក្រមព្រហ្មទណ្ឌ។ ដូចនេះ ការស្រាវជ្រាវ គឺផ្អែកទៅលើ ក្រមរដ្ឋប្បវេណី ដែលមានចាប់តាំងពី អំពើអនីត្យានុកូល អាយុអនីតិជនដែលត្រូវទទួលខុសត្រូវលើអំពើអនីត្យានុកូល និងក្រមព្រហ្មទណ្ឌដែលទាក់ទង នឹងលក្ខខណ្ឌអាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន។ អ្វីដែលអាចជាការខ្វះខាតចំពោះការស្រាវជ្រាវនេះ គឺផ្នែកដែលពាក់ព័ន្ធនឹងអនីតិជនអាចមានវិសាលភាពធំជាងអ្វីដែលបានស្រាវជ្រាវ។ ចំពោះដែនកំណត់នៃការស្រាវជ្រាវ ដោយផ្អែកទៅតាមពេលវេលាកំណត់ គឺសិក្សាទៅលើតែឯកសារច្បាប់ដែលទាក់ទងទៅនឹងអនីតិជន ដែលមានដូចជាក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់យុត្តធម៌ស្តីពីអនីតិជន។

## ៥.សារៈសំខាន់នៃការស្រាវជ្រាវ

តាមការសិក្សាស្រាវជ្រាវសិក្សាកន្លងមកឃើញថា មានសំណេរជាច្រើនបានលើកនូវបញ្ញត្តិនានាក្នុងក្រមរដ្ឋប្បវេណី ដូចជាសន្តិកម្ម ការលែងលះ ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធជាដើម ដោយក្នុងនោះមានការលើកឡើងបន្តិចបន្តួច ជាចំណុចផ្សេងៗទៅលើការពិភាក្សាចំពោះអនីតិជន។ ហេតុនេះទើបសារណាទាក់ទងនឹងអនីតិជនតាមកំណត់ក្នុងក្រមរដ្ឋប្បវេណី និងក្រមព្រហ្មទណ្ឌ មានសារៈសំខាន់ ក្នុងការចែងរំលែងចំណេះដឹង និងពន្យល់ឲ្យច្បាស់នូវ នីតិវិធីក្នុងការធ្វើសកម្មភាពជាអនីតិជន ត្រូវគោរពការណ៍អ្វីខ្លះ ដើម្បីការពារទាំងអនីតិជន ក៏ដូចជាជនពាក់ព័ន្ធនឹងអនីតិជន។ លើសពីនេះ សំណេរសារណានេះ ក៏អាចនឹងសម្រួលទៅដល់ការសិក្សារបស់និស្សិតជំនាន់ក្រោយ ក្នុងការសិក្សាទៅលើអនីតិជន ដោយហេតុបញ្ញត្តិស្តីពីអនីតិជន ត្រូវបាន

កំណត់ជាចំណុចតូចៗ ក្នុងផ្នែកនានា ក្នុងក្រមរដ្ឋប្បវេណី។ ដូចនេះ និស្សិត អាចនឹងស្វែងរកបណ្តុំតែមួយ ដែលលើកឡើងតែពីអនីតិជន ជាមួយសារណានេះ។

## ៦.វិធីសាស្ត្រនៃការស្រាវជ្រាវ

ការប្រមូលឯកសារ ព័ត៌មាន និងទិន្នន័យនានា គឺជាកត្តាចាំបាច់ណាស់សម្រាប់ការស្រាវជ្រាវ និងចងក្រងនូវសំណេរសារណានីមួយៗ។ ដូចគ្នាដែរ ចំពោះសំណេរសារណានេះ គឺផ្តោតសំខាន់ទៅប្រភពទិន្នន័យសំខាន់ៗចំនួនពីរគឺ៖

### ទិន្នន័យចម្បង

ដោយហេតុតែប្រធានបទផ្តោតទៅលើការកំណត់ក្នុងក្រមរដ្ឋប្បវេណី ដូចនេះ ទិន្នន័យចម្បង គឺស្រង់គោលគំនិត និងព័ត៌មានពីច្បាប់ ពោលគឺក្រមរដ្ឋប្បវេណី សេចក្តីកំណត់មាត្រា សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ស្តីពីយុត្តិធម៌អនីតិជន។

### ទិន្នន័យបន្ទាប់បន្សំ

ចំណែកឯទិន្នន័យបន្ទាប់បន្សំវិញ គឺបានប្រមូលយកព័ត៌មានទិន្នន័យ និងឯកសារចេញពីសៀវភៅមេរៀនសាស្ត្រាចារ្យផ្សេងៗ និក្ខេបបទនានា គេហទំព័រ និងឯកសារទាក់ទងពីបទបង្ហាញដែល ជាកម្មវិធីរបស់សាកលវិទ្យាល័យផ្ទាល់។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវទៅលើ ប្រធានបទ **ការទទួលខុសត្រូវរបស់អនីតិជន** បានបែងចែកចេញជាបីជំពូក។ ជំពូកទី១ មានចំណងជើង **សញ្ញាណទូទៅនៃអនីតិជន** ដែលធ្វើការរៀបរាប់អំពីគោលការណ៍ផ្សេងៗចំពោះការកំណត់ថាជាជនដូចម្តេចដែលត្រូវបានចាត់ទុកជាអនីតិជន។ ជំពូកទី២ គឺយើងខ្ញុំនឹងធ្វើការបកស្រាយទៅលើ **ការទទួលខុសត្រូវរបស់អនីតិជនក្នុងកិច្ចសន្យា និងការទទួលខុសត្រូវរបស់អនីតិជនក្នុងអំពើអនីត្យានុកូល** ដែលសំដៅទៅលើ ការទទួលខុសត្រូវទៅលើកិច្ចសន្យា និងអំពើអនីត្យានុកូលបង្កឡើងដោយអនីតិជន។ រីឯជំពូកទី៣ **ការទទួលខុសត្រូវអនីតិជននៅក្នុងនីតិព្រហ្មទណ្ឌ** នឹងមានការបកស្រាយផ្តោតសំខាន់លើអាយុរបស់អនីតិជន ដើម្បីមកទទួលខុសត្រូវ។

# ជំពូកទី១

## សញ្ញាណទូទៅ

# ជំពូកទី១

# សញ្ញាណទូទៅ

ដើម្បីយល់ច្បាស់អំពីប្រធានបទនេះ ត្រូវយល់ច្បាស់អំពីនិយមន័យនៃពាក្យ ការទទួលខុសត្រូវ និងពាក្យ អនីតិជនជាមុនសិន។ ការទទួលខុសត្រូវ គឺជាកាតព្វកិច្ចរបស់បុគ្គលម្នាក់ៗដែលត្រូវធានារ៉ាប់រងអំពើរបស់ខ្លួន ដោយមានមូលដ្ឋាននៅលើសីលធម៌និងច្បាប់ហើយហ៊ានទទួលសារភាពថាខ្លួនជាអ្នកប្រព្រឹត្ត និងទទួលផល វិបាកនៃអំពើទាំងនោះ ។

រីឯពាក្យថា អនីតិជនគឺជាពេចន៍នៃវិស័យច្បាប់ដែល គឺជាគោលការណ៍មួយ ក្នុងចំណោមគោលការណ៍ ទូទៅដែលជាការកំណត់នូវអាយុរបស់រូបវន្តបុគ្គលណាម្នាក់ ដែលត្រូវបានគិតថាពុំមានសមត្ថភាពក្នុងការវិនិច្ឆ័យ ទៅលើសកម្មភាពរបស់ខ្លួន ដូចនេះនឹងត្រូវបានការពារដោយច្បាប់។

ចំណែកនូវសម័យមុនតាមការស្រាវជ្រាវបានឲ្យដឹងថា វិធីឆ្លងវ័យមួយត្រូវបានប្រជាជនខ្មែរនិយមប្រតិបត្តិ យ៉ាងខ្ជាប់ខ្ជួនគឺ វិធីចូលម្លប់[1]។

ពិធីចូលម្លប់ គឺជាពិធីឆ្លងវ័យរបស់ក្មេងស្រីពេញវ័យ (វ័យគ្រប់ការ) ឱ្យឆ្លងកាត់ការរស់នៅក្នុងបន្ទប់ ឬក្នុង ផ្ទះដែលជាម្លប់និងជានិមិត្តរូបនៃផ្ទៃម្តាយ ដើម្បីបន្ទុំខ្លួនឬបន្ទុំខ្លួនក្នុងផ្ទៃរង់ចាំកើតពីផ្ទៃមកវិញនៅថ្ងៃចេញម្លប់ ឯការកើតនេះមិនមែនជាទារកទេគឺក្លាយជាមនុស្សវ័យមួយថ្មីទៀតដែលអាចរៀបការបានឬការប្តីបាន។ តែគេមិន បានដឹងច្បាស់ថាមានតាំងពីពេលណាមកនោះទេរហូតមកដល់ចុងរជ្ជកាលព្រះបាទស៊ីសុវត្ថិមុនីវង្ស ប៉ុន្តែ ប្រហែលនៅឆ្នាំ១៩៣០ដល់ឆ្នាំ១៩៤០ គេពុំសូវឃើញមានការប្រារព្ធពិធីគ្រប់ទីកន្លែងនៅប្រទេសកម្ពុជាដូចកាល ពីមុនទៀតទេ។ នេះគឺជាវិធីបញ្ជាក់អំពីកូនស្រីថាគ្រប់អាយុ ឬមិនទាន់គ្រប់អាយុ(អនីតិជន) របស់ប្រជាជន សម័យមុន។ ខណៈកូនប្រុស គឺ បញ្ជាក់ថាពេញវ័យនៅពេលដែលកូនប្រុសនោះចូលបួសរៀនក្នុងសំណាក់ ព្រះពុទ្ធសាសនា ។

ជាកំណត់សម្គាល់ផងដែរ ពាក្យអនីតិជននៅក្នុងបរិបទនៃការស្រាវជ្រាវនេះ គឺសំដៅទៅលើការអនុវត្ត ក្នុងវិសាលភាពនៃក្រមរដ្ឋប្បវេណី និងរួមបញ្ចូលវិសាលភាពរបស់ក្រមព្រហ្មទណ្ឌផងដែរ។

ចំពោះសញ្ញាណទូទៅនៃអនីតិជន មានគោលការណ៍សំខាន់ដូចជា **លក្ខណៈនៃអនីតិជន(១.១) និង គោលការណ៍មូលដ្ឋាន(១.២)**

[1] ងួន ញ៉ិល សៀវភៅ ព្រលឹងមាតាធិបតេយ្យក្នុងសង្គមខ្មែរ ជំពូកទី២

## ១.១.លក្ខណៈនៃអនីតិជន

ជាទូទៅ ការកំណត់នូវលក្ខណៈរបស់អនីតិជន គឺតែងតែមានការកំណត់ខុសៗគ្នា ទៅតាមបរិបទសង្គមនៃប្រទេសនីមួយៗ។ ចំណែកក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាវិញបានកំណត់ និងផ្ដល់អត្ថន័យថា អនីតិជនសំដៅទៅលើជនដែលមានអាយុក្រោម១៨ (ដប់ប្រាំបី)ឆ្នាំ មិនទាន់គ្រប់ការ ជនដែលមិនអាចចុះកិច្ចសន្យាបាន ជនដែលមិនអាចធ្វើឲ្យកើតសិទ្ធិ និងករណីកិច្ចបាន។ តែទោះបីជាការកំណត់នេះ បានបញ្ជាក់ច្បាស់លាស់ពីលក្ខណៈនៃអនីតិជនក៏ដោយ ក៏ប៉ុន្តែការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពចំពោះអនីតិជនមានអញ្ញត្រកម្មផ្សេងៗដែលអត្ថបទនេះនឹងលើកនៅផ្នែកក្រោយៗ។

អនីតិជន[2]សំដៅដល់ជនដែលមានអាយុក្រោម១៨(ដប់ប្រាំបី)ឆ្នាំ។ ក៏ប៉ុន្តែមិនមែនអនីតិជនគ្រប់រូបសុទ្ធតែត្រូវបានកម្រិតសមត្ថភាពនោះទេដូចជា អនីតិជនដែលទទួលបានអត្តាធិនភាព គឺមិនត្រូវមានការកម្រិតសមត្ថភាពឡើយ និងត្រូវចាត់ទុកបានថាដល់នីតិភាព។ អ្នកដែលមានអំណាចមេបា (ឪពុក ម្ដាយ) មានសិទ្ធិនិងករណីកិច្ចបីបាច់ថែរក្សារូបកាយរបស់កូនដែលជាអនីតិជន។ តែបើចំពោះករណីអនីតិជន គ្មានឪពុកឬម្ដាយនោះទេ គេត្រូវបង្កើតរបបអាណាព្យាបាលសម្រាប់អនីតិជនដើម្បីជ្រើសតាំង បុគ្គលណាម្នាក់សម្រាប់គ្រប់គ្រងអនីតិជនដែលមានសិទ្ធិនិងករណីកិច្ចដូចអ្នកមានអំណាចមេបាដែរ។

ជាគោលការណ៍សកម្មភាពដែលអនីតិជនបានធ្វើដោយគ្មានការយល់ព្រមពីឪពុកម្ដាយ សកម្មភាពទាំងអស់នឹងត្រូវបានលុបចោលដោយ ឪពុកម្ដាយរបស់អនីតិជននោះ។ ក៏ប៉ុន្តែសកម្មភាពខ្លះ គឺមិនអាចលុបចោលបានទេដូចជា ការទទួលយកប្រទានកម្ម ការចុះកិច្ចសន្យាដោយរួចផុតពីកាតព្វកិច្ច ការទិញលក់របស់ប្រើប្រាស់ប្រចាំថ្ងៃ ការចាត់ចែងទ្រព្យសម្បត្តិដោយមានការអនុញ្ញាតពីឪពុកម្ដាយ ការប្រកបអាជីវកម្មត្រឹមការអនុញ្ញាតរបស់ឪពុកម្ដាយ។

ដោយសារអនីតិជន គឺជាជនត្រូវបានកម្រិតនូវសមត្ថភាព ដោយហេតុផលកង្វះសមត្ថកិច្ចក្នុងការវិនិច្ឆ័យដូចនេះជារឿយៗតែងតែផ្ដល់ផលលំបាកទៅដល់អនីតិជនផ្ទាល់។ ដើម្បីសម្រួលឲ្យអនីតិជនអាចធ្វើសកម្មភាពផ្សេងៗមួយចំនួនបាន ក្រមរដ្ឋប្បវេណីបានចែងឲ្យអនីតិជនអាចធ្វើសកម្មភាព ក្នុងករណីដែលអនីតិជន នោះត្រូវទទួលការអនុញ្ញាតពីសំណាក់អ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលរបស់អនីតិជន ព្រោះអ្នកទាំងនេះ គឺជាអ្នកមានកាតព្វកិច្ចមើលថែ ការពារអនីតិជន ដូចនេះត្រូវបានជឿជាក់ថានឹងផ្ដល់នូវសេចក្ដីយល់ព្រមលើសកម្មភាពណា ដែលខ្លួនគិតថាអនីតិជននឹងមិនបាត់បង់ប្រយោជន៍។

[2] មាត្រា១៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

អនីតិជន (កូនៗ)របស់អ្នកគឺជាកម្លាំងលើកទឹកចិត្តដ៏ធំមួយដែលធ្វើឲ្យឪពុកម្តាយតស៊ូគ្រប់បែបយ៉ាងនៅក្នុងឆាកជីវិតរស់នៅរបស់ពួកគាត់។ នៅពេលដែលកូនៗរបស់ពួកគាត់ចេះស្តាប់ដំបូន្មាននោះពួកគេនឹងមានចរឹតល្អ និងដើរតាមគន្លងធម៌វាគឺជារឿងដែលធ្វើឲ្យឪពុកម្តាយមានមោទនភាពហើយសប្បាយចិត្ត។ ប៉ុន្តែនៅពេលដែលពួកគាត់មានអាកប្បកិរិយាមិនត្រឹមត្រូវ ឬតែងតែប្រព្រឹត្តរឿងខុសឆ្គងដែលសង្គមស្អប់ខ្ពើមនោះវានឹងផ្តល់ផលវិបាកជាច្រើនសម្រាប់គ្រួសារ និងការពិបាកគ្រាំចិត្តរបស់ពួកគាត់។ ប៉ុន្តែតើអ្នកធ្លាប់ឆ្ងល់ទេថាតើអ្វីទៅដែលបណ្តាលឲ្យពួកគាត់មានអាកប្បកិរិយាមិនល្អទាំងនោះឡើង? វាអាចបណ្តាលមកពីការអប់រំព្រានប្រដៅរបស់ឪពុកម្តាយ ឬក៏អាចបណ្តាលមកពីការជះឥទ្ធិពលមិនល្អពីមិត្តភក្តិ និងបរិយាកាសមិនល្អពីសាលារៀន? ប៉ុន្តែមិនមែនកុមារទាំងអស់មានអាកប្បកិរិយាមិនត្រឹមត្រូវដោយសារតែការខ្វះខាតការអប់រំពីក្រុមគ្រួសារ ឬបញ្ហាសុខភាពផ្សេងទៀតនោះទេ វាអាចកើតឡើងពីការមិនយកចិត្តទុកដាក់ពីឥរិយាបថប្រចាំថ្ងៃរបស់ពួកគាត់រហូតដល់កុមារលែងស្តាប់បង្គាប់ និងបានក្លាយទៅជាក្មេងខូច។

១.មិនទទួលបានតម្រូវការគ្រប់គ្រាន់ពីឪពុកម្តាយ បើឃ្លានអ្នកទៅទូទឹកកកយកអ្វីញុំា បើរងាអ្នកយកភួយមកសណ្តប់ ប៉ុន្តែចំពោះក្មេងៗវិញពួកគេមិនមានវាក្យសព្ទ ឬសមត្ថភាពផ្លូវចិត្តក្នុងការប្រាប់អ្នកអំពីរឿងទាំងនោះឡើយ។ ដូច្នេះពួកគេត្រូវការអ្នកបើមិនដូច្នោះទេពួកគេនឹងធ្វើទុកស្រែកយំរំខានអ្នក។ តម្រូវការដែលមិនអាចបំពេញបានវាអាចជាហេតុផលធំមួយដែលធ្វើឲ្យកុមារប្រព្រឹត្តខុស និងមានអាកប្បកិរិយាមិនល្អទាំងនោះ។

២.បញ្ហាសុខភាពផ្លូវចិត្តដែលមិនច្បាស់លាស់ ឬពិការភាពក្នុងការរៀនសូត្រ កុមារមួយចំនួនមានបញ្ហាសុខភាពផ្លូវចិត្តដែលបណ្តាលមកពីកត្តាណាមួយក្នុងជីវិតរស់នៅ ឬមានផលវិបាកក្នុងការរៀនសូត្រដែលអាចបណ្តាលឲ្យពួកគេប្រព្រឹត្តខុស។

៣.ការធ្វើត្រាប់តាមអ្នកដទៃ ជាទូទៅកុមារភាគច្រើនត្រូវបានធ្វើត្រាប់តាមដោយសារការមើលទូរទស្សន៍ និងពីមនុស្សធំដទៃទៀតដែលពួកគេបានឃើញ។ នៅពេលដែលអ្នកអនុញ្ញាតឲ្យកូនៗរបស់អ្នកមើលអ្វីៗលើសពីអាយុរបស់ពួកគេវាជារឿងធម្មតាទៅហើយដែលពួកគេនឹងធ្វើត្រាប់តាមរឿងខ្លះដែលពួកគេមិនគួរធ្វើ។ ឧទាហរណ៍ដូចជាការនិយាយពាក្យជេរប្រមាថដែលអ្នកមិនដឹងថាពួកគេរៀនវាមកពីណា។

៤.ការធ្វេសប្រហែស និងការប្រងើយកន្តើយ ក្មេងខ្លះធ្វើសកម្មភាពដោយសារតែពួកគេព្យាយាមប្រាប់អ្នកថាពួកគេត្រូវការជំនួយ ឬប្រហែលជាគាត់ត្រូវបានគេមិនយកចិត្តទុកដាក់នៅផ្ទះ។ កង្វះការយកចិត្តទុកដាក់គឺជាកត្តាដែលជំរុញឲ្យពួកគាត់សម្រេចចិត្តធ្វើអ្វីមួយខុសឆ្គង ហើយនេះក៏ដោយសារតែភាពក្មេងវ័យរបស់ពួកគាត់។ ហេតុដូច្នេះហើយបានជាការទទួលបានការយកចិត្តទុកដាក់ គឺផ្តល់ភាពវិជ្ជមានសម្រាប់ក្មេងៗ។

៥.ការបញ្ចេញឥទ្ធិពល និងការគ្រប់គ្រងរបស់មនុស្សធំឪពុកម្តាយភាគច្រើនមានទម្លាប់ធ្វើការប្រឆាំងទៅនឹងអាកប្បកិរិយាឈ្លោះប្រកែកគ្នា ហើយនៅពេលដែលកូនៗមើលឃើញបែបនោះពួកគាត់នឹងបញ្ចេញការ

គ្រប់គ្រងវិញទៅកាន់អ្នក ដើម្បីជួយបញ្ឈប់ការឈ្លោះគ្នា។ កុំខឹង ឬព្យាយាមយកឈ្នះពួកគាត់ តែផ្តល់ជម្រើសដល់ពួកគេវិញដើម្បីអាចគ្រប់គ្រងស្ថានការណ៍បាន។

៦.ការរៀនយកអាកប្បកិរិយាមិនត្រឹមត្រូវ ប្រសិនបើកូនរបស់អ្នកស្រែកយំអ្នកនឹងឲ្យទូរស័ព្ទលេង ឬទិញរបស់អ្វីមួយឲ្យដើម្បីបំបាត់ការរំខាននៃការយំរបស់គាត់មកកាន់អ្នក។ ក្មេងៗធ្វើសកម្មភាពបែបនេះពី ព្រោះវាមានប្រសិទ្ធភាពដូច្នេះលើកក្រោយពួកគេនឹងដឹងថាត្រូវប្រើយុទ្ធសាស្ត្រនេះម្តងទៀតដើម្បីទទួលបានអ្វីដែលពួកគេចង់បាន។

## ១.២.គោលការណ៍មូលដ្ឋាន

ច្បាប់ស្តីពីយុត្តិធម៌អនីតិជនភាគច្រើន ផ្តើមចេញជាមួយការចែងអំពីការណែនាំដែលមានដកស្រង់ចេញពីអនុសញ្ញាស្តីពីសិទ្ធិកុមារ និងលិខិតូបករណ៍អន្តរជាតិដទៃផ្សេងៗទៀត។[3]កត្តានេះហើយទើបធ្វើឲ្យមានការចែងជាច្បាប់បែបនេះ ក្នុងគោលដៅដើម្បីបញ្ជាក់ឲ្យច្បាស់អំពីរបៀបដែលរដ្ឋមានវិធានការចំពោះកុមារដែលប្រព្រឹត្តបទល្មើស ហើយវាមានលក្ខណៈខុសប្លែកគ្នានូវវិធីសាស្ត្រដាក់ទោស ដែលមានចែងក្នុងប្រព័ន្ធយុត្តិធម៌អនីតិជន។ គោលការណ៍ទាំងនេះក៏បានផ្តល់នូវគោលការណ៍ណែនាំដល់ស្ថាប័នតុលាការ នឹងអាជ្ញាធររដ្ឋបាលផ្សេងៗនៅពេលដែលអាជ្ញាធរ ទាំងនោះកំពុងអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនតាមច្បាប់កំណត់។ ហេតុដូចនេះហើយទើបមានបញ្ញត្តិ អំពីគោលការណ៍ដែលទាក់ទងទៅ និងឧត្តមប្រយោជន៍របស់កុមារគោលការណ៍ដូចតទៅ ៖

•គោលការណ៍សមាមាត្រ ដែលដកស្រង់ចេញពីអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលមានខ្លឹមសារថា វិធានការឆ្លើយតបណាមួយ ចំពោះកុមារទំនាស់នឹងច្បាប់ត្រូវតែសមាមាត្រ មិនត្រឹមតែប្រភេទនៃបទល្មើសដែលបានចោទប្រកាន់ប៉ុណ្ណោះទេ ត្រូវតែសមាមាត្រជាមួយនឹងកាលៈទេសៈ និងភាពចាស់ទុំរបស់កុមារផងដែរ ។

•បឋមភាពនៃការឆ្លើយតបតាមរយៈការបង្វែរ ដែលមានខ្លឹមសារថា លើកលែងតែផលប្រយោជន៍ជាសាធារណៈដែលតម្រូវឲ្យដំណើរការនីតិវិធីព្រហ្មទណ្ឌ មិនត្រូវអនុវត្តចំពោះកុមារសោះឡើយប្រសិនបើ មានមធ្យោបាយសម្រាប់ប្រើជំនួសក្នុងការដោះស្រាយបញ្ហានោះ ។

•សិទ្ធិកុមារ ដែលមានខ្លឹមសារថា កុមារមានសិទ្ធិចូលរួមក្នុងដំណើរការនីតិវិធី និងបញ្ចេញមតិរបស់ខ្លួនដោយសេរី និងទទួលបាននូវការគាំទ្រផ្លូវច្បាប់ និងការគាំទ្រផ្សេងៗទៀត (ព្រមទាំងសមាជិកគ្រួសារ) ដើម្បីជួយពួកគេនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនីតិវិធី។

[3] ចែងក្នុងច្បាប់របស់ប្រទេសអូស្ត្រាលី កាណាដា ឡាវ ប៉ាពូ ញូហ្គានៀ ហ្វីលីពីន និងអាហ្វ្រិចខាងត្បូង

•ការរៀបរាប់អំពីគោលបំណង ដែលមានខ្លឹមសារថា គឺជាការឆ្លើយតបតាមសមាគមន៍ដែលជាការចាំបាច់ ហើយកាតព្វកិច្ចក្នុងការអនុវត្តការឃាត់ខ្លួន ការឃុំខ្លួន និងការដាក់ពន្ធនាគារត្រូវតែជាវិធានការចុងក្រោយបំផុត និងរយៈពេលខ្លី និងសមស្របបំផុត។[4]

យោងតាមមាត្រា៣៧ ចំណុច(ក) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ បានចែងថា គ្មានកុមារណាម្នាក់ត្រូវទទួលទារុណកម្មឬការប្រព្រឹត្តទៅលើខ្លួន ឬការផ្តន្ទាទោសឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបឡើយ។ ទោសប្រហារជីវិត ឬដាក់គុកអស់មួយជីវិតដោយគ្មានលទ្ធភាពដោះលែងមិនត្រូវដាក់ចំពោះបទល្មើសដែលប្រព្រឹត្តដោយមនុស្សមានអាយុក្រោម១៨ឆ្នាំឡើយ។ ហេតុនេះយើងត្រូវយកចិត្តទុកដាក់ និងពិចារណារាល់សកម្មភាពពាក់ព័ន្ធ និងឧត្តមប្រយោជន៍របស់អនីតិជន ជាពិសេសគឺជាការធានានូវសិទ្ធិរស់រានមានជីវិត និងការរីកចម្រើនលូតលាស់ជាអតិបរមា និងមិនរើសអើងចំពោះអនីតិជន មានជាអាទិ៍ ជាតិសាសន៍ ភេទ ភាសា សាសនា សង្គម ឬពូជអំបូរកំណើត ស្ថានភាពសេដ្ឋកិច្ច ឬនយោបាយ ។

យោងតាមមាត្រា៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលចែងចំពោះគ្រប់បុគ្គលដែលបំពេញតួនាទីមួយណាពាក់ព័ន្ធ នឹងអនីតិជន ត្រូវធានាឲ្យមានការគោរពគោលការណ៍ដូចតទៅ ៖

•ត្រូវយកចិត្តទុកដាក់ និងពិចារណារាល់សកម្មភាពពាក់ព័ន្ធ នឹងឧត្តមប្រយោជន៍របស់អនីតិជន ជាពិសេសធានានូវសិទ្ធរស់រានមានជីវិត និងការរីកចម្រើនលូតលាស់ជាអតិបរមា។

•ត្រូវប្រព្រឹត្តប្រកបដោយមនុស្សធម៌ និងសេចក្តីថ្លៃថ្នូរទៅលើអនីតិជន។

•ត្រូវផ្តល់ឱកាសឲ្យអនីតិជនសម្តែងមតិដោយសេរី ហើយទស្សនៈនោះត្រូវបានយកទៅពិចារណាថ្លឹងថ្លែងស្របទៅតាមអាយុ ការរីកចម្រើនផ្នែករូបកាយ បញ្ញាស្មារតី និងកម្រិតនៃការយល់ដឹងរបស់អនីតិជនចំពោះសកម្មភាពរបស់ខ្លួន។

•ត្រូវអនុវត្តទៅតាមនីតិវិធីកុមារមេត្រី។

•ត្រូវអនុវត្តការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួន និងការសម្រេចផ្តន្ទាទោសអនីតិជនជាវិធានការចុងក្រោយ និងមានរយៈពេលខ្លីបំផុតដែលអាចធ្វើទៅបាន។

•មិនត្រូវរើសអើងចំពោះអនីតិជន មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា ឋានៈសង្គម ធនធាន ដើមកំណើតជាតិ និន្នាការនយោបាយ ឬស្ថានភាពឯទៀត។

•មិនត្រូវប្រើខ្នោះ និងឧបករណ៍ផ្សេងៗទៀត ដែលប៉ះពាល់ដល់បូរណភាពរូបរាងកាយរបស់អនីតិជនលើកលែងតែក្នុងករណីចាំបាច់បំផុតប៉ុណ្ណោះ ដែលវិធានការទាំងឡាយមិនអាចអនុវត្តបាន ឬគ្មានប្រសិទ្ធភាព ។

[4] មាត្រា ៣៧ ចំណុចខ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារនិងពិធីសារបន្ថែម

•មិនត្រូវប្រើទារុណកម្ម ទណ្ឌកម្ម ឬប្រព្រឹត្តកម្មផ្សេងទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបតាមគ្រប់រូបភាពទៅលើរូបកាយ និងផ្លូវចិត្តរបស់អនីតិជន។

•មិនត្រូវបញ្ចេញ ឬផ្សព្វផ្សាយរូបភាព និង ព័ត៌មានទាំងឡាយដែលពាក់ព័ន្ធ នឹងសកម្មភាពរបស់អនីតិជន និងដែលបង្ហាញអំពីអត្តសញ្ញាណរបស់អនីតិជន ហើយដែលអាចមានឥទ្ធិពលលើសម្បទាកុមារក្នុងការទទួលបាននូវការអប់រំ ការងារ ការស្នាក់នៅ ឬសុវត្ថិភាព។ ការផ្សព្វផ្សាយរឿងក្តីអាចធ្វើទៅបាន លុះត្រាតែមានការអនុញ្ញាតពីព្រះរាជអាជ្ញា ដើម្បីផលប្រយោជន៍សាធារណៈប៉ុណ្ណោះ ប៉ុន្តែមិនត្រូវបង្ហាញអំពី អត្តសញ្ញាណរបស់អនីតិជនឡើយ។

•សន្មត់ថាគ្មានទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។

សម្រាប់ការឆ្លើយតបមកវិញ របស់អាជ្ញាធរនានាដែលមានសមត្ថកិច្ចចំពោះអនីតិជន ជានិច្ចជាកាលត្រូវសមាមាត្រ មិនត្រឹមតែទៅនឹងទម្ងន់នៃបទល្មើស តែអាស្រ័យទៅលើកាលៈទេសៈផ្ទាល់របស់អនីតិជន ដូចជាអាយុ និងសេចក្តីត្រូវការរបស់អនីតិជននោះផងដែរហើយការចាប់ខ្លួនការឃុំខ្លួន និងដាក់ពន្ធនាគារអនីតិជនអាចអនុវត្តន៍បានសម្រាប់តែវិធានការចុងក្រោយប៉ុណ្ណោះ ។

ចំពោះការប្រើប្រាស់កម្មវិធីសហគមន៍ និងកម្មវិធីសមស្របផ្សេងៗសម្រាប់បង្វែរអនីតិជនចេញពីនីតិវិធីតុលាការត្រូវបានពិចារណាក្នុងរាល់ករណីសមស្រប ហើយក្នុងករណីនៃការបង្វែរមិនមានលក្ខណៈសមស្របនោះទេ ការឃុំខ្លួនអនីតិជនត្រូវប្រព្រឹត្តទៅបន្តសម្រាប់តែរយៈពេលចាំបាច់ដែលខ្លីបំផុត[5] ហើយត្រូវបំបែកអនីតិជន ដោយធ្វើការឃុំខ្លួនដោយឡែកពីមនុស្សពេញវ័យ។ ការបង្គប់ឲ្យដាក់អនីតិជនក្នុងស្ថាប័ន ឬមណ្ឌលធ្វើឡើងតែក្នុងករណីពុំមានមធ្យោបាយជំនួសសមស្របប៉ុណ្ណោះ។ ក្នុងករណីបែបនេះត្រូវផ្តល់ការថែទាំការពារនិងជំនួយឧបត្ថម្ភផ្នែកអប់រំ ផ្នែកចិត្តសាស្ត្រនិងផ្នែកពេទ្យតាមការចាំបាច់ដើម្បីសម្រួលដល់ការស្តារនីតិសម្បទានិងការធ្វើសមាហរណកម្មសង្គមរបស់អនីតិជន។[6] ចំណែកឯការប្រកាសដកសិទ្ធិសេរីភាពរបស់អនីតិជន ត្រូវធ្វើសម្រាប់តែក្នុងករណីចាំបាច់បំផុត ដូចជា ករណីប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ ដែលពាក់ព័ន្ធនឹងអំពើហិង្សាប្រឆាំងនិងបុគ្គល ឬការប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរផ្សេងៗទៀតដោយមិនរាងចាល និងធ្វើឡើងតែក្នុងករណីពុំមានការសម្រេចសមស្របផ្សេងទៀត។

ដូចនេះចំពោះការដាក់ពន្ធនាគារអស់មួយជីវិតការដាក់ទណ្ឌកម្មលើរូបរាងកាយ និងទង្វើ ឬការដាក់ទណ្ឌកម្មឃោរឃៅ ឬបន្ថោសបន្ទាប ដល់អនីតិជនត្រូវបានហាមឃាត់។

---

[5] មាត្រា ៤ ចំណុច៩ នៃសេចក្តីព្រាងច្បាប់ស្តីពីយុតិធម៌អនីតិជន អនុម័តនា ខែកញ្ញា ឆ្នាំ២០០៧

[6] មាត្រា ៤ ចំណុច១០ នៃសេចក្តីព្រាងច្បាប់ស្តីពីយុតិធម៌អនីតិជន អនុម័តនា ខែកញ្ញា ឆ្នាំ២០០៧

សិទ្ធិកុមារ គឺជាសិទ្ធិមនុស្សរបស់កុមារដែរជាមួយនឹងការយកចិត្តដាក់ជាពិសេសទៅលើសិទ្ធិជា ពិសេសទៅលើការការពារ ហើយនិងការថែរក្សាអោយបានត្រឹមត្រូវរួមបញ្ចូលទាំងសិទ្ធិក្នុងការចូលរួមក្នុងសហគមន៍ជាមួយការថៃទាំពីឪពុកម្តាយ មនុស្សទាំងអស់គឺត្រូវការអាហារជាចាំបាច់ ជាទូទៅត្រូវការអប់រំ ការថែទាំសុខភាព និងការការពារច្បាប់ការរំលោភបំពានលើកុមារទាំងអស់ការពារអាយុជីវិត និងការអភិវឌ្ឍន៍ របស់កុមារ។ ការបកស្រាយពីសិទ្ធិកុមារត្រូវអនុវត្តទៅតាមសមត្ថភាពសំរាប់ភាពឯករាជ្យមិនមានការបង្ខំ ទាំងផ្លូវកាយទាំងបញ្ញានិងផ្លូវចិត្ត ច្បាប់កំណត់ការរំលោភជាបញ្ហានៃការពិភាក្សា។ គោលបំណងមួយផ្សេងទៀតបានរួមបញ្ចូលទាំងសិទ្ធិក្នុងការពារ និងការចិញ្ចឹមបីបាច់ថែរក្សា។

ជាអនីតិជន តាមច្បាប់មិនអាចមានភាពស្វ័យឯករាជ្យ ឬមានសិទ្ធិដើម្បីធ្វើការសំរេចការងារដោយខ្លួនឯងបានទេ។ នីតិវិធីកុមារមេត្រីសំដៅដល់ដំណើរការ និងនីតិវិធីដែលពាក់ព័ន្ធ នឹងការលើកទឹកចិត្តឱ្យអនីតិជនចូលរួមក្នុងរឿងក្តីតាមរយៈការប្រើប្រាស់ភាសា និងអាកប្បកិរិយាក្នុងកម្រិតដែលអនីតិជនអាចយល់បាន និងក្នុងបរិយាកាសដែលផ្តល់ឱ្យអនីតិជននូវសុវត្ថិភាព សន្តិសុខ សិទ្ធិ និងតម្រូវការជាមូលដ្ឋាន។

# ជំពូកទី២

## ការទទួលខុសត្រូវរបស់អនីតិជន
## ក្នុងកិច្ចសន្យា
## និង
## ការទទួលខុសត្រូវរបស់
## អនីតិជនក្នុងអំពើអនីត្យានុកូល

# ជំពូកទី២

# ការទទួលខុសត្រូវរបស់អនីតិជនក្នុងកិច្ចសន្យា និងការទទួលខុសត្រូវរបស់អនីតិជនក្នុងអំពើអនីត្យានុកូល

អនីតិជនជាជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពពោល គឺដើម្បីការពារដល់ប្រយោជន៍របស់អនីតិជន។

ចំពោះជំពូកនេះ មានការបកស្រាយអំពី ការទទួលខុសត្រូវរបស់អនីតិជនក្នុងកិច្ចសន្យា និងការទទួលខុសត្រូវរបស់អនីតិជនក្នុងអំពើអនីត្យានុកូល ។

ជាគោលការណ៍ក្រមរដ្ឋប្បវេណីបានផ្ដល់ នូវការការពារដល់ជនដែលមានសមត្ថភាពទាប ហើយដែលមិនអាចវិនិច្ឆ័យ និងធ្វើសកម្មភាពតាមលក្ខណៈសមហេតុផលបាន។ ទាក់ទងនឹងការទទួលខុសត្រូវខាងអំពើអនីត្យានុកូល អនីតិជនដែលមានអាយុក្រោម១៤(ដប់បួន)ឆ្នាំ ឬជនដែលមានវិបត្តិផ្នែកបញ្ញាស្មារតី ត្រូវរួចផុតពីការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល[7]។ ផ្ទុយទៅវិញច្បាប់តម្រូវឲ្យមានការទទួលត្រូវជាពិសេសមួយ ពីអ្នកគ្រប់គ្រងដែលជាការសង្គ្រោះមួយដល់ជនរងគ្រោះ។

ការទទួលខុសត្រូវ គឺជាកាតព្វកិច្ចរបស់បុគ្គលម្នាក់ៗដែលត្រូវធានារ៉ាប់រងអំពើរបស់ខ្លួនដោយមានមូលដ្ឋាននៅលើសីលធម៌ និងច្បាប់ហើយហ៊ានទទួលសារភាពថាខ្លួនជាអ្នកប្រព្រឹត្ត និងទទួលផលវិបាកនៃអំពើទាំងនោះ ។

កិច្ចសន្យា គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើតកែប្រែ ឬរំលត់កាតព្វកិច្ច។ អាចនិយាយម្យ៉ាងទៀតបានថា គឺជាអានុភាពដែលកើតឡើងដោយសារ សំណើ និងស្វីការត្រូវគ្នា។

ដូចនេះបានន័យថាទោះបីជាបុគ្គលពីរ ឬច្រើននាក់បានព្រមព្រៀងគ្នាចំពោះការបង្កើត ឬរំលត់កាតព្វកិច្ច ហើយក៏ដោយ សកម្មភាពទាំងនេះ ត្រូវយកបញ្ញត្តិពីការកម្រិតសកម្មភាពរបស់អនីតិជនមកអនុវត្ត បើសិទ្ធិភាគីនៃការព្រមព្រៀងនោះជាអនីតិជន។

[7] មាត្រា ៧៤៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី

## ២.១.ទំនាក់ទំនងអនីតិជនក្នុងកិច្ចសន្យា

កិច្ចសន្យាត្រូវបានឲ្យនិយមន័យ គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬរំលត់កាតព្វកិច្ច។ អាចនិយាយម្យ៉ាងទៀតបានថា គឺជាអានុភាពដែលកើតឡើងដោយសារ សំណើ និង ស្វីការត្រូវគ្នា។

ជាគោលការណ៍ កិច្ចសន្យាមួយអាចត្រូវបានបង្កើតឡើងដោយមាន សំណើ និងស្វីការត្រូវគ្នា[8]។ មានន័យថា កិច្ចសន្យាអាចនឹងមានអានុភាពដោយមានការព្រមព្រៀងគ្នាទៅវិញទៅមករវាងគូភាគីទាំងសង ខាង។ ការចែងបែបនេះ គឺបានបញ្ជាក់ឲ្យដឹងពីសេរីភាពក្នុងការបង្កើតកិច្ចសន្យា មានន័យថាកិច្ចសន្យាមួយ អាចត្រូវបានបង្កើតឡើង ដោយគ្រាន់តែមានការព្រមព្រៀងរវាងគូភាគីទៅ គឺគ្រប់គ្រាន់ហើយមិនចាំបាច់មាន ល័ក្ខខណ្ឌអ្វីផ្សេងទៀតក៏បានដែរ។

ប៉ុន្តែដើម្បីឲ្យកិច្ចសន្យាមានសុពលភាពត្រឹមត្រូវតាមច្បាប់ និងអាចដាក់ឲ្យភាគីប្រតិបត្តិតាមបាន លុះ ត្រាតែកិច្ចសន្យានោះបានគោរពនូវ គោលការណ៍សុពលភាពមួយចំនួនដូចះ

-ការព្រមព្រៀងដោយសេរី និងគ្មានវិការៈ

-កិច្ចសន្យានោះកើតចេញពីជនដែលមានសមត្ថភាពគ្រប់គ្រាន់តាមច្បាប់

-កិច្ចសន្យានោះត្រូវមានកម្មវត្ថុដែលអាចអនុវត្តកើត ស្របច្បាប់ ស្របតាមរបៀបរៀបរយសាធារណៈ ឬ ទំនៀមទំលាប់ល្អរបស់សង្គម។

### ២.១.១.ការព្រមព្រៀង

ជាដំបូងយើងត្រូវដឹងថា តើសំណើជាអ្វី? សំណើ គឺជាការបង្កើតកិច្ចសន្យា ដែលធ្វើឡើងដោយមានឆន្ទៈ ភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្តក្នុងករណីមាន ស្វីការរបស់ភាគីម្ខាងទៀតចំពោះសំណើរ។ សំណើ នឹងមាន អានុភាពបានលុះត្រាតែសំណើនោះបានទៅដល់ភាគីម្ខាងទៀត[9]។ មានន័យ សំណើគឺជាការបង្ហាញឆន្ទៈថា និង ភ្ជាប់ជាមួយនឹងចំណងគតិយុត្តនៃកិច្ចសន្យា ដែលបង្កើតឡើងក្នុងករណីដែលភាគីម្ខាងទៀតផ្តល់ស្វីការចំពោះ សំណើនោះ ហើយកិច្ចសន្យាក៏ត្រូវបានបង្កើតឡើង ដោយសារមានសំណើរ និងស្វីការត្រូវគ្នា។ ពាក្យថា បានទៅ ដល់ នៅក្នុងក្រមរដ្ឋប្បវេណីយើង មិនបានកំណត់ថាចាំបាច់ទល់តែអ្នកទទួល ឬបានបើកអានសំណើនោះទេ គឺ ឲ្យតែបានទៅដល់គឺគ្រប់គ្រាន់ហើយ។

តាមក្រមរដ្ឋប្បវេណីជប៉ុនវិញ ការបង្ហាញទៅខាងក្រៅនូវឆន្ទៈដែលធ្វើឲ្យកើតឡើងនូវអានុភាពតាមផ្លូវ ច្បាប់ហៅថា ការបង្ហាញឆន្ទៈ។ អ្នកដែលបានបង្ហាញឆន្ទៈ ហៅថាអ្នកបង្ហាញឆន្ទៈ(មានលក្ខណៈដូចគ្នាទៅនឹង

[8] មាត្រា ៣៧៦ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[9] មាត្រា ៣៧៧ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

សំណើក្នុងក្រមរដ្ឋប្បវេណីកម្ពុជាយើង)។ ដោយឆន្ទៈដែលបានបង្ហាញទៅខាងក្រៅថា ចង់លក់របស់អ្វីមួយ ឬចង់ទិញរបស់អ្វីមួយ គឺជាការបង្ហាញឆន្ទៈ។ មានន័យថា ឆន្ទៈមុនបង្ហាញឡើង គឺជាឆន្ទៈរបស់អ្នកលក់ រីឯឆន្ទៈក្រោយ គឺជាឆន្ទៈរបស់អ្នកទិញ[10]។ ត្រង់ចំណុចនេះ ការបង្ហាញឆន្ទៈក្រោយគេអាចត្រូវបានគេចាត់ទុកដូចជា ការទទួលស្វីការនៅក្នុងករណីរបស់ក្រមរដ្ឋប្បវេណីខ្មែរយើងផងដែរ។ នៅពេលដែលឆន្ទៈមុន និង ឆន្ទៈក្រោយបានត្រូវគ្នាហើយនោះកិច្ចសន្យាមួយនឹងកើតមានឡើង។

ក្រោយពីធ្វើការសិក្សាលើពាក្យថាសំណើរហើយ យើងនឹងធ្វើការសិក្សាលើពាក្យថា ស្វីការវិញម្តង។ ស្វីការត្រូវបានគេឲ្យនិយមន័យថា ការបង្ហាញឆន្ទៈ ដែលអ្នកទទួលសំណើយល់ព្រមលើសំណើនោះ ហើយវាមានអានុភាពនៅពេលដែលសំណើនោះបានដល់អ្នកស្នើ[11]។ ឧទាហរណ៍ ប្រសិនបើគ្មានអ្នកដាក់សំណើទេ បុគ្គលម្នាក់ស្រាប់តែបង្ហាញឆន្ទៈថា ខ្ញុំចង់ទិញមួយនេះ ការបង្ហាញឆន្ទៈបែបនេះ គេមិនហៅថាជា ស្វីការទេ ប៉ុន្តែអាចត្រូវបានគេបកស្រាយថាជាសំណើទៅវិញ។ ចំណែកឯក្នុងករណីដែល អ្នកទិញបានធ្វើសំណើទិញជាក់លាក់ណាមួយ ហើយអ្នកលក់ផ្ញើទំនិញនោះទៅអ្នកទិញ គេអាចធ្វើការបកស្រាយបានថា សកម្មភាពនៃការផ្ញើទំនិញរបស់អ្នកលក់នោះចាត់ទុកជាស្វីការ ទោះបីជាអ្នកលក់មិនបានបង្ហាញឆន្ទៈនៃស្វីកាច្បាស់លាស់ក៏ដោយ[12]។

ចំណែកនៅក្នុងក្រមរដ្ឋប្បវេណីជប៉ុន មិនមានមាត្រាណាមួយចែងពីចំណុចស្តីពីស្វីការនោះទេ។ ប៉ុន្តែដោយសារមានការបកស្រាយជាច្រើន បានគោរពតាមគោលការណ៍នៃស្វីការនេះ ព្រោះជាទូទៅកិច្ចសន្យាមួយមិនអាចបង្កើតឡើងបានឡើយ ប្រសិនបើមានតែសំណើហើយគ្មានស្វីការនោះទេ។

**២.១.២.សមត្ថភាពក្នុងការចុះកិច្ចសន្យា**

នៅក្នុងការបង្កើតកិច្ចសន្យានីមួយៗ បន្ទាប់ពីមានការព្រមព្រៀងរបស់គូភាគីហើយនោះកត្តាមួយដែលស្តីពីសមត្ថភាពនៃគូភាគីបង្កើតកិច្ចសន្យានោះក៏មានសារៈសំខាន់ផងដែរ។ ព្រោះថាប្រសិនបើគេពិនិត្យឃើញថាកិច្ចសន្យាណាមួយនោះ ត្រូវបានបង្កើតឡើងដោយជនដែលគ្មានសមត្ថភាពក្នុងការបង្កើតកិច្ចសន្យាតាមផ្លូវច្បាប់ទេ កិច្ចសន្យានោះអាចត្រូវបានគេចាត់ទុកថាមានវិការៈហើយមិនមានសុពលភាព និងគ្មានអានុភាពសម្រាប់យកមកអនុវត្តបានផងដែរ។ ក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ក៏បានចែងពីការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពក្នុងការបង្កើតកិច្ចសន្យាឬសកម្មភាពឯកតោភាគីផ្សេងៗផងដែរ។[13] ការកម្រិតពីរបបសមត្ថភាព

[10] សាស្ត្រាចារ្យ ណូម៉ូរ៉ា គូយ៉ូហ៊ីរ៉ូ សៀវភៅសេចក្តីផ្តើមនីតិរដ្ឋប្បវេណី ភ្នំពេញ កម្ពុជា បោះពុម្ពលើកទី៥ ឆ្នាំ២០១១

[11] មាត្រា ៣៣៧ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[12] មាត្រា ៣៣៧ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[13] មាត្រា១៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ក្នុងការធ្វើសម្មភាពបែបនេះ គឺធ្វើឡើងដើម្បីការពារកុំឲ្យមានការទទួលរងនូវផលប៉ះពាល់ និងការខូចខាតនានាដែលអាចកើតមានឡើងដោយសារកិច្ចសន្យាលក់ទិញ របស់ជនដែលមិនមានសមត្ថភាពក្នុងការវិនិច្ឆ័យ ដោយបានចែងមិនអនុញ្ញាតឲ្យជនមួយចំនួន ធ្វើការបង្កើតកិច្ចសន្យាដែលមាន សុពលភាពពេញលេញមួយបាននោះ។

ជាធម្មតាជនដែលមានសមត្ថភាពចុះកិច្ចសន្យាទាំងនោះមានដូចជា៖ អនីតិជនដែលមានអត្តាធីន ភាព និងអនីតិជនធម្មតា។ ចំណែកឯ ជនដែលមិនមានសមត្ថភាពក្នុងការចុះកិច្ចសន្យាវិញ មានដូចជា៖ អនីតិជនដែលគ្មានអត្តាធីនភាព អនីតិជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ និងអនីតិជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភ។ ហេតុដូច្នេះហើយ ជនដែលត្រូវបានកម្រិតសមត្ថភាពធ្វើសកម្មភាព គឺជាជនដែលមានសមត្ថភាពក្នុងការធ្វើសកម្មភាពពេញលេញ។ រាល់កិច្ចសន្យាដែលបង្កើតឡើងដោយជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព គឺមានសមត្ថភាពពេញលេញ ប្រសិនបើពុំមានមូលហេតុផ្សេងទៀតដែលនាំឲ្យ មោឃៈ ឬមូលហេតុដែលនាំឲ្យមានការលុបចោលកិច្ចសន្យាទេនោះ។

ឧទាហរណ៍៖ បើអនីតិជនចង់ទិញម្ហូបអាហារដើម្បីបរិភោគ ដែលសកម្មភាពនេះត្រូវបានចាត់ទុកជាកិច្ចសន្យាទិញលក់ ហើយចាំបាច់ត្រូវមានការយល់ព្រមពីសំណាក់អ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលអនីតិជននោះ ការទិញម្ហូបអាហារបរិភោគនឹងផ្តល់នូវផលលំបាក និងធ្វើឲ្យខូចដល់ផលប្រយោជន៍របស់អនីតិជន។ សកម្មភាពទាក់ទង នឹងជីវភាពរស់នៅប្រចាំថ្ងៃ ជាសកម្មភាពដែលមានភាពងាយស្រួលក្នុងការវិនិច្ឆ័យជាទូទៅមានតម្លៃទឹកប្រាក់ទាប ដែលមិនមានការព្រួយបារម្ភអំពីការខូចខាតផលប្រយោជន៍របស់អនីតិជន។[14] ដូចនេះ សកម្មភាពទាក់ទង នឹងជីវភាពរស់នៅប្រចាំថ្ងៃ សំដៅទៅលើសកម្មភាពដូចជា ការទិញសំលៀកបំពាក់ ការទិញបរិភោគ ការបង់ទឹកភ្លើង ជាអាទិ៍។

**២.១.៣. ការទទួលខុសត្រូវរបស់អនីតិជនក្នុងកិច្ចសន្យា**

ជាទូទៅ អនីតិជនដែលស្ថិតនៅក្រោមអាយុ១៨ឆ្នាំ តែងតែទទួលបានការអនុញ្ញាតឲ្យធ្វើ ឬមិនឲ្យធ្វើជាមុនសិនពីសំណាក់អ្នកដែលមានអំណាចមេបា ឬអាណាព្យាបាល។ ហេតុដូចនេះហើយ ទើបជាគោលការណ៍ រាល់សកម្មភាពទាំងឡាយដែលអនីតិជនធ្វើឡើងដោយឆន្ទៈខ្លួនឯង ហើយគ្មានការទទួលយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬអាណាព្យាបាលសម្រាប់អនីតិជនទេនោះ គេអាចលុបចោលសកម្មភាពទាំងនោះបាន ដើម្បីជាមធ្យោបាយមួយសម្រាប់ការពារដល់អនីតិជននោះ។

[14] ទំព័រទី១៥ នៃឯកសាររបស់ក្រុមការងារសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៃមេរៀន ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ របស់ក្រសួងយុត្តិធម៌

ចំពោះអនីតិជន ការបង្កើតកិច្ចសន្យាអាចកើតឡើងក្នុងករណី ដែលអនីតិជននោះបានទទួលនូវការយល់ព្រមពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ហើយបើកិច្ចសន្យានោះពុំមានការយល់ព្រមពីអ្នកតំណាងដែលច្បាប់បានកំណត់របស់អ្នកនោះទេ កិច្ចសន្យានោះនឹងត្រូវមានវិការៈដែលជាលក្ខខណ្ឌមួយនៅក្នុងការលុបកិច្ចសន្យា។[15]

ដោយសារតែ សកម្មភាពធ្វើឡើងដោយអនីតិជននោះ ជាសកម្មភាពដែលមានវិការៈ ហេតុដូចនេះហើយ អនីតិជនសាមីខ្លួនផ្ទាល់ ព្រមទាំងអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចធ្វើការលុបចោលនូវសកម្មភាពទាំងនោះបាន។

ថ្វីត្បិតតែ សកម្មភាពដែលធ្វើឡើងដោយអនីតិជន អាចត្រូវបានលុបចោល ប្រសិនបើសកម្មភាពនោះ ធ្វើឡើងដោយគ្មានការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬអាណាព្យាបាលក៏ដោយ ក៏នៅមានបញ្ញត្តិពិសេសមួយចំនួន ដែលទទួលស្គាល់នូវការធ្វើកិច្ចសន្យា ដោយមានសុពលភាពពេញលេញរបស់អនីតិជនផងដែរ។ សកម្មភាពទាំងនោះមានដូចជា សកម្មភាពដែលទទួលបានសិទ្ធិ ឬឲ្យរួចផុតពីកាតព្វកិច្ច និងការទិញវត្ថុប្រើប្រាស់ប្រចាំថ្ងៃជាអាទិ៍។

ចំពោះករណីប្រទេសជប៉ុនវិញ រាល់ជនដែលមានអាយុ២០ឆ្នាំ ត្រូវបានចាត់ទុកថាជានីតិជន ហើយមានសមត្ថភាពពេញលេញក្នុងការប្រព្រឹត្តសកម្មភាពនានាបាន។[16] ហេតុនេះហើយយើងអាចនិយាយបានថា អនីតិជនសម្រាប់ករណីប្រទេសជប៉ុន គឺជាជនទាំងឡាយណាដែលមានអាយុក្រោម២០ឆ្នាំ។ ចំពោះសកម្មភាពនៃការប្រព្រឹត្តតាមផ្លូវច្បាប់របស់អនីតិជន គឺត្រូវតែទទួលបានការយល់ព្រមពីអ្នកតំណាងតាមច្បាប់កំណត់ជាដាច់ខាត បើមិនដូច្នេះទេសកម្មភាពនោះមិនអាចយកមកអនុវត្តបានឡើយ។ ប៉ុន្តែប្រសិនបើក្នុងករណីដែលទទួលបានសិទ្ធិ ឬត្រូវបានដកកាតព្វកិច្ចពីអនីតិជននោះ គឺមិនចាំបាច់ធ្វើការលុបចោលសកម្មភាពនោះឡើយ។[17]

ជារួមមកដូចដែលបានរៀបរាប់ខាងលើមកអាចនិយាយបានថា ករណីរបស់ប្រទេសកម្ពុជា និងជប៉ុន គឺមានលក្ខណៈប្រហាក់ប្រហែលគ្នាស្ទើរតែទាំងស្រុង ទាក់ទងទៅ នឹងការកំណត់ពីសកម្មភាពរបស់ អនីតិជន។ ដោយមានចំណុចខុសគ្នាត្រង់ថា អនីតិភាពរបស់កម្ពុជាយើងគឺ ចាប់ពីអាយុ១៨ឆ្នាំចុះក្រោម ចំណែកឯជប៉ុនវិញ អនីតិភាពរបស់គេគឺ ចាប់ពីអាយុ២០ឆ្នាំចុះក្រោម។

---

[15] កិច្ចការក្រុមការងារក្រសួងយុត្តធម៌ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២ ទំព័រ៦ ឆ្នាំ២០១៦

[16] មាត្រា៤ ក្រមនីតិវិធីនៃប្រទេសជប៉ុន

[17] មាត្រា៥ ក្រមនីតិវិធិនៃប្រទេសជប៉ុន

រីឯការលុបចោល គឺសំដៅទៅលើការបដិសេធសុពលភាពនៃសកម្មភាពគតិយុត្ត។ ដូចនេះបាននន័យថា កិច្ចសន្យាដែលបង្កើតឡើងដោយអនីតិជន នឹង ត្រូវអាចបដិសេធនូវសុពលភាពរបស់កិច្ចសន្យានោះបាន។ អ្នកដែលមានសិទ្ធិលុបកិច្ចសន្យារបស់អនីតិជន មានដូចជា អនីតិជនសាមីខ្លួន អ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន។

ឧទាហរណ៍៖ និមល បានទិញម៉ូតូពី សិលា ក្នុងតម្លៃ ១៥០០ដុល្លា។ និមល មានអាយុត្រឹមតែ១៤ ឆ្នាំ ហើយការទិញម៉ូតូនេះ គឺដោយពុំមានការអនុញ្ញាតពីឪពុកម្តាយឡើយ។ ក្នុងករណីនេះឪពុកម្តាយរបស់ និមល ដែលជាអ្នកមានអំណាចមេបា មានសិទ្ធិក្នុងការលុបចោលកិច្ចសន្យាទិញលក់ម៉ូតូនេះ។ ដូចនេះ សិលា ត្រូវប្រគល់លុយឲ្យទៅនិមល ឬ ឪពុកម្តាយរបស់ និមល វិញ ហើយខាងនិមលក៏ត្រូវប្រគល់ម៉ូតូឲ្យទៅភាគី សិលា វិញដែរ។

ទោះបីជា កិច្ចសន្យាដែលគ្មានការយល់ពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចនឹងលុបចោលបានក៏ដោយក៏កិច្ចសន្យានេះអាចនឹងមានសុពលភាពពេញលេញក្នុងលក្ខខណ្ឌដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនបានផ្តល់នូវសច្ចានុម័តចំពោះសកម្មភាពរបស់អនីតិជននោះ។

សច្ចានុម័ត គឺជាសកម្មភាពដែលបុគ្គលមានសិទ្ធិលុបចោល បង្ហាញជាស្ថាពរថាខ្លួនមិនអនុវត្តសិទ្ធិលុបចោល ដោយផ្អែកលើបុរលក្ខខណ្ឌ ដែលបានដឹងថាសកម្មភាពរបស់ខ្លួនអាចលុបចោលបាន[18] ។ ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោលបានផ្តល់សច្ចានុម័តទៅលើសកម្មភាពដែលអាចលុបចោលហើយ សិទ្ធិលុបចោលរបស់បុគ្គលនោះនឹងត្រូវបានរលត់ ដូចនេះ សកម្មភាពនោះនឹងមិនអាចលុបចោលនៅពេលក្រោយបានឡើយ។ ការធ្វើសច្ចានុមតិ និងការលុបចោល គឺអាចធ្វើឡើងនៅក្រៅតុលាការបាន។

ចំពោះកិច្ចសន្យាការងាររបស់អនីតិជន ជាធម្មតា ជនដែលអាចប្រកបការងារបាន ត្រូវមានបញ្ញត្តិឲ្យមានអាយុចាប់ពី១៨ឆ្នាំឡើងទៅដោយហេតុតែមានជនខិលខូចប្រើប្រាស់នូវសមត្ថភាពក្នុងការវិនិច្ឆ័យរបស់អនីតិជនដើម្បីផលប្រយោជន៍ខ្លួន និងកត្តាកាយសម្បទានរបស់អនីតិជនផងដែរ។ ប៉ុន្តែប្រសិនបើយើងពិនិត្យមើលទៅក្នុងសង្គមសព្វថ្ងៃភាពកង្វះខាតហិរញ្ញវត្ថុ គឺជាបញ្ហាមួយដែលត្រូវបង្ខំឲ្យអនីតិជនត្រូវរកការងារដើម្បីចិញ្ចឹមជីវិត។ ដើម្បីសម្រួលទៅដល់ជីវិតរបស់ពលរដ្ឋជាពិសេសអនីតិជន ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានសម្រេចឲ្យអនីតិជនមានស្វ័យភាពក្នុងការបង្កើតនូវកិច្ចសន្យាការងារ ប៉ុន្តែត្រូវគោរពនូវលក្ខខណ្ឌមួយចំនួន[19] ក៏ដូចជាមានចែងនៅក្នុងច្បាប់ពិសេស គឺច្បាប់ស្តីពីការងាររបស់ព្រះរាជាណាចក្រកម្ពុជា។

[18] កិច្ចការក្រុមការងារក្រសួងយុត្តធម៌ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២ ឆ្នាំ២០១៦

[19] មាត្រា ២៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

កិច្ចសន្យាការងារ គឺជាកិច្ចសន្យាដែលបង្កើតឲ្យមានការទាក់ទងផ្នែកការងាររវាងកម្មករនិយោជិត និង និយោជន។[20] មានន័យថាជនដែលបានចុះកិច្ចសន្យាការងារហើយ នឹងទទួលបាននូវសិទ្ធិ និងកាតព្វកិច្ចជាមួយនឹងនិយោជកដូចមានចែងក្នុងកិច្ចសន្យា។

យោងតាមច្បាប់ស្តីពីការងាររបស់ព្រះរាជាណាចក្រកម្ពុជា គេបានកំណត់អាយុអប្បបរមាសម្រាប់ការប្រកបការងារត្រឹម ១៥ ឆ្នាំ[21] ដោយក្នុងនោះក៏បានចែងផ្សេងៗទៀតនូវអាយុសម្រាប់ប្រភេទការងារដែលមានផលប៉ះពលមួយចំនួន។ សម្រាប់ក្រមរដ្ឋប្បវេណីវិញ អនីតិជនត្រូវបានការពារចំពោះការចុះកិច្ចសន្យាការងារដោយបញ្ញត្តិថា អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន មិនអាចធ្វើកិច្ចសន្យាការងារជំនួសអនីតិជនឡើយ។ បើពិនិត្យទៅមើលលើមាត្រា ១០៥៣ និងមាត្រា ១០៨០ ការងារចុះកិច្ចសន្យា អាចធ្វើបានតាមរយៈអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ប៉ុន្តែដើម្បីការពារនូវការកេងប្រវ័ញ្ចនូវពលកម្ម មាត្រា២៣ បានចងនូវលក្ខខណ្ឌដែលតម្រូវឲ្យអនីតិជនជាអ្នកចុះកិច្ចសន្យាផ្ទាល់ ព្រោះសកម្មភាពនេះ គឺបានបង្កើតនូវកាតព្វកិច្ចចំពោះអនីតិជនដូចនេះអនីតិជនត្រូវតែជាអ្នកផ្តល់ការយល់ព្រម។ គួរកត់សម្គាល់ថា ទោះបីជាអនីតិជនមានសិទ្ធិក្នុងការបង្កើតកិច្ចសន្យាការងារក៏ដោយ ក៏ត្រូវទទួលបានការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនទើបកិច្ចសន្យាការងារមានប្រសិទ្ធិភាព។ រីឯការរំលាយកិច្ចសន្យាការងាររបស់អនីតិជន បុគ្គលដែលអាចធ្វើការរំលាយកិច្ចសន្យានេះបាន គឺមានអ្នកអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬស្ថាប័នរដ្ឋបាល។[22] ការធ្វើបែបនេះបាន គឺក្នុងគោលបំណងការពារទៅលើប្រយោជន៍របស់អនីតិជន ពីព្រោះនៅពេលដែលកិច្ចសន្យាការងាររបស់អនីតិជនបានកើតឡើងពេញលេញហើយ (ដោយមានការយល់ព្រមពីអ្នកតំណាងដែលច្បាប់បានកំណត់) តែដោយហេតុមានការផ្លាស់ប្តូរបរិស្ថានការងារ ឬស្ថានភាពសេដ្ឋកិច្ចណាមួយ អាចនឹងធ្វើឲ្យអនីតិជនខូចប្រយោជន៍អនីតិជន។ នៅក្នុងនោះអ្នកមានសិទ្ធិរំលាយកិច្ចសន្យាការងារ ក៏មានស្ថានប័នរដ្ឋបាលដែរ។ ការបញ្ចូលស្ថាប័នរដ្ឋបាលឲ្យមានសិទ្ធិក្នុងការរំលាយកិច្ចសន្យាការងារនេះ ដោយសារពេលខ្លះមានលក្ខខណ្ឌចាំបាច់ដែលស្ថាប័នរដ្ឋបាលគួរមានសិទ្ធិក្នុងការរំលាយកិច្ចសន្យា ដើម្បីការពារនូវការកេងប្រវ័ញ្ចពលកម្មកុមារ ឬក្នុងករណីដែលអនីតិជនពុំមានអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនជាអាទិ៍។

[20] មាត្រា ៦៥ នៃច្បាប់ស្តីពីការងារ

[21] មាត្រា ១៧៧ នៃច្បាប់ស្តីការងារ

[22] មាត្រា ២៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

## ២.២.ទំនាក់ទំនងអនីតិជនក្នុងអំពើអនីត្យានុកូល

អំពើអនីត្យានុកូល គឺជាអំពើដែលបំពានដោយខុសច្បាប់ទៅលើសិទ្ធិ ឬផលប្រយោជន៍របស់អ្នកដទៃដោយកំហុសចេតនា ឬកំហុសអចេតនា។ ដូច្នេះបុគ្គលដែលត្រូវបានបំពាននូវសិទ្ធិ និងផលប្រយោជន៍មានសិទ្ធិទាមទារនូវសំណងនៃការខូចខាតនេះពីបុគ្គលដែលបានបង្កការខូចខាតនេះ។

ចំពោះលក្ខខណ្ឌនៃការទទួលខុសត្រូវលើអំពើអនីត្យានុកូលវិញ គឺជាលក្ខខណ្ឌ ឬធាតុផ្សំដែលត្រូវតែបំពេញឲ្យគ្រប់ចំនួនកំណត់ ដើម្បីអាចធ្វើការទាមទារ ការទទួលខុសត្រូវលើកំហុសចេតនា ឬអចេតនាដែលត្រូវបានបង្កឡើងដោយចារី។ យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា៧៤៣ ធាតុផ្សំនីត្យានុកូលនៃអំពើអនីត្យានុកូលមានដូចជា៖

- កំហុសអាចជាកំហុសចេតនាឬកំហុសអចេតនា
- ការខូចខាតឬព្យសនកម្ម
- ទំនាក់ទំនងហេតុនិងផល។

### ២.២.១.កំហុស[23]

ការកំណត់អំពី ការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល គឺទាមទារឲ្យមានកំហុសនៅពេលមានព្យសនកម្មកើតឡើងហើយកំហុស គឺជាស្ថានភាពផ្លូវចិត្តរបស់បុគ្គលម្នាក់ៗដោយខ្លួនអាចយល់ដឹងអំពីនោះ និងលទ្ធផលដែលកើតចេញពីអំពើរបស់ខ្លួន។ កំហុសមានពីរ(២) ប្រភេទ គឺកំហុសចេតនា និងកំហុសអចេតនា។ កំហុសចេតនា គឺជាការបំពានករណីកិច្ចប្រុងប្រយ័ត្នមិនយកចិត្តទុកដាក់ចំពោះកាតព្វកិច្ចដែលច្បាប់កំណត់ ចំណែកកំហុសអចេតនា គឺជាការប្រព្រឹត្តអំពើណាមួយដោយបុគ្គលនោះអាចយល់ដឹងឬព្យាករណ៍ទុកមុនបានអំពីលទ្ធផលនៃអំពើរបស់ខ្លួនថានឹងអន្តរាយដល់អ្នកដទៃបាន។

ជាគោលការណ៍ជនដែលបំពានលើសិទ្ធិ ឬផលប្រយោជន៍របស់អ្នកដ៏ទៃទោះបីជាសំភារៈឬស្មារតីបុគ្គលនោះត្រូវទទួលខុសត្រូវចំពោះសំណងនៃការខូចខាតដោយសារកំហុសរបស់ខ្លួន ក៏ប៉ុន្តែមានករណីខ្លះ គឺជាអញ្ញត្រកម្មដោយមិនចំណុះឲ្យមានកំហុសនោះទេដូចជា អំពើអន្យានុកូលដែលកើតមានពីគ្រោះថ្នាក់ចរាចរណ៍ បរិស្ថាន ឬផលិតផលជាអាទិ៍។ កាតព្វកិច្ចបញ្ជាក់អំពីកំហុសជា(ជនរងគ្រោះ) ក៏ប៉ុន្តែនៅក្នុងករណីខ្លះ កាតព្វកិច្ចក្នុងការបញ្ជាក់កំហុសនេះត្រូវធ្លាក់លើចារីវិញ ដោយហេតុថាជនរងគ្រោះពុំមានកាតព្វកិច្ចក្នុងការបញ្ជាក់នោះឡើយ។

---

[23] អ៊ុំ ប៉ូលី <នីតិរដ្ឋប្បវេណី> (មេរៀនសង្ខេបសម្រាប់សមាជិកគណៈមេធាវី, គណៈមេធាវី, ២១ ធ្នូ ២០១១)

### ២.២.២.ការខូចខាត[24]

ព្យសនកម្ម គឺការខូចខាតដែលបង្កឡើងដោយអំពើរបស់បុគ្គលណាមួយ ឬដោយវត្ថុ សត្វ ចិញ្ចឹមហើយ ព្យសនកម្មនោះកើតឡើងលើទ្រព្យសម្បត្តិ រូបរាងកាយ និងផ្លូវចិត្ត។ ព្យសនកម្មត្រូវតែកើតឡើងផ្ទាល់ ដូចខាងក្រោមនេះ៖

•ព្យសនកម្មកើតឡើងផ្ទាល់ ជាគោលការណ៍ព្យសកម្មត្រូវតែកើតឡើងដោយផ្ទាល់ទៅលើជនរងគ្រោះ ហើយត្រូវកើតឡើងនៅក្នុងពេលបច្ចុប្បន្នទៀតផង មានន័យថា ព្យសនកម្មមិនអាចកើតទៅលើក្រុមគ្រួសារ ឬសាច់ញាតិរបស់ជនរងគ្រោះបានឡើយ។

•ត្រូវនៅក្នុងពេលបច្ចុប្បន្ននៅពេលមានអំពើបង្ក ហើយវាបណ្តាលឲ្យមានការខូចខាចកើតឡើងភ្លាមៗពោល គឺនៅពេលបច្ចុប្បន្ន។ ប៉ុន្តែ ក៏មានព្យសនកម្មមួយចំនួនអាចកើតឡើងនៅពេលអនាគតផងដែរ។ ទាំងនេះ មួយចំនួនត្រូវហាមឃាត់ និងត្រូវបានលុបចោលដោយអ្នកមានសិទ្ធិ។ ក៏ប៉ុន្តែមានសកម្មភាពមួយចំនួនក៏ច្បាប់អនុញ្ញាតផងដែរដូចជាសកម្មភាពដែលរស់នៅប្រចាំថ្ងៃ និងសកម្មភាពមួយចំនួនទៀតដែលត្រូវច្បាប់កំណត់ថាត្រូវមានការអនុញ្ញាតពីបុគ្គលដែលគ្រប់គ្រងរបបនោះ។

### ២.២.៣.ទំនាក់ទំនងហេតុ និងផល

ទំនាក់ទំនង និងហេតុផលនៃការកើតឡើងនូវការខូចខាតចំពោះជនរងគ្រោះ និងចេតនា ឬកំហុសរបស់ចារី។ ក្នុងន័យនេះមានន័យថាព្យសនកម្មត្រូវកើតឡើងដោយមានភាពស៊ីសង្វាក់គ្នារវាង ហេតុ និងចេតនា ឬកំហុស ដូចជា ប្រសិនបើការខូចខាតដោយអំពើរបស់វត្ថុត្រូវកើតឡើងបណ្តាលមកពីវត្ថុ ពុំមែនបង្កឡើងដោយមនុស្សទេនោះពុំអាចចាប់បង្ខំបុគ្គលនោះឲ្យទទួលខុសត្រូវនូវព្យសនកម្មដែលពុំមាន ទំនាក់ទំនងរវាងហេតុនិងបច្ច័យនោះបានឡើយ។

•ព្យសនកម្មត្រូវកើតឡើងដោយផ្ទាល់ពីកំហុស[25]៖ បើគ្មានអំពើបង្កឡើងឲ្យមានការខូចខាតកើតឡើងទេក៏កំហុសពុំកើតមានដែរដូចនេះចាត់ទុកថាកំហុសបានត្រូវមានច្បាប់ចែងទុកជាមុនច្បាស់លាស់ទើបអាច ចាប់បង្ខំបុគ្គលណាមួយទទួលខុសត្រូវនូវកំហុសនោះបាន។

•ព្យសនកម្មត្រូវកើតឡើងដោយផ្ទាល់៖ ការខូចខាតត្រូវតែស៊ីសង្វាក់គ្នាជាមួយ នឹងអំពើប្រព្រឹត្តផ្ទាល់ក្នុងករណី ពុំអាចរកឃើញអំពើផ្ទាល់ទេ គឺគ្មានភស្តុតាងក្នុងការដាក់បន្ទុកដើម្បីចាប់បង្ខំឲ្យមានការទទួលខុសត្រូវឡើយ។

[24] សាស្ត្រាចារ្យ ខាំ សុមករា <អំពើអនីត្យានុកូល> ឆ្នាំ២០១៣

[25] សាស្ត្រាចារ្យ ញឹក រិទ្ធី សៀវភៅនីតិកាតព្វកិច្ច ភាគ២ មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បោះពុម្ពលើកទី១ ឆ្នាំ២០២១

នៅពេលដែលមានមូលដ្ឋានសំអាងពិសេសដោយផ្អែកទៅលើចរិកលក្ខណៈ និងផលប្រយោជន៍ដែលទទួលបានការការពារនាំឲ្យបុគ្គល ដែលធ្វើសកម្មភាពអាចរួចផុតពីការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលបានបើការបំពាននោះមានលក្ខណៈខុសច្បាប់ ដូចជាកិច្ចការពារជាធម្មានរូបស្ថានភាពចាំបាច់ និងមូលហេតុផ្សេងទៀត។

ជាទូទៅនៅគ្រប់អំពើអនីត្យានុកូលមិនមែនសុទ្ធតែបុគ្គលដែលជាអ្នកត្រូវទទួលខុសត្រូវ ចំពោះអំពើនោះទេ ហើយអាចជាអ្នកផ្សេងទៅវិញ ដែលជាអ្នកត្រូវទទួលខុសត្រូវ។ ក្នុងករណីនេះហៅថាការទទួលខុសត្រូវលើអំពើអ្នកដទៃ ដែលនៅក្នុងនោះយើងនឹងធ្វើការសិក្សាទៅលើការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលដែលបង្កឡើងដោយអនីតិជន។

ចំពោះគោលការណ៍នៃការទទួលខុសត្រូវ ចំពោះឆន្ទៈបុគ្គលដែលពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការវិនិច្ឆ័យដោយសារមានបញ្ហាផ្នែកបញ្ញាស្មារតី ឬដោយសារអាយុរបស់បុគ្គលនោះ នាំឲ្យបុគ្គលនោះមិនទទួលខុសត្រូវទៅលើអំពើដែលខ្លួនបានបង្កឡើងឡើយ។

ដោយយោងតាមមាត្រា ៧៤៥ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បុគ្គលដែលគ្មានការទទួលខុសត្រូវលើអំពើផ្ទាល់ខ្លួនគឺ អសមត្ថកិច្ច ឬជន អសមត្ថភាព។ អសមត្ថកិច្ច គឺជាជនដែលមានសមត្ថភាពពិចារណាមិនគ្រប់គ្រាន់ចំពោះអំពើ និងព្យសនកម្ម ដែលបានកើតឡើងពីអំពើរបស់ខ្លួនផ្ទាល់ ដែលសំដៅដល់ **អនីតិជនក្រោមអាយុ១៤ឆ្នាំ និងអនីតិជនចាប់ពីអាយុ១៤ឆ្នាំឡើងទៅ** ដែលមានក្នុង(ក) និង(ខ)។

**ក.អនីតិជនក្រោមអាយុ១៤ឆ្នាំ**

ការរស់នៅក្នុងសង្គមសម័យទំនើបនេះ កុមារទាំងអស់កាន់តែមានការលូតលាស់ខាងផ្នែកបញ្ញាស្មារតីក្នុងការដឹងខុសត្រូវទៅលើសកម្មភាពដែលគួរធ្វើ និងមិនគួរធ្វើ។ ការលូតលាស់ខាងផ្នែកបញ្ញាស្មារតី គឺអាស្រ័យទៅតាមបុគ្គលម្នាក់ៗ ហេតុនេះហើយសមត្ថភាពអាចត្រូវបានគេកំណត់ទៅតាមករណីនីមួយៗ។ នេះមានន័យថាទោះបីជាក្មេងដែលមានអាយុត្រឹមតែ(១៣)ឆ្នាំក៏ដោយ ក៏អាចមានប្រាជ្ញាគ្រប់គ្រាន់ ដើម្បីទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលបានដែរ ចំពោះជនដែលមានអាយុ២១ឆ្នាំ ក៏នៅតែអាចទទួលបានការការពារដោយច្បាប់ដែរដោយសារតែជននោះខ្វះសមត្ថភាព ក៏ប៉ុន្តែដើម្បីធ្វើការបញ្ជាក់អំពីលក្ខណៈនៃការវិនិច្ឆ័យឲ្យបានច្បាស់លាស់ច្បាប់បានបញ្ញត្តិនូវលក្ខណៈនៃការវិនិច្ឆ័យ ដោយកំណត់ការទទួលខុសត្រូវ។ តាមបញ្ញត្តិមាត្រា៧៤៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានចែងថា ជនដែលមានអាយុក្រោម(១៤ឆ្នាំ) មិនទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលទេ។ ហេតុដូច្នេះហើយ ជនរងគ្រោះមិនអាចធ្វើការអះអាងបានទេថាអនីតិជនដែលមានអាយុក្រោម (១៤ឆ្នាំ) ត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលនោះមានប្រាជ្ញាខ្ពស់យ៉ាងណាក៏ដោយ។ ប៉ុន្តែយោងតាមមាត្រា៧៤៦ កថាខណ្ឌទី១ វិញបានចែងថា បុគ្គលដែលមានករណីកិច្ចដែលបាន

កំណត់ដោយច្បាប់ក្នុងការត្រួតពិនិត្យអនីតិជនអាយុក្រោម (១៤ឆ្នាំ) ឬបុគ្គលដែលស្ថិតក្នុងស្ថានភាពដែលមិនអាចយល់ដឹង និងវិនិច្ឆ័យបានអំពីការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ឬមូលហេតុផ្សេងទៀត មានករណីយកិច្ចត្រូវសងការខូចខាតរបស់អ្នកដទៃ ដែលកើតឡើងដោយអំពើបំពានរបស់បុគ្គលនៅក្រោមការត្រួតពិនិត្យរបស់ខ្លួន។

**ខ.អនីតិជនចាប់ពី១៤ឆ្នាំ**

យោងតាមមាត្រា៧៤៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បុគ្គលដែលមានករណីកិច្ចត្រួតពិនិត្យអនីតិជនចាប់ពីអាយុ១៤ឆ្នាំឡើងទៅ ត្រូវមានការទទួលខុសត្រូវដោយសាមគ្គីភាពជាមួយអនីតិជននោះ។ មានន័យថា នៅពេលដែលអនីតិជនបានបង្កឲ្យមាននូវការបំពានណាមួយ ដែលបណ្តាលឲ្យមានការប៉ះពាល់ដល់អ្នកដទៃ ពេលនោះអនីតិជនត្រូវតែធ្វើការជួសជុលនូវការខូចខាតតាមរយៈសំណងសម្រាប់ជនរងគ្រោះ។

ប៉ុន្តែប្រសិនបើអនីតិជននោះពុំអាចធ្វើការទូទាត់នូវសំណងនោះបានទេ ពេលនោះហើយទើបការទទួលខុសត្រូវ ត្រូវធ្លាក់ទៅលើអ្នកដែលមានករណីយកិច្ចត្រួតពិនិត្យក្នុងការចេញនូវសំណងជំនួសអនីតិជននោះ ឬជួយបំពេញបន្ថែមទៅលើអ្វីដែលអនីតិជននោះពុំមានលទ្ធភាព។

# ជំពូកទី៣

## ការទទួលខុសត្រូវអនីតិជននៅក្នុងនីតិព្រហ្មទណ្ឌ

# ជំពូកទី៣
# ការទទួលខុសត្រូវអនីតិជននៅក្នុងនីតិព្រហ្មទណ្ឌ

នៅក្នុងនីតិព្រហ្មទណ្ឌ ជាគោលការណ៍ទូទៅ នៅពេលដែលមានបទល្មើសមួយកើតឡើងទោះអំពីនោះ ប្រព្រឹត្តឡើងដោយចេតនាក្តី ឬដោយអចេតនាក្តី ដែលជាហេតុបណ្តាលឲ្យមានព្យសន្តកម្មដល់បុគ្គលដទៃ គឺជាលក្ខខណ្ឌចម្បងនៃការទទួលខុសត្រូវព្រហ្មទណ្ឌ។ នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់ចាប់ពីអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ។[26] ប៉ុន្តែតុលាការ ក៏អាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ(**៣.២.១**) បានផងដែរ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ(**៣.១.២**)។

## ៣.១.កាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជន

យោងតាមគោលការណ៍នៃការកំណត់អំពីទណ្ឌកម្ម ឬគោលការណ៍ក្នុងការកំណត់ការផ្តន្ទាទោស ចៅក្រមដើម្បីអាចផ្តន្ទាទោសជនល្មើសណាម្នាក់បាន ត្រូវពិចារណាអំពីបាតុកម្មសង្គមដែលបទល្មើសបានកើតឡើងឲ្យបានគ្រប់ជ្រុងជ្រោយជាមុនសិន ទើបធ្វើការសម្រេចផ្តន្ទាទោសទៅលើចារីនោះ។ មានន័យថា ដើម្បីអាចចេញនូវសេចក្តីសម្រេចប្រកបដោយសុក្រិត្យភាព និងសុភវិនិច្ឆ័យចៅក្រមត្រូវពិចារណា ទៅលើបីចំណុចសំខាន់ៗគឺ ទីមួយ ត្រូវពិចារណាពាក់ព័ន្ធនឹងបញ្ហាដែលមានចែងនៅក្នុងច្បាប់ ពោលគឺសំដៅទៅដល់គោលការណ៍នីត្យានុកូលនៃទោស។ ទីពីរ គឺត្រូវពិចារណាទៅលើស្ថានភាពនៃការប្រព្រឹត្តបទល្មើស តើបទល្មើសនោះបានប្រព្រឹត្តនៅក្នុងកាលៈទេៈណា? ពេលវេលាណា? ទីបី គឺត្រូវពិនិត្យទៅលើបុគ្គលិកលក្ខណៈរបស់ជនល្មើសនោះផងដែរ?

### ៣.១.១.កាលៈទេសៈនៃបទល្មើស

ដោយហេតុថា ច្បាប់ពុំបានកំណត់អំពីនិយមន័យ ឬផ្តល់នូវលក្ខណៈវិនិច្ឆ័យនៃពាក្យកាលៈទេសៈនៃបទល្មើសឲ្យបានជាក់លាក់ ដូចនេះអាចឲ្យគេយល់បានថា កាលៈទេសៈនៃបទល្មើស គឺសំដៅទៅលើកត្តារួមផ្សំនៃបទល្មើសនេះឯង។ មានន័យថា កត្តាទាំងនេះ គឺស្ថិតនៅក្នុងធាតុសន្យានុម័តនៃបទល្មើសផ្ទាល់តែម្តង ពោល គឺវាមានតួនាទីសម្រាប់កំណត់បទល្មើស និងកំណត់អំពីព្រំដែននៃទណ្ឌកម្មផងដែរ។ ដើម្បីឲ្យងាយយល់កាន់តែច្បាស់ជាងនេះទៅទៀតនោះគឺ យើងអាចធ្វើការសិក្សាស្វែងយល់ និងពិចារណាតាមរយៈបទពិសោធន៍ជាក់ស្តែងរបស់ចៅក្រមក្នុងការពិចារណា និងសម្រេចអំពីទណ្ឌកម្មជាក់ស្តែងទៅលើអនីតិជនដែលជាជនល្មើស តាមរយៈកត្តារួមផ្សំដូចខាងក្រោម[27]៖

---

[26] ច្បាប់ស្តីពីយុត្តធម៌អនីតិជន មាត្រា ៧ ឆ្នាំ២០១៦

[27] សាស្ត្រាចារ្យ ហ៊ី សោភា, នីតិព្រហ្មទណ្ឌទូទៅ,ទំព័រ ៧៣

**មធ្យោបាយប្រព្រឹត្តបទល្មើស**

មធ្យោបាយប្រព្រឹត្តបទល្មើស សំដៅលើបណ្តាលវត្ថុ ឬសម្ភារៈ និងរួមបញ្ចូលទាំងឧបករណ៍ប្រព្រឹត្តបទល្មើសផងដែរ ដែលអនីតិជននោះបានប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើស។

ឧទាហរណ៍៖ ប្រសិនបើជាអនីតិជនម្នាក់ បានប្រព្រឹត្តអំពើហិង្សាទៅលើអនីតិជនម្នាក់ទៀតដោយប្រើប្រាស់អាវុធ ឬគំរាមកំហែងនឹងអាវុធ ជាសញ្ញាមួយនៃស្ថានទម្ងន់ទោសក្នុងបទហិង្សាដោយចេតនា។[28]

**វិធីសាស្ត្រប្រព្រឹត្តបទល្មើស**

វិធីសាស្ត្រប្រព្រឹត្តបទល្មើសសំដៅទៅលើបែបផែននៃវិធីក្នុងការប្រព្រឹត្តនូវអំពើល្មើសច្បាប់មួយឡើង។

ឧទាហរណ៍៖ អនីតិជនម្នាក់ដែលមានអាយុ ១៥ឆ្នាំ បានប្រើឧបាយកលទុច្ចរិត ទៅលើអនីតិជនម្នាក់ទៀត ដើម្បីឲ្យអនីតិជននោះ ប្រគល់នូវទ្រព្យសម្បត្តិអ្វីមួយឲ្យមកខ្លួន។ នេះជាសញ្ញាមួយសម្រាប់កំណត់ល្មើសឆបោក ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ មាត្រា៣៧៧។

**ពេលវេលាប្រព្រឹត្តបទល្មើស**

ពេលវេលាប្រព្រឹត្ត អាចជាពេលមួយ ឬរយៈពេលមួយជាកំណត់ ដែលអំពើល្មើសច្បាប់ព្រហ្មទណ្ឌបានស្តែងចេញមកខាងក្រៅ។ មានន័យថា នៅក្នុងច្បាប់ព្រហ្មទណ្ឌ ពេលវេលាប្រព្រឹត្តបទល្មើស អាចជាសញ្ញាមួយសម្រាប់កំណត់នូវបទល្មើសផ្ទាល់តែម្តង។

**ទីកន្លែងប្រព្រឹត្តបទល្មើស**

ទីកន្លែងប្រព្រឹត្តបទល្មើស មានន័យថា ជារង្វង់ដែនដីមួយជាកំណត់ ដែលនៅទីនោះបទល្មើសបានចាប់ផ្តើម និងបញ្ចប់ ឬនៅទីនោះបច្ច័យនៃអំពើល្មើសច្បាប់ព្រហ្មទណ្ឌបានកើតឡើង។ មានន័យថាទីកន្លែងអាចជាចំណុចណាមួយ ឬជាតំបន់ដែនដីណាមួយជាកំណត់ ដែលច្បាប់ព្រហ្មទណ្ឌបានបញ្ញត្តិថា វាជាទីកន្លែងមួយដែលសម្រាប់កំណត់នូវបទល្មើសព្រហ្មទណ្ឌ។

**ទិដ្ឋភាពនានាជុំវិញបទល្មើស**

ទិដ្ឋភាពនានាជុំវិញបទល្មើស ជាការសរុបនូវរាល់ករណីលំអិតនានាផ្នែកសន្យានុម័តជុំវិញការប្រព្រឹត្តបទល្មើសដែលមានឥទ្ធិពលទៅលើកម្រិតគ្រោះថ្នាក់ដល់សង្គមនៃបទល្មើស។ ដែលទិដ្ឋភាពជុំវិញនៃបទល្មើសទាំងនោះ ត្រូវបានច្បាប់បញ្ញត្តិថា ជាសញ្ញានៃស្ថានទម្ងន់ទោស ឬស្ថានសម្រាលទោសផងដែរ។

---

[28] មាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ឧទាហរណ៍៖ អនីតិជនអាយុ ១៥ឆ្នាំ ម្នាក់ បានប្រព្រឹត្តបទ មនុស្សឃាតដោយអចេតនាដោយសារកាលៈទេសៈ ឬដោយសារស្ថានភាពចិត្តសាស្ត្ររបស់អនីតិជននោះជាសញ្ញាណនៃការទទួលបាននូវស្ថានសម្រាលទោស [29]។

### ៣.១.២.បុគ្គលិកលក្ខណៈរបស់អនីតិជន

យោងតាមមាត្រា ៦៤ ចំណុច គ នៃច្បាប់ស្តីពីយុត្តធម៌អនីតិជន បានចែងថា បុគ្គលិកលក្ខណៈរបស់អនីតិជនមានដូចជាអាយុ កម្រិតយល់ដឹង បញ្ញា និងអត្តចរិករបស់អនីតិជននោះ។ ត្រង់ចំណុចនេះដែរ យើងឃើញថា នីតិករមានចង្អុលបង្ហាញឲ្យឃើញយ៉ាងជាក់លាក់អំពីអត្ថន័យនៃពាក្យ បុគ្គលិកលក្ខណៈនេះផ្ទាល់តែម្តង គឺក្នុងគោលដៅដើម្បីបញ្ចៀសកុំឲ្យអ្នកសិក្សា ឬ អ្នកអនុវត្តច្បាប់មានការភណ្ឌ័ច្រឡំទៅលើអត្ថន័យនៃពាក្យពេចន៍នេះ ហើយព្យាយាមធ្វើការបកស្រាយប្រាសចាកពីគោលគំនិតដើមរបស់ច្បាប់។ ទាញចេញពីខ្លឹមសារខាងលើ អាចឲ្យគេយល់បានថា បុគ្គលិកលក្ខណៈរបស់អនីតិជន សំដៅទៅលើសមត្ថភាពទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់អនីតិជននោះផ្ទាល់តែម្តងចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត។ ដូច្នេះតុលាការមុននឹងធ្វើការប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនបាន ត្រូវពិចារណាអំពីការរីកចម្រើននៃរូបរាងកាយរបស់អនីតិជន ប្រាជ្ញា ស្មារតី និងបទពិសោធន៍ក្នុងជីវភាពរស់នៅរបស់អនីតិជននោះជាមុនសិន។

## ៣.២.ការកំណត់អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

អនីតិជន គឺជាជនដែលមិនទាន់គ្រប់អាយុទៅតាមច្បាប់កំណត់ ឬជនដែលមានអាយុក្រោម ១៨ ឆ្នាំ ឬជាជន ដែលច្បាប់មិនទាន់ឲ្យទទួលខុសត្រូវលើអំពើដែលខ្លួនបានប្រព្រឹត្ត ឬជាជនដែលច្បាប់កំណត់ឲ្យទទួលខុសត្រូវព្រហ្មទណ្ឌមានកម្រិត[30]។ ដើម្បីឲ្យអនីតិជនទទួលខុសត្រូវព្រហ្មទណ្ឌច្បាប់បានកំណត់ពីអាយុរបស់បុគ្គលនេះ។ ដើម្បីឈានទៅដល់ការដាក់ទណ្ឌកម្មណាមួយយកទៅអនុវត្តលើអនីតិជន ច្បាប់កំណត់ពីនីតិភាពនៃការទទួលខុសត្រូវលើការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។ នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវកំណត់ចាប់ពីអាយុ ១៨ ឆ្នាំ ឡើងទៅ។ ប៉ុន្តែតុលាការអាច នឹងប្រកាសទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ ឆ្នាំឡើង ប្រសិនបើកាលៈទេសៈតម្រូវ ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ[31]។ ដូច្នេះបើអនីតិជនដែលប្រព្រឹត្តបទល្មើសមានអាយុចាប់ពី ១៤ ឆ្នាំឡើង ហើយតុលាការយល់ឃើញថាជននោះមានភាពចាស់ទុំស្មារតីគ្រប់គ្រាន់ទៅតាមអាយុ អត្តចរិក និងកម្រិតយល់ដឹង ហើយការប្រព្រឹត្តបទល្មើសជាច្រើនដងដោយមិនរាងចាល

---

[29] ក្រមព្រហ្មទណ្ឌ មាត្រា៩៣ មាត្រា២០៧ ឆ្នាំ២០០៩

[30] សន្ទានុក្រមព្រហ្មទណ្ឌ ឆ្នាំ២០១១,លេខរៀង ២៣០

[31] ច្បាប់ស្តីពីយុត្តធម៌អនីតិជន ឆ្នាំ២០០៦ មាត្រា៧

ក៏អាចតម្រូវឲ្យទទួលខុសត្រូវចំពោះបទល្មើសព្រហ្មទណ្ឌរបស់ខ្លួនផងដែរ[32] លើកលែងតែករណីមានចែង ពិសេសក្នុងច្បាប់ផ្សេងទៀត។

ចំពោះការកំណត់អាយុនេះ អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជនត្រូវកំណត់យកអាយុនៅថ្ងៃដែលអនីតិជននោះប្រព្រឹត្តបទល្មើស។ ភស្តុតាងនៃអាយុរបស់អនីតិជននោះត្រូវបានបញ្ជាក់ដោយសំបុត្រកំណើត[33] ឬឯកសារផ្សេងៗទៀតដែលអាចបញ្ជាក់បានពីកំណើត។ ក្នុងករណីពុំមានឯកសារ ឬមានការសង្ស័យអំពីអាយុរបស់អនីតិជន វិមតិសង្ស័យត្រូវបានជាអត្ថប្រយោជន៍ដល់អនីតិជន ឬប្រសិនបើមានភាពច្បាស់លាស់នឹងយថាភូតនៃឯកសារ ភស្តុតាងនៃអាយុរបស់អនីតិជនអាចផ្តល់តាមគ្រប់មធ្យោបាយផ្សេងទៀតដែលអាជ្ញាធរតុលាការអាចជឿទុកចិត្តបាន។

អាជ្ញាធរមានសមត្ថកិច្ចត្រូវស្វះស្វែងរកភស្តុតាង ដើម្បីកំណត់អាយុរបស់អនីតិជនឲ្យបានឆាប់រហ័សបំផុតដែលអាចធ្វើទៅបាន។ ហេតុដូច្នេះ ពេលខ្លះភាពលំបាកអាចកើតមានឡើងក្នុងការកំណត់ពីអាយុរបស់អនីតិជន ជាពិសេសគឺនៅដំណាក់កាលនគរបាលយុត្តិធម៌ ដែលជាដំណាក់កាលដំបូងនៅពេលដែល អនីតិជនណាម្នាក់បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។ក្នុងករណីដែលអនីតិជនមិនបានដឹងអំពីកាលបរិច្ឆេទនៃកំណើតនិងពុំមានសំបុត្រកំណើតផងនោះ នគរបាលយុត្តិធម៌ត្រូវប្រឹងប្រែងស្វែងរកព័ត៌មានពីក្រុមគ្រួសាររបស់អនីតិជន។ ហើយអនីតិជន ឬឪពុកម្តាយ ឬសមាជិកដទៃទៀតក្នុងគ្រួសារ នឹងត្រូវតែបានគេសាកសួរថា តើអនីតិជននោះកើតឡើងក្នុងអំឡុងពេល ឬក្នុងរដូវកាលជាក់លាក់ណាមួយ។

ជាមួយគ្នានេះដែរ ដើម្បីឆ្លើយតបទៅនឹងលក្ខខណ្ឌអាយុខាងលើ សូមធ្វើការបែងចែកអនីតិជនជាពីរប្រភេទ៖

**៣.២.១.អនីតិជនដែលមានអាយុក្រោម១៤ឆ្នាំ**

អនីតិជនប្រភេទនេះ នៅពេលដែលប្រព្រឹត្តបទល្មើស គឺច្បាប់បានកំណត់ថា មិនឲ្យទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។ ដោយហេតុថា ទាញចេញអនុសញ្ញាស្តីពីសិទ្ធិកុមារត្រង់មាត្រា ៤០ ចំណុចទី៣ កថាខណ្ឌ ក បានតម្រូវឲ្យរដ្ឋជាភាគី ដែលក្នុងនោះក៏មានព្រះរាជាណាចក្រកម្ពុជាផងដែរ ត្រូវធ្វើការកំណត់កម្រិតអាយុអប្បបរមានៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់កុមារដែលក្រោមអាយុអប្បបរមានេះ កុមារត្រូវបានសន្មតជាមុនថា ពុំមានសមត្ថភាពនឹងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌឡើយ[34]។ រីឯមាត្រា ១៤ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ប្រកាសឲ្យប្រើ នៅថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៦ បានចែងថា "អនីតិជនមានអាយុក្រោម១៤

[32] សេចក្តីព្រាងស្តីពី សៀវភៅមគ្គុទ្ទេសសម្រាប់នគរបាលយុត្តធម៌ ស្តីពីនីតិវិធីនគរបាលយុត្តធម៌បែបកុមារមេត្រី ឆ្នាំ២០០៧

[33] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ២០០០,មាត្រា២,កថាខណ្ឌទី២ និងទី៣

[34] អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ៤០ ចំណុចទី៣ កថាខណ្ឌ ក

(ដប់បួន) ឆ្នាំ ដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើស ពុំអាចត្រូវបានគេឃាត់ខ្លួនឡើយ ហើយមន្ត្រីនគរបាលយុត្តធម៌ត្រូវប្រគល់អនីតិជននោះទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់”។ ចំណែកមាត្រា២៧ នៃច្បាប់ស្តីពីយុត្តធម៌អនីតិជន កថាខណ្ឌទី១ ក៏បានចែងផងដែរថា “ក្នុងករណី អនីតិជនមានអាយុក្រោម១៤ (ដប់បួន) ឆ្នាំ គិតមកត្រឹមថ្ងៃដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើសនោះព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ និងត្រូវប្រគល់អនីតិជនទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់វិញភ្លាម” ជាមួយគ្នានេះដែរ ក៏មានបញ្ញត្តិនៅ មាត្រា៣៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន កថាខណ្ឌទី១ វាក្យខណ្ឌទី១ ដដែលនេះបានចែងថា អនីតិជនអាយុក្រោម១៤ (ដប់បួន) ឆ្នាំមិនត្រូវបានឃុំខ្លួនបណ្តោះអាសន្នឡើយ។

តាមខ្លឹមសារខាងលើនេះ អាចនាំឲ្យគេសន្និដ្ឋានបានថា អាយុ១៤ (ដប់បួន) ឆ្នាំ ជាកម្រិតអាយុអប្បបរមានៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ឬអនីតិជនអាយុក្រោម១៤(ដប់បួន)ឆ្នាំ ពុំទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនោះទេ។

ឧទាហរណ៍៖ ក្មេងប្រុសម្នាក់ អាយុ៩ ឆ្នាំ បានចោលដុំថ្មលេងមិនប្រយ័ត្ន បណ្តាលឲ្យត្រូវក្បាលក្មេងប្រុសម្នាក់ទៀតរងរបួសបែកក្បាលជាដំណំ។ ក្នុងករណីនេះ ក្មេងដែលបានប្រព្រឹត្តអំពើល្មើសនោះ មិនអាចត្រូវទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ អាស្រ័យដោយហេតុថាក្មេងនោះនៅមិនទាន់មានការយល់ដឹងខុសត្រូវពីអំពើរបស់ខ្លួននៅឡើយ។

គួរគត់សម្គាល់ថា អាយុក្រោម១៤ (ដប់បួន) ឆ្នាំ សច្ចធារណ៍មិនអាចប្រកែកបាននៃការមិនទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដែលរារាំងមិនឲ្យតុលាការធ្វើការប្រកាសទោសទៅលើអនីតិជននោះឡើយ។ ប៉ុន្តែមិនមែនមានន័យថា បានរារាំងចំពោះការចូលខ្លួនមកកាន់តុលាការ និងការប្រកាសសេចក្តីសម្រេចនោះទេ (ការស្តីបន្ទោស ឬវិធានអប់រំ)។ ដូច្នេះ តុលាការក៏នៅតែអាចធ្វើការកោះហៅអនីតិជននោះឲ្យចូលខ្លួនមកកាន់តុលាការបានផងដែរ ក្នុងគោលបំណងដើម្បីប្រកាសសេចក្តីសម្រេចដាក់ឲ្យអនុវត្តនូវវិធានការណាមួយ ដែលតុលាការបានធ្វើការសម្រេចលើអនីតិជននោះ។ វិធានការទាំងនោះរួមមាន វិធានការតាមដាន វិធានការអប់រំ វិធានការឧបត្ថម្ភ ឬក៏ប្រគល់អនីតិជននោះទៅឲ្យសាច់ញាតិ សេវាសាធារណៈ អង្គការឯកជនដែលមាននីតិសម្បទា មន្ទីរពេទ្យ ឬស្ថានប័នឯកទេស និងអាចដាក់អនីតិជននោះឲ្យស្ថិតក្រោមការការពាររបស់តុលាការបានផងដែរ[35]។

[35] មាត្រា ៤០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

### ៣.២.២. អនីតិជនដែលមានអាយុចាប់ពី១៤ ឆ្នាំ ដល់ ក្រោម១៨ ឆ្នាំ

ចំពោះអនីតិជនប្រភេទនេះវិញ នៅពេលដែលជននេះបានប្រព្រឹត្តបទល្មើស គឺត្រូវទទួលខុសត្រូវលើអំពើដែលខ្លួនបានប្រព្រឹត្តនោះ។ ហេតុដែលច្បាប់តម្រូវឲ្យជននេះមានការទទួលខុសត្រូវ ព្រោះយល់ឃើញថា អនីតិជនប្រភេទនេះ មានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌហើយ។ សមត្ថភាពទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ គឺជាលទ្ធភាពរបស់មនុស្សនៅពេលដែលប្រព្រឹត្តអំពើបង្កគ្រោះថ្នាក់ដល់សង្គម ហើយជននោះអាចយល់ដឹងអំពីចរិតគ្រោះថ្នាក់នៃអំពើរបស់ខ្លួន នឹងអាចបញ្ជានូវរាល់អំពើទាំងនោះបាន។ ការយល់ឃើញយ៉ាងដូច្នេះ អាស្រ័យដោយហេតុថា នីតិករបានពិចារណាដោយផ្អែកទៅលើ ការរីកចម្រើនអំពី រូបរាងកាយ ប្រាជ្ញា ស្មារតី និង ការសន្សំនូវរាល់បទពិសោធន៍នៃជីវិតក្នុងជីវភាពរស់នៅកន្លងមករបស់អនីតិជននោះឯង។ កត្តាទាំងអស់នេះហើយ ដែលជាហេតុនាំឲ្យច្បាប់សន្មតថា អនីតិជនប្រភេទនេះអាចពិចារណាយល់ដឹងបានគ្រប់គ្រាប់នូវបណ្តាការទាមទារ និងរបបកំណត់របស់សង្គម ព្រមទាំងអាចបញ្ជាបាននូវរាល់អំពើរបស់ខ្លួនថែមទៀតផង។ ថ្វីត្បិតតែច្បាប់បានតម្រូវឲ្យអនីតិជនមានការទទួលខុសត្រូវទៅលើអំពើដែលខ្លួនបានប្រព្រឹត្តឡើងក៏ពិតមែន ប៉ុន្តែការទទួលខុសត្រូវនេះមិនមានលក្ខណៈពេញលេញដូចនីតិជនឡើយ ពោលគឺស្ថានភាពដែលជននេះត្រូវទទួលរងគឺ មានកម្រិតស្រាលជាងនីតិជន។ ហើយដើម្បីអាចសម្រេចផ្តន្ទាទោសលើអនីតិជនបាន តុលាការត្រូវពិចារណាថ្លឹងថ្លែងជាមុនពាក់ព័ន្ធទៅនឹងកាលៈទេសៈនៃបទល្មើសដែលអនីតិជនបានប្រព្រឹត្ត និង រួមទាំងបុគ្គលិកលក្ខណៈរបស់គាត់ផងដែរ[36]។ ចំពោះទោសដែលត្រូវទទួលរងវិញ គឺអាចមានទាំងទោសដកហូតសេរីភាព និងទោសពិន័យជាប្រាក់។ សូមបញ្ជាក់ថា បើទោះបីជាអនីតិជនអាចទទួលរងនូវទោសបែបនេះក៏ដោយ ក៏កម្រិតនៃទោសដែលទទួលរង គឺត្រូវបន្ថយមកត្រឹមពាក់កណ្តាល បើប្រៀបធៀបទៅនឹងទោសដែលមានចែងចំពោះនីតិជន។

#### ការអនុវត្តទោសចំពោះអនីតិជន

អនុលោមតាមមាត្រា ៣៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានប្បញ្ញត្តិថា នគរបាលយុត្តិធម៌អាចចាប់ខ្លួនអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន)ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី )ឆ្នាំ តែក្នុងករណីដែលអនីតិជនប្រព្រឹត្តបទមជ្ឈិម ឬបទឧក្រិដ្ឋជាក់ស្តែងតែប៉ុណ្ណោះ។ ប៉ុន្តែអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន)ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ)ឆ្នាំ ការចាប់ខ្លួនអាចធ្វើទៅបានតែក្នុងករណីដែលអនីតិជននោះប្រព្រឹត្តបទមជ្ឈិមដោយចេតនា។ រាល់ការចាប់ខ្លួនអនីតិជនត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាម។ ការអនុវត្តការចាប់ខ្លួនរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវគោរពតាមនីតិវិធីដូចខាងក្រោម ៖

[36] មាត្រា ៤០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ក្នុងការចាប់ខ្លួនអនីតិជនត្រូវជៀសវាងក្នុងការធ្វើឲ្យអាម៉ាស់មុខ និងបាត់បង់សេចក្តីថ្លៃថ្នូររបស់អនីតិជន និងត្រូវបញ្ជូនអនីតិជនទៅឲ្យផ្នែក ឬអង្គភាពដែលមាននគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជនដែលនៅជិតបំផុត។ ព្រមទាំងមិនប្រើប្រាស់ខ្នោះដៃ អាវុធ កាំភ្លើង ឬឧបករណ៍ប្រហាក់ប្រហែលសម្រាប់បង្ខំ ឬរារាំងឡើយ លើកលែងតែបានប្រើប្រាស់អស់គ្រប់មធ្យោបាយសម្រាប់ត្រួតត្រាផ្សេងៗទៀតរួចហើយ ឬប្រើគ្រប់មធ្យោបាយផ្សេងៗទៀតពុំសមស្របនិងកាលៈទេសៈ ឬដើម្បីរារាំងសកម្មភាពដែលអនីតិជននោះអាចបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរលើខ្លួនឯង ឬលើបុគ្គលដទៃទៀត។ ក្នុងករណីមានការរារាំង ឬប្រើប្រាស់កម្លាំងមន្ត្រីនគរយុត្តិធម៌ត្រូវចុះក្នុងកំណត់ហេតុ ហើយបញ្ជាក់ពីមូលហេតុ និងកាលៈទេសៈដែលត្រូវប្រើប្រាស់កម្លាំង។ បន្ទាប់មកត្រូវបញ្ជូនអនីតិជនទៅឲ្យផ្នែកឬអង្គភាពនគរបាលយុត្តិធម៌ជំនាញទាក់ទងនិងអនីតិជនដែលនៅជិតបំផុត។

ដោយយោងតាមមាត្រា ១៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦ បានចែងបន្ថែមថាមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរលើខ្លួនបុគ្គលដែលជាអនីតិជនបាន។ ការឆែរឆេរលើខ្លួនបុគ្គលត្រូវធ្វើឡើងដោយបុគ្គលដែលភេទដូចគ្នា និងមិនត្រូវជាប់ពាក់ព័ន្ធនឹងបទល្មើសពុំមានទំនាស់ឬជាប់សាច់ញាតិ ឬមានទំនាក់ទំនងជិតស្និទ្ធជាមួយអនីតិជននោះឡើយលើកលែងតែក្នុងករណីមិនអាចជៀសវាងបាន។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុ និងចុះនិទ្ទេសអំពីបញ្ហានេះ។

អនុសញ្ញាស្តីពីសិទ្ធិកុមារ និងវិធានរបស់អង្គការសហប្រជាជាតិសម្រាប់ការការពារអនីតិជនដែលត្រូវបានដកហូតសេរីភាពរបស់ខ្លួន ចែងអំពីក្រមដែលមានលក្ខណៈពេញលេញនៃសិទ្ធិកុមារដែលត្រូវបានដកហូតសេរីភាពរបស់ខ្លួន។ បទដ្ឋានជាមូលដ្ឋានទាំងនេះគួរបានបញ្ចូលទៅក្នុងក្រមព្រហ្មទណ្ឌរបស់ច្បាប់ជាតិ។ ហេតុនេះហើយត្រូវចែងឲ្យបានច្បាស់លាស់អំពីគោលបំណង ឬវត្ថុបំណងនៃការឃុំដែលផ្តោតលើការស្តារនីតិសម្បទាមិនមែនជាការដាក់ទណ្ឌកម្មទេ។ បើយោងតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលបានផ្តល់ឲ្យនូវអនីតិជនដែលបានផ្តន្ទាទោស ត្រូវស្ថិតនៅជាលក្ខណៈជាជនដែលត្រូវទទួលនូវគោលការណ៍ស្តារនីតិសម្បទាតែប៉ុណ្ណោះ។ កត្តានេះហើយធ្វើឲ្យមានការសម្រេចសេចក្តីថា តុលាការគ្រប់លំដាប់ថ្នាក់អាចសម្រេចប្រគល់ទណ្ឌិតជាអនីតិជន ដែលត្រូវបានផ្តន្ទាទោសទៅមណ្ឌលយុវនីតិសម្បទារាជធានី-ខេត្តណាមួយ ដែលសមស្របប្រសិនបើមានសំណូមពរពីទណ្ឌិតជាអនីតិជន។ ប្រសិនបើទណ្ឌិតជាអនីតិជនឈានចូលអាយុ ១៨ (ដប់ប្រាំបី)ឆ្នាំ ក្នុងពេលបាននិងកំពុងអនុវត្តទោសនៅក្នុងមណ្ឌលយុវនីតិសម្បទា ទណ្ឌិតនោះត្រូវបានរក្សាទុកនៅក្នុងមណ្ឌលយុវនីតិសម្បទារហូតដល់អាយុក្រោម ២៤ (ម្ភៃបួន)ឆ្នាំ។ នៅពេលទណ្ឌិតឈានចូលអាយុ ២៤ (ម្ភៃបួន)ឆ្នាំ ទណ្ឌិតនោះត្រូវផ្ទេរអនុវត្តទោសបន្តនៅមណ្ឌលឃុំខ្លួនសម្រាប់អនីតិជន។ បែបបទនិងនីតិវិធីនៃការផ្ទេរ ការប្រគល់ និងការទទួលទណ្ឌិត ត្រូវកំណត់ដោយប្រកាសអន្តរជាតិក្រសួងរវាងមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**ទោសដែលអាចអនុវត្តបានចំពោះអនីតិជន**

មានទ្រឹស្តីជាច្រើន ដែលកំណត់អំពីប្រភេទនៃទោសខុសៗគ្នានៅលើសាកលលោកយើងនេះ។ ហើយទោសព្រហ្មទណ្ឌនេះទៀតសោតន៍ គឺមានការបែងចែកជាច្រើនប្រភេទទៅតាមប្រទេសនីមួយៗដែលប្រកាន់យកប្រព័ន្ធច្បាប់ ឬគោលការណ៍ផ្សេងៗគ្នា។ គេសង្កេតឃើញថាទោសនេះ គឺមានភាពប្រែប្រួលទៅតាមបុគ្គលដែលបានប្រព្រឹត្តបទល្មើសផងដែរ។ ការប្រែប្រួលនេះនាំឲ្យគេយល់ឃើញថា អាចបណ្តាលមកពីមូលហេតុនៃវិបត្តិរបស់ជនល្មើសនៅក្នុងសង្គមនៃឧក្រិដ្ឋកម្មនេះឯង។ ដោយឡែកផ្អែកទៅតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់យកនិងធ្វើការបែងចែកប្រភេទនៃទោសនេះជា បី ប្រភេទគឺ ៖

**មូលទោស** គឺជាទោសមូលដ្ឋានដែលយកទៅប្រើប្រាស់សម្រាប់ការប្រកាសទោសចំពោះជនជាប់ចោទដែលបានប្រព្រឹត្តបទល្មើស។ មូលទោស ត្រូវបានកំណត់ដោយក្រមព្រហ្មទណ្ឌ រួមមាន ទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។ ក្នុងករណីនេះដែរប្រសិនបើអនីតិជនម្នាក់ដែលមានអាយុចាប់ពី ១៤ ឆ្នាំដល់ក្រោម ១៨ ឆ្នាំ ហើយបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ ចៅក្រមបានពិន័យ និងពិចារណាទៅលើកាលៈទេសៈនៃបទល្មើស និងបុគ្គលិកលក្ខណៈរបស់អនីតិជននោះឃើញថា មានលក្ខណៈតម្រូវគ្រប់គ្រាន់ហើយដូចនេះច្បាប់បានផ្តល់នូវឆន្ទានុសិទ្ធ ដល់ចៅក្រម អាចប្រកាសអំពីទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជននោះបាន។ប្រសិនបើចៅក្រមសម្រេចផ្តន្ទាទោសអនីតិជន ពោលគឺត្រូវលើកយកមូលទោសដែលមានចែងក្នុងបញ្ញត្តិនៃមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌមកអនុវត្ត។

គួរកត់ចំណាំថា ក្នុងករណីដែលចៅក្រមសម្រេចយ៉ាងដូច្នេះ គឺជាជម្រើសចុងក្រោយបំផុតហើយដោយហេតុថា ស្ថានភាពនៃការប្រព្រឹត្តបទល្មើសរបស់អនីតិជននោះ ច្បាស់ណាស់ថាប្រាកដជាមានលក្ខណៈសាហាវព្រៃផ្សៃខ្លាំងណាស់ហើយ ឬ ក៏អាចជាហេតុនាំឲ្យមានការប៉ះពាល់ដល់សង្គម ទើបធ្វើការសម្រេចយ៉ាងដូច្នេះ។ ឧទាហរណ៍ ៖ អនីតិជនម្នាក់បានប្រព្រឹត្តនូវបទឧក្រិដ្ឋមួយដែលមានលក្ខណៈប៉ះពាល់យ៉ាងខ្លាំងដល់សណ្តាប់ធ្នាប់សង្គម ពោលគឺគាត់បានជិះម៉ូតូឆក់កាបូបរបស់ជនរងគ្រោះតាមផ្លូវបណ្តាលឲ្យជនរងគ្រោះដួលបោកក្បាលស្លាប់ភ្លាមៗនៅហ្នឹងកន្លែង។ ករណីបែបនេះ គឺប្រហែលជាមិនប្រើប្រាស់នូវវិធានការផ្សេងក្រៅពីទោសលើរូបគាត់ឡើយ ហេតុនេះជម្រើសដែលគួរសមជាងគេបំផុតគឺ ច្បាស់ជាត្រូវផ្តន្ទាទោសព្រហ្មទណ្ឌលើរូបគាត់ហើយ ទើបអាចរក្សានូវសណ្តាប់ធ្នាប់សង្គម និងធ្វើឲ្យមានរបៀបរៀបរយឡើងវិញ។ ដូចនេះមូលទោសដែលត្រូវអនុវត្តចំពោះអនីតិជន គឺច្បាប់បានកំណត់ក្នុងមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌបានចែងអំពី មូលទោសដែលអនុវត្តចំពោះអនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ឡើងទៅ។ កាលណាតុលាការសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ ឆ្នាំឡើងទៅ មូលទោសលើបទល្មើសដែលត្រូវចោទប្រកាន់ ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចតទៅ ៖

១. អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបានបន្ថយពាក់កណ្ដាល។

ឧទាហរណ៍ ៖ ប្រសិនបើអនុវត្តចំពោះមនុស្សពេញវ័យ ទោសដែលត្រូវទទួលរងគឺ ២០ (ម្ភៃ) ឆ្នាំ ប៉ុន្តែចំពោះអនីតិជនត្រូវទទួលរងជាអតិបរមាត្រឹមតែ ១០ (ដប់) ឆ្នាំប៉ុណ្ណោះ។

២.ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិតអតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ ។

៣. អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្ដាលប្រសិនបើអប្បបរមានេះលើសពី ១ (មួយ) ថ្ងៃ។

ឧទាហរណ៍ ៖ ក្នុងករណីដែលទោសជាប់ពន្ធនាគារត្រូវទទួលរងគឺ ៤ (បួន) ថ្ងៃអប្បបរមាចំពោះបទលហុ អនីតិជនដែលត្រូវរងគឺ ២ (ពីរ) ថ្ងៃអប្បបរមា ។

៤. អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ត្រូវបន្ថយពាក់កណ្ដាល។

ឧទាហរណ៍ ៖ ប្រសិនបើទោសពិន័យដែលត្រូវទទួលរងគឺនៅចន្លោះពី២០០០ ០០០លានរៀលនិង៦០០០ ០០០ លានរៀល ចំពោះអនីតិជនត្រូវទទួលរងត្រឹមតែពីន័យចន្លោះពី ១០០០ ០០០ លានរៀល និង ៣០០០ ០០០ លានរៀល។

ក្នុងករណីដែលចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបញ្ញត្តិនៃមាត្រានេះមានអានុភាពបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមចិរវេលាមួយស្មើ ឬតិចជាង ៥ (ប្រាំ) ឆ្នាំ នោះបទល្មើសដែលត្រូវចោទប្រកាន់នោះគឺនៅតែជាបទឧក្រិដ្ឋដដែល។ សូមបញ្ជាក់ថានេះគ្រាន់តែជាការរំលឹកនូវវិធានដែលចែងថា ប្រភេទនៃបទល្មើសពុំកែប្រែដោយការបន្ថយស្របច្បាប់នូវទោសដាក់ពន្ធនាគារ ដែលអនុវត្តចំពោះអនីតិជនឡើយ។ បើយើងពិនិត្យមើលទៅលើមាត្រា ៥៦ នៃក្រមព្រហ្មទណ្ឌ ត្រង់ចំណុចទី២ បានចង្អុលបង្ហាញយ៉ាងច្បាស់ថា ចំពោះបទឧក្រិដ្ឋទោសដាក់ពន្ធនាគារដែលត្រូវទទួលរងគឺ មានរយៈពេលលើសពី៥ (ប្រាំ) ឆ្នាំ។ ដូច្នេះដោយហេតុថាមានការបន្ថយស្របច្បាប់ដែលបានចែងជាប្រយោជន៍ដល់អនីតិជន ប្រសិនបើទោសដែលទទួលរងដោយអនីតិជនចំពោះបទឧក្រិដ្ឋបែរតិចជាង ៥ (ប្រាំ) ឆ្នាំទៅវិញនោះពុំត្រូវបានផ្លាស់ប្ដូរប្រភេទគតិយុត្តដើមជា បទឧក្រិដ្ឋនៃបទល្មើសឡើយ។ គប្បីពិចារណាផងដែរថា ទោះបីជាអនីតិជនដែលមានអាយុលើសពី ១៤ (ដប់បួន) ឆ្នាំហើយក៏ដោយ ក៏តុលាការគួរតែអនុគ្រោះដល់ការប្រកាសនូវវិធានការ ឧបត្ថម្ភ អប់រំ និងការពារ ជាអាទិ៍ ដើម្បីបានជាប្រយោជន៍ជូនទៅអនីតិជននោះផងដែរ។ ជាជាងការដាក់ទណ្ឌកម្មបង្ក្រាប ដើម្បីជៀសវាងនូវការដាក់ពន្ធនាគារដែរជា ញឹកញាប់ក្លាយទៅជាប្រភពនៃគ្រោះថ្នាក់កាន់តែកើនឡើងចំពោះអនីតិជនដែលជាប់ជាមួយអ្នកឃុំឃាំងផ្សេងៗទៀត ដែលជួនកាលមានសភាពគ្រោះថ្នាក់ជាងនេះទៅទៀតផងក៏អាចថាបាន។ ក្រៅពីទោសដែលជាមូលដ្ឋានតុលាការក៏អាចធ្វើការសម្រេចពិចារណាអំពីទោសបន្ថែមដែលអាចប្រកាស ចំពោះទណ្ឌិតជាអនីតិជននោះបានថែមទៀតផងដែរ។

**ទោសបន្ថែម** គឺសំដៅដល់ប្រភេទនៃទោសមួយ ដែលបន្ថែមទៅលើមូលទោស។ មានន័យថាជាទូទៅនៅពេលដែលចៅក្រមប្រកាសអំពីមូលទោស ហើយក្នុងករណីដែលក្ខខណ្ឌច្បាប់ចែងកំណត់ថាអនុញ្ញាតឲ្យមានការផ្តន្ទាទោសបន្ថែមទៀតនោះ ចៅក្រមអាចសម្រេចទោសបន្ថែមនេះដើម្បីបន្ថែមទៅលើមូលទោសនោះទៀតបាន។ បើពិនិត្យទៅមើលបច្ចេកទេសនៅក្នុងការអនុវត្តទោសបន្ថែមចំពោះទណ្ឌិតជាអនីតិជននេះ គឺមិនមានលក្ខណៈអ្វីខុសប្លែកពីការអនុវត្តទោសបន្ថែមចំពោះអនីតិជនឡើយ។ ប៉ុន្តែអ្វីដែលខុសគ្នានោះគឺនៅត្រង់ថាទោសបន្ថែមដែលអាចអនុវត្តចំពោះអនីតិជនគឺមានត្រឹមតែចំនួន ៥ ចំណុច ប៉ុណ្ណោះ ខុសពីទោសបន្ថែមដែលអនុវត្តចំពោះនីតិជន គឺមានរហូតទៅដល់ ១៩ ចំណុចឯណោះ។ យោងតាមក្រមព្រហ្មទណ្ឌត្រង់បញ្ញត្តិនៃមាត្រា ១៦១ បានចែងអំពីទោសដែលអាចលើកយកមកអនុវត្តចំពោះអនីតិជនបានមានដូចតទៅ ៖

- ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើក្នុងការប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស។
- ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។
- ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។
- ការរឹបអូសឧបករណ៍ភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត។
- ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។

ដូច្នេះមានតែទោសបន្ថែមត្រឹមតែ ៥ ដូចដែលបានរៀបរាប់ខាងលើនេះ តែប៉ុណ្ណោះដែលអាចអនុវត្តចំពោះអនីតិជនបាន ។ ហើយក្នុងចំណោមទោសបន្ថែមទាំងនេះមានទោសបន្ថែមទី ៤ គឺជាវិធានការរឹបអូសនូវទ្រព្យសម្បត្តិ ដែលមានទំនាក់ទំនងជាមួយនឹងបទល្មើស ចំណែកឯទោសបន្ថែមទី ៥ វិញគឺគ្រាន់តែជាការហាមឃាត់មិនឲ្យធ្វើការកាន់កាប់ ឬប្រដាប់អាវុធតែប៉ុណ្ណោះ។

សូមបញ្ជាក់ថាទោសបន្ថែមទាំងនេះ គឺគ្រាន់តែជាវិធានការប្រាតិភោគតែប៉ុណ្ណោះ ហើយមាននូវវត្ថុបំណងផ្តល់បុព្វសិទ្ធដល់ទិដ្ឋភាពអប់រំ ជាជាងទិដ្ឋភាពបង្ក្រាប។ ដោយផ្អែកទៅលើគោលការណ៍មនុស្សធម៌ ក៏ដូចជាអនីតិភាពនៃជនល្មើស ចៅក្រមអាចពិនិត្យពិចារណាទៅលើស្ថានភាព និងកាលៈទេសៈនៃការប្រព្រឹត្តបទល្មើស ដើម្បីជៀសវាងការអនុវត្តទោសដែលជាមូលដ្ឋានដោយយកទោសការងារសហគមន៍មកអនុវត្តចំពោះអនីតិជនវិញ។

**ការងារសហគមន៍** គឺជាកាតព្វកិច្ចត្រូវបំពេញក្នុងចិរវេលាចន្លោះពី ៣០ (សាមសិប) ម៉ោង ទៅ២០០ (ពីររយ) ម៉ោង នូវការងារគ្មានកម្រៃជាប្រយោសជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គលនៃនីតិសាធារណៈផ្សេងៗទៀតដល់សមាគមន៍ ឬដល់អង្គការមិនមែនរដ្ឋាភិបាល។ ដោយឡែកទោសការងារសមាគមន៍ដែលអនុវត្តចំពោះអនីតិជននេះ គឺមានលក្ខណៈខុសប្លែកគ្នាពីទោសការងារសហគមន៍ដែលអនុវត្តចំពោះនីតិជន

ដូចដែលបានលើកឡើងខាងលើនេះ។ ព្រោះអាស្រ័យដោយហេតុថា យោងតាមបញ្ញត្តិនៃក្រមព្រហ្មទណ្ឌត្រង់មាត្រា ១៦២ លក្ខខណ្ឌដែលអាចលើកយកទោសការងារសមាគមន៍មកអនុវត្តចំពោះអនីតិជនបានមានដូចតទៅ ៖

ទី១ **លក្ខខណ្ឌអាយុ** លុះត្រាតែអនីតិជននោះមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំដល់ ១៨ (ដប់ប្រាំបី) ឆ្នាំ ទើបអាចលើកយកមកអនុវត្តបាន ( អនុសញ្ញាអន្តរជាតិ ស្តីពីនីតិភាពការងារ ) ។

**ទី២ ចិរវេលាដែលត្រូវអនុវត្ត** ចំពោះចិរវេលាដែលអាចត្រូវអនុវត្ត គឺមិនឲ្យលើសពី ១០០ (មួយរយ) ម៉ោងនោះទេ មានន័យថាចិរវេលានៃទោសការងារសមាគមន៍ចំពោះអនីតិជននេះ គឺច្បាប់បានកំណត់ត្រឹមតែពាក់កណ្តាលនៃចិរវេលាដែលត្រូវអនុវត្តចំពោះនីតិជនតែប៉ុណ្ណោះ។ ដូច្នេះចិរវេលានេះត្រូវកម្រិតមកត្រឹមអប្បបរមាចំនួនមួយរយម៉ោងដែលតិចជាងបីសប្តាហ៍នៃការមិនទទួលកម្រៃ។

ទី៣ **ត្រូវតែសម្របសម្រួលទៅលើអនីតិជន** ពោលគឺសំដៅទៅលើស្ថានភាពដែលទាក់ទង នឹងការជ្រើសរើសការងារមួយដ៏សមស្របសម្រាប់អនីតិជន ដែលមានលក្ខណៈជាការបណ្តុះបណ្តាល ការកែប្រែ ការអប់រំ និងសម្រួលដល់ការបញ្ជូនខ្លួនអនីតិជនឲ្យចូលទៅរួមរស់នៅក្នុងសង្គមវិញ។ ហេតុដូច្នេះហើយ លក្ខខណ្ឌដែលទាក់ទងទៅនឹងទោសការងារសមាគមន៍ចំពោះអនីតិជននេះ គឺត្រូវមានការគិតគូរពិចារណាជាពិសេសទៅដល់កន្លែងធ្វើការដែលមានលក្ខណៈជាការបណ្តុះបណ្តាលដើម្បីឲ្យអនីតិជននោះអាចបានរៀនសូត្រ អប់រំ និងធ្វើការកែប្រែខ្លួនដើម្បីអាចចូលមករស់នៅក្នុងសង្គមដូចដើមវិញ ឬក៏ធ្វើសមាហរណកម្មខ្លួនមកក្នុងសង្គមវិញ។

ចំណុចគួរកត់សម្គាល់ ៖ បើពិនិត្យមើលទៅលើច្បាប់ស្តីពីការងារឆ្នាំ ១៩៩៧ ត្រង់បញ្ញត្តិនៃមាត្រា ១៧៧ បានចែងអំពី ការងារសម្រាប់ក្មេងបានកំណត់ត្រឹមតែអាយុ ១៥ (ដប់ប្រាំ) ឆ្នាំប៉ុណ្ណោះ អាចធ្វើការងារជាកម្មករនិយោជិកបានហើយ។ ដោយហេតុថាការងារនេះគឺជាការងារមួយដែលអនីតិជនធ្វើហើយអាចផ្តល់នូវផលកម្រៃតបស្នងចំពោះអនីតិជននោះវិញ ហើយកម្រៃដែលទទួលបាននេះអាចយកទៅចិញ្ចឹមគ្រួសារ និងអនីតិជនខ្លួនឯងផងដែរ។ តែដោយឡែកផ្សាភ្ជាប់ជាមួយការងារសមាគមន៍ដែលយើងកំពុងតែសិក្សានេះ គឺគ្មានកម្រៃសម្រាប់ផ្តល់ឲ្យអនីតិជននោះទេ ដូច្នេះការដែលច្បាប់បានកំណត់ត្រឹមអាយុ ១៦ (ដប់ប្រាំមួយ) ឆ្នាំនេះ គឺជាការល្អប្រសើរបំផុតណាស់ទៅហើយ។ [37]ចៅក្រមស៊ើបសួរអាចបង្គាប់ទៅនិយោជក មិនឲ្យព្យួរ ឬព្យួរការងាររបស់អនីតិជនប្រសិនបើអនីតិជនមិនត្រូវបានឃុំខ្លួនបណ្តោះអាសន្នទេ។ ក្នុងករណីអនីតិជនត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ឬត្រូវអនុវត្តផែនការបង្វែរនិយោជកអាចព្យួរការងាររហូតដល់មានសេចក្តីសម្រេចរបស់តុលាការជាស្ថាពរ។ ក្នុង

[37] ច្បាប់ស្តីពីយុត្តធម៌អនីតិជន ឆ្នាំ២០១៦,មាត្រា ៣៧

ករណីតុលាការសម្រេចសេចក្តីថាគ្មានទោសវិញទេ នោះនិយោជនត្រូវអនុញ្ញាតឲ្យអនីតិជនចូលធ្វើការជាធម្មតាឡើងវិញ។

## ៣.៣.ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ និងស្ថានសម្រាលទោសចំពោះអនីតិជន

អនីតិជនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបាន លុះត្រាតែនៅពេលទង្វើរបស់អនីតិជននោះបានលើកលែងដោយច្បាប់ បើមិនដូច្នេះទេអនីតិជននោះនៅតែទទួលខុសត្រូវចំពោះអំពើនោះដដែល។ មានន័យថាអនីតិជននោះអាចនឹងត្រូវជាប់ពន្ធនាគារ ឬច្បាប់នឹងចាត់វិធានការផ្សេងៗដើម្បីអនុវត្តចំពោះបុគ្គលនោះ។ មូលហេតុ ដែលនាំឲ្យអនីតិជនរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌរួមមាន អាយុរបស់ជនល្មើសជាដើម។

### ៣.៣.១.ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ

អនីតិជន គឺជាជនដែលមិនទាន់គ្រប់អាយុទៅតាមច្បាប់កំណត់ ឬជនដែលមានអាយុក្រោម១៨ ឆ្នាំ[38] ឬជាជនដែលច្បាប់មិនទាន់ឲ្យទទួលខុសត្រូវលើអំពើរបស់ខ្លួនបានប្រព្រឹត្ត ឬជនដែលច្បាប់កំណត់ឲ្យទទួលខុសត្រូវលើអំពើរបស់ខ្លួនដោយមានកម្រិត[39]។ ជាគោលការណ៍អនីតិជនដែលមានអាយុក្រោម១៤ ឆ្នាំ មិនទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ ដោយហេតុថាជនទាំងនោះមិនទាន់យល់ដឹងខុសត្រូវពីភាពធ្ងន់ធ្ងរនៃអំពើរបស់ខ្លួននោះទេ[40]។ ម្យ៉ាងទៀត គេគិតថាអនីតិជនក្រោម ១៤ ឆ្នាំ មិនមានសមត្ថភាពក្នុងការប្រព្រឹត្តបទល្មើសនោះទេ ហើយតាមផ្លូវច្បាប់មិនត្រូវបានចោទប្រកាន់លើអនីតិជនល្មើសពីបទមជ្ឈឹម ឬបទឧក្រិដ្ឋណាឡើយ[41]។ ដូច្នេះហើយ តុលាការអាចប្រកាសទោសព្រហ្មទណ្ឌលើអនីតិជនបាន លុះត្រាតែអនីតិជននោះមានអាយុ ១៤ ឆ្នាំឡើងទៅ ដោយគិតចាប់ពីថ្ងៃប្រព្រឹត្តបទល្មើស[42]។ ថ្វីត្បិតតែអនីតិជនមិនទទួលខុសត្រូវព្រហ្មទណ្ឌក៏ពិតមែន ប៉ុន្តែពុំមែនមានន័យថា ច្បាប់មិនអើពើ ឬមិនយកចិត្តទុកដាក់ និងពុំមានវិធានការអ្វីមួយអនុវត្តចំពោះអនីតិជនឡើយ។ ជាក់ស្តែង ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានចែងពីវិធានការផ្សេងៗ ដើម្បីអាចយកមកអនុវត្តចំពោះអនីតិជនទាំងនោះ។ អនីតិជនដែលបានប្រព្រឹត្តបទល្មើសជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ដោយប្រភេទនៃវិធានការនេះ មានដូចខាងក្រោម៖

១. ការប្រគល់អនីតិជនឲ្យឪពុកម្តាយ អាណាព្យាបាល ឬបុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសាកសម។ បើទោះបីជាអនីតិជនស្ថិតនៅដំណាក់កាលនៃនីតិវិធីរបស់តុលាការក៏ដោយ បើអនីតិជនត្រូវបានរកឃើញថាមានអាយុក្រោម ១៨ ឆ្នាំ គិតចាប់ពីថ្ងៃសង្ស័យថាប្រព្រឹត្តបទល្មើស

[38] សន្ធានុក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧,លេខរាង ១៨៧

[39] សន្ធានុក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧.លេខរៀង ២៣០.

[40] នីតិព្រហ្មទណ្ឌទូទៅ ឆ្នាំ ២០១២,ទំព័រ ២៣១

[41] សេចក្តីព្រាងស្តីពី សៀវភៅមគ្គុទ្ទេសក៏សម្រាប់នគរបាលយុត្តធម៌ស្តីពីនីតិវិធីនគរបាលយុត្តធម៌បែបកុមារមេត្រីមេត្រី ឆ្នាំ២០១៧

[42] ច្បាប់ស្តីពីយុត្តធម៌អនីតិជន ឆ្នាំ២០០៦,មាត្រា ៨, កថាខណ្ឌទី១

អនីតិជនពុំអាចត្រូវបានគេឃាត់ខ្លួន[43] ឬត្រូវតម្កល់រឿងទុកឥតចាត់ការ[44] ឬមិនអាចឃុំខ្លួនបណ្ដោះអាសន្នបានឡើយ[45] ហើយត្រូវប្រគល់អនីតិជននោះឲ្យទៅអ្នកតំណាងដែលច្បាប់កំណត់វិញ។

២. ការប្រគល់អនីតិជនឲ្យសេវាសាធារណៈដែលទទួលបន្ទុកថែទាំអនីតិជន។

៣. ការប្រគល់អនីតិជនឲ្យទៅអង្គការឯកជនដែលមាននីតិសម្បទា[46]ក្នុងការទទួលអនីតិជន។

៤. ការប្រគល់អនីតិជនឲ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស[47]។ ក្នុងករណីអនីតិជនត្រូវការកិច្ចការពារ និងថែទាំ ត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរ ឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ច រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចាត់វិធានការសមស្របទៅនឹងសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន។ មន្ទីរ ឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ច រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍អំពីការទទួលអនីតិជន។ ក្រោយពីបានទទួលអនីតិជនហើយ ប្រសិនបើយល់ឃើញថាអនីតិជននោះត្រូវមានកិច្ចការពារ និងថែទាំនោះ មន្ទីរដែលបានទទួលអនីតិជនត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជននោះមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីអាចឲ្យតុលាការសម្រេចអំពីការព្យួរ ឬដកហូត ឬបញ្ឈប់អ្នលតំណាងដែលច្បាប់បានកំណត់ និងអាណាព្យាបាលលើអនីតិជន។ ក្នុងករណីអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ។

៥.ការដាក់អនីតិជនឲ្យស្ថិតក្រោមការការពាររបស់តុលាការ តុលាការត្រូវចាត់តាំងបុគ្គលមួយរូបឲ្យទទួលភារៈធ្វើការតាមដានអនីតិជន។ បុគ្គលនេះធ្វើរបាយការណ៍ស្ដីពីកិរិយាមាយាទរបស់អនីតិជនឲ្យបានទៀងទាត់ដល់ព្រះរាជអាជ្ញា។ បុគ្គលនេះផ្ដល់ព័ត៌មានជូនព្រះរាជអាជ្ញាអំពីព្រឹត្តការណ៍ទាំងអស់ដែលអាចនាំឲ្យមានកែប្រែនូវវិធានការនេះ។

តុលាការការ ជាស្ថាប័នដែលមានសមត្ថកិច្ចក្នុងការការចាត់ចែងវិធានការដែលបានរៀបរាប់ខាងលើ។ ប៉ុន្តែផ្ទុយទៅវិញប្រសិន បើតុលាការយល់ឃើញថាកាលៈទេសៈរបស់បទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវឲ្យអនីតិជនទទួលខុសត្រូវព្រហ្មទណ្ឌនោះ ក៏ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជនមិនអាចស្ថិតនៅលើគោលការណ៍ស្មើភាពដូចនីតិជនដែរ។

[43] ច្បាប់ស្ដីពីយុត្តធម៌អនីតិជន ឆ្នាំ២០១៦,មាត្រា ១៤,កថាខណ្ឌទី១

[44] ច្បាប់ស្ដីពីយុត្តធម៌អនីតិជន ឆ្នាំ២០១៦,មាត្រា ២៧,កថាខណ្ឌទី១

[45] ច្បាប់ស្ដីពីយុត្តធម៌អនីតិជន ឆ្នាំ២០១៦,មាត្រា ៣៩,កថាខណ្ឌទី៣

[46] សន្ធានុក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១១,លេខរៀង ៦០

[47] សន្ធានុក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១១,លេខរៀង ២២៧

## ៣.៣.២.ស្ថានសម្រាលទោសចំពោះអនីតិជន

ចំពោះករណីដែលតុលាការសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌ ចំពោះអនីតិជនអាយុចាប់ពី១៤ឆ្នាំឡើងទៅ មាត្រា១៦០ បានកំណត់ថា ទោសដែលត្រូវអនុវត្តចំពោះអនីតិជនគឺត្រូវបានផ្តោតទៅលើគោលការណ៍៤៖

•ទោសដែលខ្ពស់បំផុត ឬអតិបរិមានៃទោស ត្រូវបន្ថយមកត្រឹមពាក់កណ្តាល

•ប្រសិនបើមានការជាប់ពន្ធធនាគារអស់មួយជីវិតវិញ ត្រូវបន្ថយមកត្រឹម២០ឆ្នាំ

•ទោសដែលទាបបំផុត ឬអប្បបរិមានៃទោស មានរយៈពេលលើសពី១ថ្ងៃឡើងទៅ ត្រូវថយមកត្រឹមពាក់កណ្តាលវិញ

•សម្រាប់ទោសពិន័យជាប្រាក់ ក៏ត្រូវបន្ថយមកត្រឹមពាក់កណ្តាលដែរទោះបីជាស្ថិតនៅក្នុងអតិបរិមានៃទោស ឬអប្បបរិមានៃទោសក៏ដោយ។

ក្នុងការចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើ បទបញ្ញត្តិនៃ មាត្រានេះមានអានុភាពបន្ថយ អតិបរមា នៃទោសដាក់ពន្ធនាគារមកត្រឹមចិរវេលាមួយស្មើ ឬតិចជាង ៥ (ប្រាំ) ឆ្នាំនោះបទល្មើស ដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល។ ក្រៅពីមូលទោសតុលាការក៏អាចប្រកាសទោសបន្ថែម និងទោសការងារសហគមន៍បានផងដែរ ដែលចំណុចនេះមានបញ្ញត្តិនៅក្នុងមាត្រា ១៦១ និង១៦២ នៃក្រមព្រហ្មទណ្ឌ។

នៅក្នុងមាត្រា១៦៤ បានចែងថា ប្រសិនបើតុលាការសម្រេចឲ្យមានស្ថានសម្រាលទោស អប្បបរិមានៃទោសទៅលើអនីតិជនចំពោះបទឧក្រិដ្ឋព្រហ្មទណ្ឌក៏ដោយបទមជ្ឈឹមក៏ដោយ គឺត្រូវមានការបន្ថយទោសដូចតទៅ៖

- បើជាប់ពន្ធធនាគារស្មើ ឬលើស១០ឆ្នាំ ត្រូវបន្ថយមកត្រឹម១ឆ្នាំវិញ
- បើជាប់ពន្ធធនាគារស្មើ ឬលើស៥ឆ្នាំ តូចជាង១០ឆ្នាំ ត្រូវបន្ថយមក៦ខែវិញ
- បើជាប់ពន្ធធនាគារស្មើ ឬលើស២ឆ្នាំ តូចជាង ៥ឆ្នាំ ត្រូវបន្ថយមកត្រឹម៣ខែ
- បើជាប់ពន្ធធនាគារស្មើ ឬលើស៦ថ្ងៃ តូចជាង២ឆ្នាំ ត្រូវបន្ថយមកត្រឹម១ថ្ងៃវិញ
- ចំពោះប្រាក់ពិន័យត្រូវកាត់បន្ថយពាក់កណ្តាល

ចំពោះការឃុំឃាំងអនីតិជនវិញ គឺមានភាពខុសគ្នាពីការឃុំឃាំងនីតិជន។ក្នុងមាត្រា ១៦៦ បានបញ្ញត្តិថាបើអនីតិជនត្រូវជាប់ពន្ធធនាគារកន្លែងឃុំឃាំងត្រូវនៅដាច់ដោយឡែកពីនីតិជន។ អនីតិជនត្រូវស្ថិតនៅក្រោមរបបដោយឡែកជាឯកត្តបុគ្គលដែលជាទីកន្លែងអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ។ របបឃុំឃាំងត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ។

សរុបមកឲ្យតែមានការប្រព្រឹត្តបទល្មើស អ្វីមួយកើតឡើងពិតណាស់វាតែងបង្កឲ្យមានព្យសនកម្ម ឬក៏ហៅម្យ៉ាងទៀតថាជាការខូចខាតផ្សេងៗដែលជាមូលហេតុមួយតម្រូវឲ្យមានការទទួលខុសត្រូវចំពោះអំពើ និងផលដែលខ្លួនបានប្រព្រឹត្តិចំពោះបុគ្គលដែលយើងបានជះផលទៅឲ្យ។

ប៉ុន្តែជាបទបញ្ញត្តិដោយឡែកច្បាប់ក៏បានកំណត់នូវគោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌ មួយដាច់ដោយឡែកសម្រាប់ អនីតិជន ដែលប្រព្រឹត្តបទល្មើសផងដែរ ដើម្បីជាការការពារអនីតិជនដើម្បីកុំឲ្យប៉ះពាល់ទៅដល់សិទ្ធិ ក៏ដូចជាបង្កនូវការលំបាកដល់អនីតិជនដែលជាគោលការណ៍អនីតិជនត្រូវបានគាំពារយ៉ាងខ្លាំងដោយច្បាប់ជាពិសេសនោះគឺច្បាប់ស្តីពីយុត្តិធម៌អនីតិជន។

អនីតិជន មានអាយុក្រោម ១៤ ឆ្នាំ មិនអាចត្រូវទទួលរងនូវការផ្តន្ទាទោសណាមួយឡើយ ទោះបីជាអនីតិជន នោះបានប្រព្រឹត្តបទល្មើសប្រភេទណាក៏ដោយ[48] ក៏ប៉ុន្តែតុលាការអាចចាត់វិធានការណាមួយដូចមានចែងនៅមាត្រា ៤០ នៃក្រមព្រហ្មទណ្ឌបាន ។

ក្នុងករណីដែលអនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ បានប្រព្រឹត្តបទល្មើស ធ្ងន់ធ្ងរដូចជា បទល្មើសឃាតកម្ម ជួញដូរគ្រឿងញៀន រំលោភសេពសន្ថវៈ លួចមានស្ថានទម្ងន់ ជាដើម កាលៈទេសៈនៃការប្រព្រឹត្តបទល្មើស នេះអាចជាមូលហេតុឱ្យតុលាការប្រកាសទណ្ឌកម្មព្រហ្មទណ្ឌលើអនីតិជនបាន ។

ឧទាហរណ៍ ៖ អនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ដល់ ១៨ ឆ្នាំ បានលួចអាវមួយ តើកាលៈទេសៈនៃការប្រព្រឹត្ត បទល្មើសនេះតម្រូវឱ្យតុលាការប្រកាសទោសលើអនីតិជនបានដែរឬទេ ? ការដែលតុលាការត្រូវប្រកាស ដាក់ទណ្ឌកម្មលើអនីតិជនត្រូវបន្ថយក្នុងលក្ខខណ្ឌដូចមានចែងនៅមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ៖

- អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល។
- ប្រសិនអតិបរមានៃទោសដាក់ពន្ធនាគារ គឺជាទោសដាក់ពន្ធនាគារអស់១ជីវិតអតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ ឆ្នាំ។
- អប្បបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាលប្រសិនបើអប្បបរមានេះលើសពី ១ ថ្ងៃ។
- អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ត្រូវបន្ថយពាក់កណ្តាល ។

**ចំពោះវិធានបង្វែរ**

ការបង្វែរ ជាវិធានការដែលអាចប្រើប្រាស់ក្នុងករណីអនីតិជនបានសារភាពថា បានប្រព្រឹត្តបទល្មើស ហើយដែលអាចជឿជាក់បានថាបានប្រព្រឹត្តបទល្មើសមែន ចេញពីដំណាក់កាលនីមួយៗនៃនីតិវិធីតុលាការ[49]។ មានន័យថា ការបង្វែរនេះគឺជាវិធានការមួយដែលតម្រូវឲ្យអនីតិជនបំពេញជាកាតព្វកិច្ច ហើយមានរយៈពេល

[48] មាត្រា ២១២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[49] មាត្រា ៦០ ច្បាប់ស្តីពីយុត្តធម៌អនីតិជន ឆ្នាំ២០១៦

កំណត់ណាមួយជាក់លាក់។ អាជ្ញាធរទទួលបន្ទុកបង្វែររួមមានតំណាងអយ្យការ ចៅក្រមស៊ើបសួរ ចៅក្រមជំនុំជម្រះនៃសាលាដំបូង និងក្រុមប្រឹក្សានៃសាលាឧទ្ធរណ៍[50]។ ក្នុងករណីបង្វែរ អាជ្ញាធរទទួលបន្ទុកបង្វែរអាចសម្រេចជ្រើសរើសយកនូវវិធានការមួយ ឬច្រើនសម្រាប់អនីតិជនបំពេញជាកាតព្វកិច្ច។ គួរកត់សម្គាល់ផងដែរថា រាល់ផែនការបង្វែរដែលទាក់ទងនឹងការងារត្រូវអនុទ្បោមតាមច្បាប់ស្តីពីការងារ និងអនុសញ្ញាអន្តរជាតិស្តីពីការងារដែលព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់។ ការអនុវត្តផែនការបង្វែរ ភ្នាក់ងារសង្គមកិច្ច និងបុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរ ត្រូវធានារ៉ាប់រងអនុវត្តសេចក្តីសម្រេច និងផែនការបង្វែររបស់អាជ្ញាធរទទួលបន្ទុកបង្វែរ ក្នុងការគ្រប់គ្រង និងត្រួតពិនិត្យលើអនីតិជនដែលត្រូវអនុវត្តផែនការបង្វែរ[51]។ បុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរ ត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលជោគជ័យ ឬបរាជ័យ ឬឧបសគ្គដែលកើតមាន នៅក្នុងការអនុវត្តលើផែនការទៅលើភ្នាក់ងារសង្គមកិច្ច។ ភ្នាក់ងារសង្គមកិច្ច ត្រូវបញ្ជូនរបាយការណ៍រួមទាំងយោបល់របស់ខ្លួនទៅអាជ្ញាធរទទួលបន្ទុកបង្វែរហើយចម្លងជូនទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី-ខេត្ត។

[50] មាត្រា ៦១ ច្បាប់ស្តីពីយុត្តធម៌អនីតិជន ឆ្នាំ២០១៦

[51] មាត្រា ៦៩ ច្បាប់ស្តីពីយុត្តធម៌អនីតិជន ឆ្នាំ២០១៦

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាស្រាវជ្រាវ និងបកស្រាយលើប្រធានបទស្តីពីការទទួលខុសត្រូវរបស់អនីតិជនមួយរយៈកន្លងមកនេះឃើញថា ការទទួលខុសត្រូវរបស់អនីតិជន គឺជាផ្នែកមួយដ៏សំខាន់ផងដែរ។ អនីតិជន ជាជន ដែលមានអាយុក្រោម១៨ ឆ្នាំហើយស្ថិតក្រោមការគ្រប់គ្រងរបស់អាណាព្យាបាល (ឪពុកម្តាយ)។ អនីតិជនខុសពីនីតិជន ដោយហេតុថា នីតិជនជាជនដែលមានសមត្ថភាពគ្រប់គ្រងក្នុងការធ្វើសកម្មភាពនានា។ រីឯអនីតិជនចំពោះទំនាក់ទំនងក្នុងសង្គមវិញ អនីតិជនជាជនដែលមានលក្ខណៈទន់ខ្សោយទាំងកាយសម្បទា និង បញ្ញាស្មារតីដែលតម្រូវឲ្យច្បាប់ការពារពួកគាត់ក្នុងគោលបំណងកុំឲ្យខាតបង់ប្រយោជន៍ណាមួយដែលមិនសមស្រប។ ការទទួលខុសត្រូវរបស់អនីតិជនផ្នែករដ្ឋប្បវេណីក៏ត្រូវមានកម្រិតសមស្របតាមច្បាប់ដែលបានចែង។ អនីតិជនត្រូវទទួលខុសត្រូវលុះត្រាតែត្រូវទៅតាមអ្វីដែលបានច្បាប់កំណត់ដូចជាការកំណត់អាយុដែលត្រូវទទួលខុសត្រូវជាដើម។

ច្បាប់ដែលកំណត់ដើម្បីការពារអនីតិជន គឺជាមធ្យោបាយដ៏សំខាន់ក្នុងការបង្ការទុកជាមុនចំពោះការបង្កើតនូវកិច្ចសន្យាណាមួយដោយអនីតិជនដែលអាច នឹងធ្វើឲ្យអនីតិជននោះជាប់កាតព្វកិច្ច ឬជាប់បន្ទុកដោយពុំសមហេតុផល ការលើកលែង ឬបន្ថយនូវការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលដែលបង្កឡើងដោយអនីតិជននោះ។ ប៉ុន្តែក៏មិនអាចបណ្តោយឲ្យអនីតិជនធ្វើតាមតែចិត្តហើយយកច្បាប់មកការពារខ្លួននោះទេ។ នោះមិនសមហេតុផលឡើយ និងបង្កឲ្យប៉ះពាល់ដល់ប្រយោជន៍អ្នកដ៏ទៃផងដែរ។

ដោយឡែកបើអនីតិជនបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌវិញ តើអាចរួចផុតពីការទទួលខុសត្រូវដូចក្រមរដ្ឋប្បវេណីដែរ ឬទេ? អនីតិជននៅពេលប្រព្រឹត្តបទល្មើសមិនអាចជៀសផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌនោះឡើយ ពោលគឺអនីតិជននៅតែត្រូវទទួលខុសត្រូវលើទង្វើដែលគេបានធ្វើនៅចំពោះមុខច្បាប់ដូចទៅ នឹងនីតិជនផងដែរ។ ប៉ុន្តែដោយហេតុថា អនីតិជន គឺស្ថិតនៅក្នុងដំណាក់កាលកំពុងវិវឌ្ឍន៍ដែលពួកគេស្ថិតនៅក្នុងវ័យកំពុងលូតលាស់ផ្នែកគំនិត ប្រាជ្ញាស្មារតី និងការគិតពិចារណារបស់ពួកគេនៅមានភាពក្មេងខ្ចីនៅឡើយ។ កត្តាទាំងនោះហើយបានធ្វើឲ្យនីតិករចាំបាច់ធ្វើការពិចារណា ទៅលើចំណុចមួយចំនួនដើម្បីអាចកំណត់បានថាអនីតិជននោះមានលទ្ធភាពក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ឬនៅចំណុចទាំងនោះ រួមមានដូចជា កត្តាអាយុកាលៈទេសៈនៃបទល្មើស និងបុគ្គលិកលក្ខណៈរបស់អនីតិជន។ ចៅក្រម និងតំណាងអយ្យការ ត្រូវយកកត្តាទាំងអស់នេះមកពិចារណាឲ្យបានល្អិតល្អន់ និងម៉ត់ចត់បំផុតមុននឹងធ្វើការសន្និដ្ឋានថា អនីតិជនត្រូវទទួលខុសត្រូវ ឬមិនទទួលខុសត្រូវ ព្រោះថាប្រសិនបើគ្មានការពិចារណាឲ្យបានល្អិតល្អន់ទេនោះវានឹងអាចជះឥទ្ធិពលអាក្រក់ទៅលើអនាគតរបស់អនីតិជនដែលត្រូវទទួលខុសត្រូវជាខ្លាំង។

# អនុសាសន៍

យោងតាមការសិក្សាស្រាវជ្រាវបកស្រាយ និងការធ្វើសេចក្តីសន្និដ្ឋានលើប្រធានបទស្តីពី ការទទួលខុសត្រូវរបស់អនីតិជន ឃើញថាក្រមរដ្ឋប្បវេណី ក៏ដូចជាក្រមព្រហ្មទណ្ឌ បានផ្តល់នូវការការពារដ៏ល្អ សម្រាប់អនីតិជន ប៉ុន្តែទោះបីជាមានច្បាប់កំណត់ពីអាយុនៃការទទួលខុសត្រូវក៏ដោយ ក៏ការអនុវត្តនៅក្នុងសង្គមជាក់ស្តែងនៅមានចន្លោះខ្វះខាតជាច្រើនទាក់ទង និងការទទួលខុសត្រូវផងដែរ។ កង្វះខាតទាំងនេះមានដូចជា សង្គមបច្ចុប្បន្ននៅពេល អនីតិជនបង្កគ្រោះថ្នាក់ចរាចរណ៍ជាយថាហេតុ ពួកគេតែងតែប្រាប់ថាខ្លួននៅជាអនីតិជននៅឡើយ និងបង្កបញ្ហាដដែលៗធ្វើឲ្យប៉ះពាល់ដល់អ្នកដទៃដោយពួកគេដល់ថាគេនៅមិនទាន់គ្រប់អាយុទទួលខុសត្រូវមុខច្បាប់។ កង្វះខាតផ្សេងទៀត គឺបញ្ហាជីវភាពរបស់ប្រជាពលរដ្ឋខ្មែរដែលជាបញ្ហាសំខាន់មួយនាំឲ្យការយកចិត្តទុលដាក់ទៅលើអនីតិជនពុំបានគ្រប់គ្រាន់ពេញលេញ ដូចជាទាក់ទងនឹងការរស់នៅនាំឲ្យអនីតិជនប្រព្រឹត្តអំពើមិនល្អក្នុងសង្គម មិនដឹងថាខ្លួនត្រូវប្រឈមនិងការជាប់ទោស ឬការទទួលខុសត្រូវទោះបីពួកគេអាយុ១៨ឆ្នាំ ហើយក៏ដោយ។ កត្តាដែលសំខាន់មួយទៀតនោះ គឺការយល់ដឹងអំពីច្បាប់របស់ ប្រជាពលរដ្ឋក៏ដូចជាអនីតិជនខ្មែរ នៅមានកម្រិតទាប និងការផ្សព្វផ្សាយពាក់ព័ន្ធនឹងច្បាប់ ទៅដល់ប្រជាពលរដ្ឋក៏មិនទាន់ទូលំទូលាយនៅឡើយដែលនាំឲ្យការអនុវត្តច្បាប់នៅមានការលំបាក។

ការកំណត់ដូចបានរៀបរាប់ខាងលើនេះ គឺជាភាពចាំបាច់មួយដើម្បីស្វែងរកបញ្ហាក្នុងការដោះស្រាយ និងស្វែងរកច្រកចេញឲ្យទាន់ពេលវេលា និងឆាប់រហ័សដើម្បីស្តារនូវកង្វះខាតខាងលើ។ ហើយបញ្ហាទាំងនេះ គឺជាក្តីកង្វល់មួយរបស់សង្គម ដោយហេតុថានេះគឺជាបញ្ហាដែលទាក់ទង និងកុមារដែលជាអនាគត និងក្តីសង្ឃឹមរបស់សង្គមជាតិរបស់យើង។ ខាងក្រោមនេះ គឺជាអនុសាសន៍ដែលឆ្លើយតប និងបញ្ហាប្រឈមខាងលើដែលកំពុងនឹងជួបប្រទះក្នុងបច្ចុប្បន្នចំពោះកុមារដើម្បីធានាឲ្យមានការការពារៈ

១.សូមស្នើឲ្យមានការពង្រីកការចែករំលែកផ្នែកច្បាប់ ទៅប្រជាពលរដ្ឋទៅតាមតំបន់ឲ្យកាន់តែមានភាពទូលំទូលាយជាងមុនទាក់ទង និងអនីតិជន។

២.បង្កើតឲ្យមានតុលាការអនីតិជនដែលមានមន្ត្រីជំនាញធ្វើការលើរឿងក្តីអនីតិជន។

៣.សូមស្នើឲ្យកំណត់អាយុ១៥ ឆ្នាំ ត្រូវទទួលការខុសត្រូវ ព្រោះថាអនីតិជន១៤ ឆ្នាំ មិនទាន់មានសមត្ថភាពគ្រប់គ្រាន់នៅឡើយទេ។

៤.ស្នើឲ្យមានការរឹតបន្តឹងទៅលើការទទួលខុសត្រូវរបស់អនីតិជនបន្ថែមទៀត។

# ឯកសារយោង

# ឯកសារយោង


## ១. លិខិតគតិយុត្តជាតិ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣
- ច្បាប់ស្តីពីយុត្តធម៌អនីតិជនប្រកាសឲ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០៧១៦/០០៩ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦
- ក្រមព្រហ្មទណ្ឌនៃព្រះរាជណាចក្រកម្ពុជាប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៦/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
- ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៧
- ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦

## ២. លិខិតគតិយុត្តអន្តរជាតិ

- អនុសញ្ញាស្តីពីសិទ្ធិកុមារ ឆ្នាំ២០០៩
- ក្រមនីតិវិធីប្រទេសជប៉ុន បោះពុម្ពលើកទី៥ ឆ្នាំ២០១១ កម្ពុជា

## ៣. សៀវភៅមេរៀន

- ក្រមរដ្ឋប្បវេណី ភាគទី៣ ស្តីពីមូលដ្ឋាននៃនីតិកិច្ចសន្យា, ភ្នំពេញ កម្ពុជា, ខែមិនា, ឆ្នាំ២០១២
- សេចក្តីកំណត់ចំពោះមាត្រានៃក្រមរដ្ឋប្បវេណី ភាគ១ គន្លឹ២
- សាស្ត្រាចារ្យ ណូមូរ៉ា តូយ៉ូហ៊ីរ៉ូ សេចក្តីផ្តើមនីតិរដ្ឋប្បវេណី, កម្ពុជា, បោះពុម្ពលើកទី៥, ឆ្នាំ២០១១
- សាស្ត្រាចារ្យ អ៊ីកិដា ម៉ាសាអូ សៀវភៅណែនាំសិក្សាច្បាប់រដ្ឋប្បវេណីប្រទេសជប៉ុន
- អ៊ីវប៉ូលី មេរៀនសង្ខេបសម្រាប់សមាជិកគណៈមេធាវី គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០១០

## ៥. ឯកសារស្រាវជ្រាវ

- សំម ឫទ្ធីរដ្ឋា និងកែវ វុទ្ធី សិទ្ធិអនីតិជនតាមការកំណត់ក្នុងក្រមរដ្ឋប្បវេណី សារណាបញ្ចប់ការសិក្សាភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច, ឆ្នាំ២០១៩
- លីវលីម សុថាណា ប្រៀបធៀបសុពលភាពកិច្ចសន្យាលក់ទិញករណីប្រទេសកម្ពុជា-ជប៉ុន សារណាបញ្ចប់ការសិក្សាភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច, ឆ្នាំ២០១៤
- គា ភារ៉ា និងហេង វឌ្ឍនៈ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន សារណាបញ្ចប់ការសិក្សាភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច, ឆ្នាំ២០១៧
- ហូ ស៊ីឃ័រ និងឡឹកសុភារីកា អនីតិជនក្នុងរឿងក្តីព្រហ្មទណ្ឌ សារណាបញ្ចប់ការសិក្សាភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច, ឆ្នាំ២០១៧

## ៦. រចនាក្រម

- សន្ធានុក្រមផ្នែករដ្ឋប្បវេណី រៀបចំដោយគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និង បោះពុម្ពដោយទីស្ដីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០០៧
- វចនាក្រមច្បាប់តាមបទដ្ឋានគតិយុត្តខ្មែរ សមាគមស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ខ្មែរ បោះពុម្ពលើកទី២ ឆ្នាំ២០១៦

# ឧបសម្ព័ន្ធ

# ក្រមរដ្ឋប្បវេណី

# ព្រះរាជក្រម

នស/រកម/១២០៧/០៧០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# គន្ថីទី ១
# បទប្បញ្ញត្តិទូទៅ
## ជំពូកទោល
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-** ច្បាប់ទូទៅនៃនីតិឯកជន

ក្រមនេះ បញ្ញត្តអំពីគោលការណ៍ទូទៅដែលទាក់ទងទៅនឹងទំនាក់ទំនងគតិយុត្តផ្នែករដ្ឋប្បវេណី ។ បញ្ញត្តិនៃក្រមរដ្ឋប្បវេណីនេះ ត្រូវយកមកអនុវត្ត ចំពោះទំនាក់ទំនងទ្រព្យសម្បត្តិ និង ទំនាក់ទំនងញាតិ លើកលែងតែមានកំណត់ផ្សេង នៅក្នុងច្បាប់ពិសេស ។

**មាត្រា ២.-** គោលការណ៍ជាមូលដ្ឋាន

ក្រមនេះ កំណត់អំពីគោលការណ៍នៃការធានាសេចក្តីថ្លៃថ្នូររបស់បុគ្គល ភាពស្មើគ្នារបស់បុរស នារី និង សិទ្ធិលើទ្រព្យសម្បត្តិ ដែលត្រូវបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ ។

**មាត្រា ៣.-** គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន

ក្រមនេះ គោរពនូវសេរីភាពនៃឆន្ទៈរបស់បុគ្គល និង បញ្ញត្តអំពីទំនាក់ទំនងគតិយុត្តប្រកបដោយសមភាពរវាងបុគ្គលឯកជន ដោយរួមបញ្ចូលទាំងនីតិបុគ្គល ។ នីតិបុគ្គលសាធារណៈ ដែលនៅក្នុងទំនាក់ទំនងនៃការជួញដូរ ត្រូវចាត់ទុកថាជាបុគ្គលឯកជន ។

**មាត្រា ៤.-** ការហាមឃាត់មិនឱ្យប្រើប្រាស់សិទ្ធិដោយបំពាន

ទោះបីជាសិទ្ធិក៏ដោយ ក៏ពុំត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ដោយបំពានឡើយ ។ នៅក្នុងករណីដែលបានប្រើប្រាស់សិទ្ធិ ដោយបំពានហួសពីទំហំនៃការការពារ ដែលត្រូវបានបញ្ញត្តទុក មិនអាចទទួលស្គាល់អានុភាពនៃការប្រើសិទ្ធិនោះឡើយ ។

**មាត្រា ៥.-** គោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់

ការប្រើសិទ្ធិ និង ការអនុវត្តករណីយកិច្ច ត្រូវធ្វើឡើងដោយសុចរិត ផ្អែកតាមភាពស្មោះត្រង់ ។

# គន្ថីទី ២

# បុគ្គល

## ជំពូកទី ១

## រូបវន្តបុគ្គល

### ផ្នែកទី ១

### សមត្ថភាពទទួលសិទ្ធិ

**មាត្រា ៦.-** គោលការណ៍សមភាពនៃសមត្ថភាពទទួលសិទ្ធិ

រូបវន្តបុគ្គលគ្រប់រូប មានលក្ខណសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និង កាតព្វកិច្ច បាន ។

**មាត្រា ៧.-** ការកម្រិតក្នុងការទទួលសិទ្ធិចំពោះជនបរទេស

ជនជាតិបរទេស មិនអាចទទួលបាន ឬ កាន់កាប់នូវសិទ្ធិមួយចំនួនដែលត្រូវបាន កំណត់ឡើយ ក្នុងករណីដែលមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ជាតិ ឬ សន្ធិសញ្ញា ឬ អនុសញ្ញា អន្តរជាតិ ។

**មាត្រា ៨.-** ពេលចាប់ផ្តើម និង បញ្ចប់សមត្ថភាពទទួលសិទ្ធិ

រូបវន្តបុគ្គលម្នាក់ៗ មានសមត្ថភាពទទួលសិទ្ធិនៅពេលចាប់កំណើត ហើយបាត់ បង់អស់នូវសមត្ថភាពទទួលសិទ្ធិនេះ នៅពេលទទួលមរណភាព ។

**មាត្រា ៩.-** ទារកនៅក្នុងគភ៌

១-ទារកដែលនៅក្នុងគភ៌នាពេលមានអំពើអនីត្យានុកូល បើទារកនេះមានកំណើត នៅពេលក្រោយ អាចទាមទារនូវសំណងនៃការខូចខាតដែលបានកើតឡើងពេលដែលខ្លួន នៅក្នុងគភ៌ ដោយអំពើអនីត្យានុកូលនោះបាន ។

២-ទារកដែលនៅក្នុងគភ៌នាពេលដែលចាប់ផ្តើមសន្តតិកម្ម បើទារកនោះមាន

កំណើតនៅពេលក្រោយ អាចទទួលមត៌ក ដោយសន្តតិកម្មនោះបាន ។

៣-ទារកដែលនៅក្នុងគភ៌នាពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព បើទារកនោះមានកំណើតនៅពេលក្រោយ អាចទទួលនូវអានុភាពនៃបណ្ដាំនោះបាន ។

## ផ្នែកទី ២
## សិទ្ធិបុគ្គល

**មាត្រា ១០.-** អត្ថន័យនៃសិទ្ធិបុគ្គល

សិទ្ធិបុគ្គល សំដៅទៅលើសិទ្ធិដែលមានអត្ថន័យពាក់ព័ន្ធនឹងជីវិត រូបកាយ សុខភាព សេរីភាព នាម កិត្តិយស ភាពឯកជន ឬ សិទ្ធិផ្សេងទៀតដែលជាផលប្រយោជន៍ទាក់ទងនឹងលក្ខណបុគ្គល ។

**មាត្រា ១១.-** សិទ្ធិទាមទារឱ្យបញ្ឈប់

ប្រសិនបើមានការបារម្ភថា នឹងអាចមានការរំលោភសិទ្ធិបុគ្គលដោយខុសច្បាប់ ឬ មានការបារម្ភថា ការរំលោភសិទ្ធិបុគ្គលដែលបានកើតឡើងហើយនោះ នឹងអាចបន្ត ឬ នឹងអាចកើតឡើងទៀតដោយខុសច្បាប់ អ្នកដែលមានសិទ្ធិបុគ្គលអាចទាមទារឱ្យបញ្ឈប់នូវការរំលោភនោះបាន ។

**មាត្រា ១២.-** សិទ្ធិទាមទារឱ្យដកចេញនូវលទ្ធផលនៃសកម្មភាពរំលោភ

បើស្ថានភាពរំលោភសិទ្ធិបុគ្គលនៅតែមានជាបន្តបន្ទាប់ ដោយសារសំណល់នៃលទ្ធផលដែលកើតពីសកម្មភាពរំលោភនោះ អ្នកដែលបានទទួលរងនូវការរំលោភសិទ្ធិបុគ្គលដោយខុសច្បាប់នោះ អាចទាមទារឱ្យដកចេញនូវលទ្ធផលនៃសកម្មភាពរំលោភនោះបាន លុះត្រាតែលទ្ធផលនោះអាចដកចេញបាន ។

**មាត្រា ១៣.-** សិទ្ធិទាមទារសំណងការខូចខាត

បញ្ញត្តិនៃមាត្រា ១១ (សិទ្ធិទាមទារឱ្យបញ្ឈប់) និង មាត្រា ១២ (សិទ្ធិទាមទារឱ្យដកចេញនូវលទ្ធផលនៃសកម្មភាពរំលោភ) នៃក្រមនេះ មិនរារាំងការទាមទារសំណងការខូច

ខាត ដោយអ្នកដែលបានទទួលរងនូវការរំលោភផលប្រយោជន៍ទាក់ទងនឹងលក្ខណបុគ្គល នោះ ដោយយោងទៅតាមបញ្ញត្តិស្តីពីអំពើអនីត្យានុកូលបានឡើយ ។

## ផ្នែកទី ៣
## សមត្ថភាពខាងឆន្ទៈ

**មាត្រា ១៤.–** ការខ្វះសមត្ថភាពខាងឆន្ទៈ

សកម្មភាពដែលភាគីបានធ្វើនៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និងវិនិច្ឆ័យបាន អំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន អាចលុបចោលបាន ។

**មាត្រា ១៥.–** និយមន័យនៃសកម្មភាព

ពាក្យ “សកម្មភាព” ដែលត្រូវបានប្រើនៅក្នុងផ្នែកទី ៣ (សមត្ថភាពខាងឆន្ទៈ) ផ្នែកទី ៤ (សមត្ថភាពក្នុងការធ្វើសកម្មភាព) និង ផ្នែកទី ៦ (ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន និង ការប្រកាសអំពីការបាត់ខ្លួន) នៃជំពូកទី ១ នេះ សំដៅទៅលើកិច្ចសន្យា និង សកម្មភាពឯកតោភាគី ។

## ផ្នែកទី ៤
## សមត្ថភាពក្នុងការធ្វើសកម្មភាព

**មាត្រា ១៦.–** អត្ថន័យនៃជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព

ជនដែលត្រូវបានកម្រិតសមត្ថភាព សំដៅទៅលើអនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និង ជននៅក្រោមហិតូបត្ថម្ភ ។

## កថាភាគទី ១
## អនីតិជន

**មាត្រា ១៧.–** អត្ថន័យនៃអនីតិជន

អនីតិជន សំដៅទៅលើជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

**មាត្រា ១៨.–** សិទ្ធិលុបចោលសកម្មភាព

សកម្មភាពដែលអនីតិជនបានធ្វើដោយមិនបានទទួលការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចលុបចោលបាន ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះសកម្មភាពដែលទទួលសិទ្ធិ ឬ ឱ្យរួចផុតពីកាតព្វកិច្ច ឬ សកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ។

**មាត្រា ១៩.–** ការចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណា-ព្យាបាលសម្រាប់អនីតិជនអនុញ្ញាតឱ្យចាត់ចែង

អនីតិជនអាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬ អ្នកអាណា-ព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឱ្យចាត់ចែង ដោយកំណត់គោលបំណង ក្នុងទំហំនៃគោលបំណងនេះបាន ។ ម្យ៉ាងទៀត អនីតិជនក៏អាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឱ្យចាត់ចែងដោយមិនបានកំណត់គោលបំណងបានដែរ ។

**មាត្រា ២០.–** អនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម

១-អនីតិជនដែលបានទទួលការអនុញ្ញាតឱ្យប្រកបអាជីវកម្មមួយប្រភេទ ឬ ច្រើនប្រភេទ ពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវមានសមត្ថ-ភាពដូចនីតិជន ចំពោះមុខជំនួញនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើបានដឹងច្បាស់ថា អនីតិជននោះមិនអាចបំពេញកិច្ចការអាជីវកម្មនោះបាន អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនអាចលុបចោល ឬ កម្រិតនូវការអនុញ្ញាតនៃការប្រកបអាជីវកម្មនោះបាន ។

**មាត្រា ២១.–** ល័ក្ខខ័ណ្ឌនៃអត្តាធីនភាព

១-ក្នុងករណីដែលអនីតិជនដែលបានដល់អាយុ ១៦ (ដប់ប្រាំមួយ) ឆ្នាំ ទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ តុលាការអាចប្រកាសនូវអត្តាធីនភាពរបស់អ្នកនោះបាន

តាមពាក្យសុំរបស់អនីតិជននោះ ប្រសិនបើតុលាការយល់ឃើញថា អត្តាធីនភាពស្របនឹងផលប្រយោជន៍របស់អនីតិជននោះ ។ ក្នុងករណីនេះ តុលាការត្រូវសួរយោបល់ពីអ្នកមានសិទ្ធិអំណាចមេបា ។

២-អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ត្រូវទទួលអត្តាធីនភាព ដោយមិនចាំបាច់មានការប្រកាសពីតុលាការទេ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ទោះបីភាគីលែងលះគ្នាក៏ដោយ ក៏អានុភាពនៃអត្តាធីនភាព មិនត្រូវរលត់ឡើយ ។

**មាត្រា ២២.–** អានុភាពនៃអត្តាធីនភាព

អនីតិជនដែលទទួលអត្តាធីនភាព ត្រូវបានចាត់ទុកថា បានដល់នីតិភាព ។

**មាត្រា ២៣.–** កិច្ចសន្យាការងាររបស់អនីតិជន

១-ទោះបីជាមានបញ្ញត្តិនៃមាត្រា ១០៥៣ (ការគ្រប់គ្រងទ្រព្យសម្បត្តិ និង ការតំណាង) និង មាត្រា ១០៨០ (ការគ្រប់គ្រងទ្រព្យសម្បត្តិ និង ការតំណាង) នៃក្រមនេះក៏ដោយ ក៏អ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន មិនអាចធ្វើកិច្ចសន្យាការងារជំនួសអនីតិជនបានដែរ ។

២-កិច្ចសន្យាដែលផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនមានអានុភាពចំពោះសាមីអនីតិជនឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះករណីដែលសាមីអនីតិជនផ្តល់សច្ចានុមតិលើកិច្ចសន្យានោះ ។

៣-ក្នុងករណីដែលយល់ឃើញថា កិច្ចសន្យាការងាររបស់អនីតិជនអាចធ្វើឱ្យខូចផលប្រយោជន៍ដល់អនីតិជននោះ អ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ ស្ថាប័នរដ្ឋបាល អាចរំលាយកិច្ចសន្យានោះ ឆ្ពោះទៅអនាគតបាន ។

# គន្ថីទី ៩

# អវសានប្បញ្ញត្តិ

## ជំពូកទោល

## អវសានប្បញ្ញត្តិ

**មាត្រា ១៣០៥.- កាលបរិច្ឆេទនៃការអនុវត្ត ជាអាទិ៍**

១-ក្រមនេះ ត្រូវអនុវត្ត ចាប់តាំងពីថ្ងៃដែលកំណត់ផ្សេងដោយច្បាប់ ។

២-ចំពោះវិធានការអន្តរកាលដែលទាក់ទងនឹងការអនុវត្តក្រមនេះ និងចំណុចចាំបាច់ផ្សេងទៀតដែលទាក់ទងនឹងការអនុវត្តក្រមនេះ ត្រូវកំណត់ផ្សេងដោយច្បាប់ ។

រាជធានីភ្នំពេញថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧
ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

តរល.០៧១២.៦២២

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
**ហត្ថលេខា**
**អង្គ វង្សវឌ្ឍានា**

លេខ:៥៧៤ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០០៧
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**
**យុន ជិនកេន**

453/453

# ក្រមព្រហ្មទណ្ឌ

# ព្រះរាជក្រម

នស/រកម/១១០៩/០២២

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/១៩៩៦/០៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះ ទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៦ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

# គន្ថីទី ១
# បទប្បញ្ញត្តិទូទៅ
## មាតិកាទី ១
## ច្បាប់ព្រហ្មទណ្ឌ
## ជំពូកទី ១
## គោលការណ៍ទូទៅ

**មាត្រា ១.-** ដែនអនុវត្តនៃច្បាប់ព្រហ្មទណ្ឌ

ច្បាប់ព្រហ្មទណ្ឌកំណត់បទល្មើស ចង្អុលបង្ហាញបុគ្គលដែលអាចត្រូវបានប្រកាសថា ជាអ្នកទទួលខុសត្រូវចំពោះបទល្មើស និងកំណត់ទោស ព្រមទាំងបែបបទនៃការអនុវត្តទោសនេះ ។

នៅក្នុងករណីចាំបាច់ បទដ្ឋានគតិយុត្តដែលចេញដោយអង្គការនីតិប្រតិបត្តិអាចចែងពីបទលហុដែលត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ ។

**មាត្រា ២.-** និយមន័យ និងចំណាត់ថ្នាក់នៃបទល្មើស

ច្បាប់បញ្ញត្តថា អំពើខ្លះរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបង្កចលាចលដល់សង្គម ជាបទល្មើស ។ បទល្មើសត្រូវបានចាត់ថ្នាក់ជា បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ទៅតាមទម្ងន់នៃបទល្មើសនោះ ។

**មាត្រា ៣.-** គោលការណ៍នីត្យានុកូលភាព

មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន ។

មានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន ។

**មាត្រា ៤.-** ចេតនាប្រព្រឹត្តបទល្មើស

ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត ។

២-ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត មានន័យថា ជាសមាជិកព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដើម្បីបំពេញមុខងារសាធារណៈដទៃទៀត ។

## ជំពូកទី ២
## មូលហេតុនៃការមិនទទួលខុសត្រូវ ឬការសម្រាលនូវការទទួលខុសត្រូវព្រហ្មទណ្ឌ

**មាត្រា ៣១.-** ការមិនទទួលខុសត្រូវដោយសារមូលហេតុវិបល្លាសស្មារតី

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលធ្វើឱ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលបន្ថយនូវការដឹងខុសត្រូវរបស់ខ្លួន ជននោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល ។ ប៉ុន្តែ តុលាការត្រូវគិតគូរអំពីបញ្ហានេះ កាលណាតុលាការកំណត់ទោស ។

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដោយសារការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារជាតិដែលច្បាប់ហាមឃាត់ មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ។

**មាត្រា ៣២.-** ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ

បុគ្គលណាដែលប្រព្រឹត្តអំពើដែលបានបញ្ញត្ត ឬអនុញ្ញាតតាមច្បាប់ បុគ្គលនោះ មិនប្រព្រឹត្តបទល្មើសទេ ។

បុគ្គលណាដែលប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនេះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់ ។

ប៉ុន្តែ ចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតក្នុងបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬបទឧក្រិដ្ឋសង្គ្រាម មិនអាចលើកលែងឱ្យផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនទេ ទោះបីជាក្នុងករណីមានមូលហេតុដូចខាងក្រោមក៏ដោយ :

១-ជនល្មើសនោះបានប្រព្រឹត្តអំពើដែលបញ្ញត្ត អនុញ្ញាត ឬមិនហាមឃាត់ដោយច្បាប់ជាធរមាន ។

២-បុគ្គលនោះបានប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ ។

## មាត្រា ៣៣.- ការការពារស្របច្បាប់

បុគ្គលណាដែលប្រព្រឹត្តបទល្មើសក្នុងសភាពការពារស្របច្បាប់ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

ការការពារស្របច្បាប់ ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ :

-បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ

-បទល្មើស និងការឈ្លានពាន ត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា និង

-គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន ។

## មាត្រា ៣៤.- សច្ចធារណ៍នៃការការពារស្របច្បាប់

ត្រូវសន្មតថាជាការការពារស្របច្បាប់ នៅក្នុងករណីដូចតទៅ :

១-បទល្មើសត្រូវបានប្រព្រឹត្ត ដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយការកាប់គាស់ទម្លុះទម្លាយ ដោយហិង្សា ឬដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សនៅ ។

២-បទល្មើសបានប្រព្រឹត្ត ដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬការប្លន់ដែលអនុវត្តដោយហិង្សា ។

សច្ចធារណ៍នៃការការពារស្របច្បាប់ ពុំមានលក្ខណៈដាច់ខាតទេ ។ សច្ចធារណ៍នេះ អាចត្រូវរំលាយដោយភស្តុតាងផ្ទុយ ។

**មាត្រា ៣៥.-** ស្ថានភាពចាំបាច់

បុគ្គលដែលស្ថិតនៅក្នុងការចាំបាច់ត្រូវតែប្រព្រឹត្តបទល្មើស មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

ស្ថានភាពចាំបាច់ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ :

-បទល្មើសត្រូវបានចាត់ទុកថា ត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន និង

-គ្មានវិសមាមាត្ររវាងមធ្យោបាយការពារនិងទម្ងន់នៃគ្រោះថ្នាក់ ។

**មាត្រា ៣៦.-** អានុភាពនៃកម្លាំង ឬការបង្ខំ

បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬការបង្ខំ ដែលបុគ្គលនេះ មិនអាចទប់ទល់បាន បុគ្គលនេះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

កម្លាំង និងការបង្ខំ អាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ ។ កម្លាំង និងការបង្ខំនេះត្រូវតែមិនអាចមើលឃើញជាមុនបាន និងមិនអាចជៀសវាងបាន ។

**មាត្រា ៣៧.-** ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

បុគ្គលដែលមិនទទួលខុសត្រូវព្រហ្មទណ្ឌ មិនត្រូវទទួលទណ្ឌកម្មព្រហ្មទណ្ឌណាមួយទេ ។

## ជំពូកទី ៣

## ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន

**មាត្រា ៣៨.-** នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ ។

## មាត្រា ៣៩.- វិធានការអនុវត្តចំពោះអនីតិជន

អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ។

ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ ។

## មាត្រា ៤០.- ប្រភេទនៃវិធានការ

វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភមានដូចតទៅ :

១-ការប្រគល់អនីតិជនឱ្យទៅឪពុកម្តាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនឹងទំនុកចិត្ត ។

២-ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន ។

៣-ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន ។

៤-ការប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស ។

៥-ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ ។

## មាត្រា ៤១.- ការដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ

ក្នុងករណីដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការនោះ តុលាការចាត់តាំងបុគ្គលមួយរូបដែលទទួលភារៈធ្វើការតាមដានអនីតិជន ។ បុគ្គលនេះធ្វើរបាយការណ៍ស្តីពីកិរិយាមារយាទរបស់អនីតិជនឱ្យបានទៀងទាត់ដល់ព្រះរាជអាជ្ញា។ បុគ្គលនេះផ្តល់ព័ត៌មាន ដល់ព្រះរាជអាជ្ញាអំពីព្រឹត្តិការណ៍ទាំងអស់ ដែលអាចនាំឱ្យមានការកែប្រែនូវវិធានការនេះ ។

# ជំពូកទី ៦
# ទោសដែលអាចអនុវត្តចំពោះអនីតិជន
## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១៦០.-** មូលទោសអនុវត្តចំពោះអនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ឡើងទៅ

កាលណាតុលាការ សម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ មូលទោសលើបទល្មើសដែលចោទប្រកាន់ ត្រូវបាន បន្ថយក្នុងលក្ខខណ្ឌដូចតទៅ :

១-អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល ។

២-ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ ។

៣-អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានេះលើសពី ១ (មួយ) ថ្ងៃ ។

៤-អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល ។

ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទប្បញ្ញត្តិនៃមាត្រានេះមានអានុភាពបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមថិរវេលាមួយស្មើ ឬតិចជាង ៥ (ប្រាំ) ឆ្នាំ នោះបទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល ។

**មាត្រា ១៦១.-** ទោសបន្ថែម

មានតែទោសបន្ថែមដូចតទៅនេះប៉ុណ្ណោះ ដែលអាចអនុវត្តទៅលើអនីតិជន :

១-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើក្នុងការប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

២-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៣-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៤-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

៥-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

**មាត្រា ១៦២.-** ទោសការងារសហគមន៍

ទោសដែលជាការងារសហគមន៍ អាចអនុវត្តទៅលើអនីតិជនដែលមានអាយុយ៉ាងតិច ១៦ (ដប់ប្រាំមួយ) ឆ្នាំ ប៉ុន្តែ ថិរវេលានៃការងារមិនអាចលើសពី ១០០ (មួយរយ) ម៉ោង ។

ការងារសហគមន៍ត្រូវតែសម្របសម្រួលទៅលើអនីតិជន មានលក្ខណៈជាការបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ ។

**មាត្រា ១៦៣.-** ការមិនអនុវត្តបទប្បញ្ញត្តិស្តីពីការមិនរាងចាល

បទប្បញ្ញត្តិស្តីពីការមិនរាងចាល មិនអនុវត្តទៅលើអនីតិជនទេ ។

**មាត្រា ១៦៤.-** ការទទួលប្រយោជន៍នៃស្ថានសម្រាលទោស

ស្ថានសម្រាលទោសត្រូវអនុវត្តទៅលើអនីតិជន ។

កាលបើតុលាការបានសម្រេចឱ្យមានស្ថានសម្រាលទោស អប្បបរមានៃមូលទោស លើអនីតិជនពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវបន្ថយតាមខ្នាតដោយឡែកដូចតទៅ :

១-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកនៅត្រឹម ១ (មួយ) ឆ្នាំ ។

២-ប្រសិនបើអប្បបរមានៃទោសជាប់ពន្ធនាគារស្មើ ឬលើសពី ៥ (ប្រាំ) ឆ្នាំ និងតិចជាង ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកត្រឹម ៦ (ប្រាំមួយ) ខែ ។

៣-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ២ (ពីរ) ឆ្នាំ និងតិចជាង ៥ (ប្រាំ) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកត្រឹម ៣ (បី) ខែ ។

៤-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ៦ (ប្រាំមួយ) ថ្ងៃ និងតិចជាង ២ (ពីរ) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយត្រឹម ១ (មួយ) ថ្ងៃ ។

៥-អប្បបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្ដាល ។

**មាត្រា ១៦៥.-** កាតព្វកិច្ចដោយឡែកក្នុងករណីនៃការព្យួរទោសសាកល្បង

នៅក្នុងករណីនៃការព្យួរទោសសាកល្បង មានតែកាតព្វកិច្ចដោយឡែកដូចតទៅនេះប៉ុណ្ណោះដែលអាចអនុវត្តទៅលើអនីតិជន :

១-ទទួលការបង្ហាត់បង្រៀន ឬការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ។

២-ស្ថិតនៅទីកន្លែងមួយជាកំណត់ ។

៣-ដាក់ខ្លួនឱ្យពេទ្យពិនិត្យ ឬព្យាបាល ។

៤-ជួសជុលព្យសនកម្មដែលបណ្ដាលមកអំពីបទល្មើស ទៅតាមធនធានរបស់ខ្លួន ។

៥-បង្ហាញភស្តុតាង បញ្ជាក់ថាខ្លួនបង់ទឹកប្រាក់ដែលជំពាក់ជូនរដ្ឋរួចហើយ តាមលទ្ធភាពនៃធនធានរបស់ខ្លួន បន្ទាប់ពីការផ្ដន្ទាទោស ។

៦-មិនត្រូវបង្ហាញមុខនៅទីកន្លែងខ្លះ ។

៧-មិនត្រូវសេពគប់ ទីកន្លែងលក់ភេសជ្ជៈស្រវឹង ។

៨-មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ដោយឡែកជាមួយសហចារី អ្នកផ្ដើមគំនិត អ្នកសមគំនិត ឬជនរងគ្រោះនៃបទល្មើស ។

៩-មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។ធ

## ផ្នែកទី ២

## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៦៦.-** លក្ខខណ្ឌនៃការឃុំខ្លួនអនីតិជនក្នុងពន្ធនាគារ

អនីតិជនដែលជាប់ពន្ធនាគារ ត្រូវឃុំខ្លួននៅទីកន្លែងពិសេស ខណ្ឌដាច់ពីនីតិជន ។ អនីតិជនស្ថិតនៅក្រោមរបបដោយឡែកជាឯកត្តបុគ្គល ដែលជាទីកន្លែង

# ច្បាប់

# ស្តីពី

# យុត្តិធម៌អនីតិជន

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ព្រះរាជក្រម

នស/រកម/០៧១៦/០០៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២.០១៦ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### មាត្រា ១.- គោលបំណង

ច្បាប់នេះមានគោលបំណង៖

- ធានាការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់អនីតិជនដែលប្រព្រឹត្តបទល្មើស
- គាំទ្រដល់ការស្ដារនីតិសម្បទា និងការធ្វើសមាហរណកម្មអនីតិជនទៅក្នុងសង្គម និងសហគមន៍
- ធានាការពារផលប្រយោជន៍សង្គមនិងសហគមន៍ ។

### មាត្រា ២.- គោលដៅ

ច្បាប់នេះមានគោលដៅកំណត់អំពីវិធាន និងនីតិវិធីទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្តតាមដោយហ្មត់ចត់ ដើម្បីកំណត់ឲ្យបានច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយដែលប្រព្រឹត្តដោយអនីតិជន ។

បទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមព្រហ្មទណ្ឌ និងច្បាប់ដោយឡែកផ្សេងទៀត ត្រូវយកមកអនុវត្ត លើកលែងតែក្នុងករណីដែលមានចែងនៅក្នុងច្បាប់នេះ ។

### មាត្រា ៣.- វិសាលភាព

ច្បាប់នេះមានវិសាលភាពអនុវត្តលើករណីអនីតិជនប្រព្រឹត្តបទល្មើស ។

### មាត្រា ៤.- និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ៖

១- យុត្តិធម៌អនីតិជន សំដៅដល់ការការពារសិទ្ធិអនីតិជនតាមរយៈយន្តការ វិធាន និងនីតិវិធីទាំងឡាយដែលត្រូវគោរព និងអនុវត្តដោយហ្មត់ចត់ ព្រមទាំងវិធាននៃការកំណត់ទោសក្នុងករណីអនីតិជនប្រព្រឹត្តបទល្មើស ។

២- អាជ្ញាធរមានសមត្ថកិច្ច សំដៅដល់បុគ្គល ឬស្ថាប័នដែលអនុវត្តដោយស្របច្បាប់នូវមុខងាររបស់ខ្លួនដែលពាក់ព័ន្ធនឹងរឿងក្ដីអនីតិជន ។

៣- អនីតិជន សំដៅដល់ជនដែលមានអាយុតិចជាង ១៨ (ដប់ប្រាំបី) ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

៤- អនីតិជនត្រូវការកិច្ចការពារ និងថែទាំ សំដៅដល់អនីតិជនដែលត្រូវការកិច្ចការពារ និងថែទាំ ដោយមូលហេតុអនីតិជននោះគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ ឬ គ្មានការថែទាំ និងគ្រប់គ្រងត្រឹមត្រូវពីសំណាក់អ្នកតំណាងដែលច្បាប់បានកំណត់ ហើយកំពុងប្រឈមនឹងសភាពគ្រោះថ្នាក់ ឬរងការរំលោភបំពាន ឬបង្ហាញការគំរាមកំហែងដល់សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬគំរាមកំហែងដល់សុវត្ថិភាពផ្ទាល់ខ្លួន ។

៥- អ្នកតំណាងដែលច្បាប់បានកំណត់ សំដៅដល់អ្នកមានអំណាចមេបា អ្នកអាណាព្យាបាលសម្រាប់អនីតិជន និងអ្នកអាណាព្យាបាលទូទៅ ។

៦- អ្នកទំនុកបម្រុង សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលត្រូវបានជ្រើសរើសដោយអនីតិជន ឬដោយអាជ្ញាធរមានសមត្ថកិច្ច និងមានការយល់ព្រមពីអនីតិជនឲ្យទទួលខុសត្រូវក្នុងការទំនុកបម្រុងខ្លួនក្នុងអំឡុងពេលអនុវត្តនីតិវិធីដែលមានចែងក្នុងច្បាប់នេះ ។

៧- នីតិវិធីកុមារមេត្រី សំដៅដល់ដំណើរការ និងនីតិវិធីដែលពាក់ព័ន្ធនឹងការលើកទឹកចិត្តឲ្យអនីតិជនចូលរួមក្នុងរឿងក្តី តាមរយៈការប្រើប្រាស់ភាសានិងអាកប្បកិរិយាក្នុងកម្រិតដែលអនីតិជនអាចយល់បាន និងក្នុងបរិយាកាសដែលផ្តល់ឲ្យអនីតិជននូវសុវត្ថិភាព សន្តិសុខ សិទ្ធិ និងតម្រូវការជាមូលដ្ឋាន ។

៨- របាយការណ៍ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន សំដៅដល់របាយការណ៍ស្តីពីស្ថានភាពទូទៅរបស់អនីតិជន និងការផ្តល់យោបល់វាយតម្លៃផ្សេងៗដែលធ្វើឡើងដោយភ្នាក់ងារសង្គមកិច្ច ។

៩- ភ្នាក់ងារសង្គមកិច្ច សំដៅដល់មន្ត្រីរបស់ក្រសួង មន្ទីរ ការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬបុគ្គលផ្សេងទៀតដែលទទួលបានការបណ្តុះបណ្តាលជំនាញផ្នែកកុមារ និងច្បាប់ពាក់ព័ន្ធនឹងអនីតិជន ហើយត្រូវទទួលបានការតែងតាំង ឬទទួលស្គាល់ពីរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

១០- មណ្ឌលយុវនីតិសម្បទា សំដៅដល់មណ្ឌលដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច សម្រាប់ផ្តល់សេវាការពារ ថែទាំ អប់រំ ស្តារនីតិសម្បទា និងសមាហរណកម្មដល់អនីតិជន ។

ROYAUME DU CAMBODGE · LE MINISTÈRE DU PALAIS ROYAL

## មាត្រា ៦.- សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី

អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើសត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ ៖

- សិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី
- សិទ្ធិមិនទទួលការបង្ខិតបង្ខំឲ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង
- សិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកជន
- សិទ្ធិទទួលបានការពិនិត្យសុខភាព និងការព្យាបាល
- សិទ្ធិទទួលបានការឲ្យដំណឹងអំពីបទចោទប្រកាន់
- សិទ្ធិក្នុងការជូនដំណឹងអំពីការចាប់ខ្លួនទៅដល់អ្នកតំណាងដែលច្បាប់បានកំណត់
- សិទ្ធិទទួលបានជំនួយពីមេធាវីដោយការជ្រើសរើស ឬដោយការចាត់តាំងដោយមិនយកកម្រៃ ស្របតាមលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចាប់តាំងពីដំណាក់កាលដំបូងបំផុតនៃនីតិវិធី
- សិទ្ធិឲ្យមានការចូលរួមពីអ្នកតំណាងដែលច្បាប់បានកំណត់នៅគ្រប់ដំណើរការរឿងក្តី ប្រសិនបើការចូលរួមនេះមិនផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន
- សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែភាសាដោយមិនយកកម្រៃ កាលបើមានការចាំបាច់
- សិទ្ធិបង្ហាញភស្តុតាង
- សិទ្ធិស្នើសុំឲ្យកោះហៅសាក្សី និងសួរសាក្សី
- សិទ្ធិស្នើសុំអនុញ្ញាតនៅក្រៅឃុំ
- សិទ្ធិស្នើសុំឲ្យកែប្រែវិធានការត្រួតពិនិត្យតាមផ្លូវតុលាការ
- សិទ្ធិទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជនជាជនបរទេស
- សិទ្ធិផ្សេងៗទៀតដែលមានចែងនៅក្នុងបទដ្ឋានគតិយុត្តជាធរមាន ។

# ជំពូកទី ៣
# ការទទួលខុសត្រូវព្រហ្មទណ្ឌ និងរដ្ឋបណ្តឹងរបស់អនីតិជន

## មាត្រា ៧.- ការទទួលខុសត្រូវព្រហ្មទណ្ឌ

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់ចាប់ពីអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ ។ ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ លើកលែងតែករណីមានចែងពិសេសនៅក្នុងច្បាប់ផ្សេងទៀត ។

ROYAUME DU CAMBODGE · LE PALAIS ROYAL

## មាត្រា ៨.- ការទទួលខុសត្រូវរដ្ឋប្បវេណី

បទប្បញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៧៤៥ (អសមត្ថភាពក្នុងការទទួលខុសត្រូវ) និងមាត្រា ៧៤៦ (ការទទួលខុសត្រូវរបស់អ្នកមានករណីយកិច្ចត្រួតពិនិត្យ) នៃជំពូកទី ១៦ (អំពើអនីត្យានុកូល) ក្នុងគន្ថីទី ៥ (កិច្ចសន្យាសំខាន់ៗ និងអំពើអនីត្យានុកូល)នៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តចំពោះការទទួលខុសត្រូវរដ្ឋប្បវេណីរបស់អនីតិជន ។

## មាត្រា ៩.- ការកំណត់អាយុ

អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ត្រូវកំណត់យកអាយុនៅពេលដែលអនីតិជននោះប្រព្រឹត្តបទល្មើស ។

ភស្តុតាងនៃអាយុរបស់អនីតិជន ត្រូវបានបញ្ជាក់ដោយសំបុត្រកំណើត ឬឯកសារផ្សេងទៀតដែលអាចបញ្ជាក់បានអំពីកំណើត ។ ក្នុងករណីពុំមានឯកសារ ឬមានការសង្ស័យ ឬមិនមានភាពច្បាស់លាស់ទាក់ទងនឹងយថាភូតនៃឯកសារនោះ ភស្តុតាងនៃអាយុរបស់អនីតិជនអាចផ្តល់តាមគ្រប់មធ្យោបាយផ្សេងទៀតដែលអាជ្ញាធរតុលាការអាចជឿទុកចិត្តបាន ។

អាជ្ញាធរមានសមត្ថកិច្ចត្រូវស្វះស្វែងរកភស្តុតាង ដើម្បីកំណត់អាយុរបស់អនីតិជនឲ្យបានឆាប់រហ័សបំផុតដែលអាចធ្វើទៅបាន ។

ក្នុងករណីមានការសង្ស័យអំពីអាយុរបស់អនីតិជន វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់អនីតិជននោះ ។

# ជំពូកទី ៤

# ជំនួយផ្នែកសេវាសង្គមកិច្ច

## មាត្រា ១០.- ការតែងតាំង និងការទទួលស្គាល់ភ្នាក់ងារសង្គមកិច្ច

ការតែងតាំង ការទទួលស្គាល់ និងការគ្រប់គ្រងភ្នាក់ងារសង្គមកិច្ចជាសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

បែបបទនៃការតែងតាំង និងការទទួលស្គាល់ភ្នាក់ងារសង្គមកិច្ច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច។

## មាត្រា ១១.- ភ្នាក់ងារសង្គមកិច្ច

ភ្នាក់ងារសង្គមកិច្ចមានភារកិច្ចជាអាទិ៍ ៖

- ជួបអនីតិជននៅគ្រប់ដំណាក់កាលនៃនីតិវិធី ជាពិសេស នៅដំណាក់កាលដំបូងនៃនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌ និងនៅក្នុងពន្ធនាគារ ដើម្បីប្រមូលព័ត៌មានវាយតម្លៃ និងផ្តល់សេវាបន្ទាន់ដល់អនីតិជន

ក្នុងករណីមានវិវាទទាក់ទងនឹងអាយុរបស់អនីតិជននៅពេលប្រព្រឹត្តបទល្មើស មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនសំណុំរឿងនេះទៅព្រះរាជអាជ្ញាជាបន្ទាន់ ។

## មាត្រា ១៥._ ការចាប់ខ្លួន

នគរបាលយុត្តិធម៌អាចចាប់ខ្លួនអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ តែក្នុងករណីដែលអនីតិជនប្រព្រឹត្តបទមជ្ឈិម ឬបទឧក្រិដ្ឋជាក់ស្តែងតែប៉ុណ្ណោះ ។ ប៉ុន្តែអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ ការចាប់ខ្លួនអាចធ្វើទៅបានតែក្នុងករណីដែលអនីតិជននោះប្រព្រឹត្តបទមជ្ឈិមដោយចេតនា ។ រាល់ការចាប់ខ្លួនអនីតិជនត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាម។

ការអនុវត្តការចាប់ខ្លួន នគរបាលយុត្តិធម៌ត្រូវចៀសវាងការធ្វើឲ្យអាម៉ាស់មុខនិងបាត់បង់សេចក្តីថ្លៃថ្នូររបស់អនីតិជន និងត្រូវបញ្ជូនអនីតិជនទៅឲ្យផ្នែក ឬអង្គភាពដែលមាននគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជនដែលនៅជិតបំផុត ។

## មាត្រា ១៦._ ការឆែកឆេរលើខ្លួនបុគ្គល

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរលើខ្លួនបុគ្គលដែលជាអនីតិជនបាន ។ ការឆែកឆេរខ្លួនបុគ្គលត្រូវធ្វើឡើងដោយបុគ្គលដែលមានភេទដូចគ្នា និងមិនត្រូវជាប់ពាក់ព័ន្ធនឹងបទល្មើស ពុំមានទំនាស់ ឬមិនជាប់សាច់ញាតិ ឬមានទំនាក់ទំនងជិតស្និទ្ធជាមួយអនីតិជននោះឡើយ លើកលែងតែក្នុងករណីមិនអាចចៀសវាងបាន ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុនិងចុះនិទ្ទេសអំពីបញ្ហានេះ ។

## មាត្រា ១៧._ ការឃាត់ខ្លួនអនីតិជនប្រព្រឹត្តបទល្មើស

មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំបាន ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌ជឿជាក់ថាអនីតិជនអាចរត់គេចខ្លួន ឬបំផ្លាញភស្តុតាង ឬបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពសាក្សី ជនរងគ្រោះ ឬសន្តិសុខសាធារណៈ ឬក្នុងគោលបំណងការពារសុវត្ថិភាពអនីតិជននោះ ។ ប៉ុន្តែ អនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ ការឃាត់ខ្លួនអាចធ្វើទៅបានតែក្នុងករណីដែលអនីតិជន នោះប្រព្រឹត្តបទមជ្ឈិមដោយចេតនា ។ រាល់ការឃាត់ខ្លួនអនីតិជន ត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាម ។ ការឃាត់ខ្លួននេះ សម្រាប់តែជាវិធានការចុងក្រោយប៉ុណ្ណោះ ។

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវបញ្ចប់ដំណើរការស៊ើបអង្កេតឲ្យបានលឿនបំផុតដែលអាចធ្វើទៅ

ក្នុងករណីអវត្តមានជនណាមួយខាងលើ ព្រះរាជអាជ្ញាត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយ ដោយបញ្ជាក់អំពីមូលហេតុ ។

បន្ទាប់ពីបញ្ចប់ការស្តាប់ចម្លើយភ្លាម អនីតិជនមានសិទ្ធិអានកំណត់ហេតុស្តាប់ចម្លើយបាន ។ ក្នុងករណីអនីតិជនមិនអាចអានកំណត់ហេតុស្តាប់ចម្លើយបាន ក្រឡាបញ្ជី ឬអ្នកបកប្រែត្រូវអានកំណត់ហេតុស្តាប់ចម្លើយឱ្យអនីតិជនស្តាប់ ។ អនីតិជនអាចសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយបាន មុននឹងចុះហត្ថលេខា ឬផ្តិតស្រាមដៃ ។

ព្រះរាជអាជ្ញាត្រូវអនុញ្ញាតឱ្យមេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ឬភ្នាក់ងារសង្គមកិច្ចអានកំណត់ហេតុស្តាប់ចម្លើយបាន ។

មេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ភ្នាក់ងារសង្គមកិច្ចដែលមានវត្តមាន ត្រូវចុះហត្ថលេខាឬផ្តិតស្រាមដៃលើកំណត់ហេតុ ។ ក្នុងករណីដែលអនីតិជន ឬអ្នកចូលរួមណាមួយមិនព្រមចុះហត្ថលេខាឬផ្តិតស្រាមដៃលើកំណត់ហេតុ ព្រះរាជអាជ្ញាត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយនោះ ។

វិធានដែលបានបញ្ញត្តនៅក្នុងមាត្រានេះ មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេនឹងនាំឱ្យមានមោឃភាពនៃនីតិវិធី ។

## មាត្រា ២៧.- ការតម្កល់រឿងទុកឥតចាត់ការចំពោះអនីតិជនអាយុក្រោម ១៤ (ដប់បួន)ឆ្នាំ

ក្នុងករណីអនីតិជនមានអាយុក្រោម ១៤(ដប់បួន)ឆ្នាំ គិតមកត្រឹមថ្ងៃដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស នោះព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ និងត្រូវប្រគល់អនីតិជនទៅឱ្យអ្នកតំណាងដែលច្បាប់បានកំណត់វិញភ្លាម ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារនិងថែទាំ ព្រះរាជអាជ្ញាត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាពនិងស្ថានភាពសង្គមរបស់អនីតិជន ។

ក្រោយពីបានទទួលអនីតិជនពីព្រះរាជអាជ្ញាហើយ ប្រសិនបើមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត យល់ឃើញថាអនីតិជននោះចាំបាច់ត្រូវមានកិច្ចការពារនិងថែទាំ នោះមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។ ក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បាន

ROYAUME DU CAMBODGE * LE SECRETARIAT DU PALAIS ROYAL

កំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការ ដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់ អាចដាក់ពាក្យប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណីបាន ។

## មាត្រា ២៨.- អំណាចរបស់តំណាងអយ្យការក្នុងការបង្វែរ

ករណីអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ប្រព្រឹត្តបទលហុ ឬបទមជ្ឈិម ព្រះរាជអាជ្ញាត្រូវពិចារណាជាបឋមទៅលើការបង្វែរដូចមានចែងក្នុងជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ។

ករណីព្រះរាជអាជ្ញាសម្រេចបង្វែរ បទប្បញ្ញត្តិនៃជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ត្រូវយកមកអនុវត្ត ។ ក្នុងករណីនេះ ព្រះរាជអាជ្ញាត្រូវសម្រេចផ្អាកនីតិវិធីចោទប្រកាន់ដោយដីកាសម្រេច ។

ប្រសិនបើការរៀបចំផែនការបង្វែរត្រូវការពេលវេលា ព្រះរាជអាជ្ញាត្រូវផ្អាកនីតិវិធីចោទប្រកាន់ និងបង្គាប់ឲ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីទទួលបានការគ្រប់គ្រងនិងថែទាំ ដើម្បីរង់ចាំអនុវត្តផែនការបង្វែរ ។

ព្រះរាជអាជ្ញាជូនដំណឹងដល់ជនរងគ្រោះឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ ក្នុងករណីជនរងគ្រោះជាអនីតិជន និងមេធាវីរបស់អនីតិជនអំពីការសម្រេចផ្អាកនីតិវិធីចោទប្រកាន់ ។ ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ អាចប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណី ។

ព្រះរាជអាជ្ញា ត្រូវសម្រេចចេញដីកាតម្កល់រឿងទុកឥតចាត់ការក្នុងករណីដែលការអនុវត្តផែនការបង្វែរទទួលបានជោគជ័យ ដោយផ្អែកលើលទ្ធផលនៃរបាយការណ៍ដែលបញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ ។

ក្នុងករណីអនីតិជនអនុវត្តផែនការបង្វែរមិនបានជោគជ័យ ព្រះរាជអាជ្ញាអាចចេញដីកាសម្រេចបង្វែរជាថ្មី ដោយពិចារណាទៅលើមូលហេតុដែលនាំឲ្យបរាជ័យក្នុងការអនុវត្តផែនការបង្វែរទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬចាត់វិធានការតាមនីតិវិធី ។

## មាត្រា ២៩.- ការឲ្យដំណឹងអំពីការចោទប្រកាន់

ក្នុងករណីណាក៏ដោយ ការសម្រេចចោទប្រកាន់របស់ព្រះរាជអាជ្ញាត្រូវឲ្យដំណឹងភ្លាមដោយផ្ទាល់និងជាលាយលក្ខណ៍អក្សរទៅអនីតិជន ហើយប្រសិនបើសមស្រប ត្រូវឲ្យដំណឹងតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់ឬអ្នកទំនុកបម្រុងនិងមេធាវីរបស់អនីតិជន ដើម្បីរៀបចំមធ្យោបាយការពារអនីតិជន ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

## មាត្រា ៣៧.- ការព្យួរការសិក្សា និងការងារសម្រាប់អនីតិជន

ចៅក្រមស៊ើបសួរអាចបង្គាប់ទៅគ្រឹះស្ថានសិក្សា ឬនិយោជក មិនឲ្យព្យួរការសិក្សា ឬព្យួរការងាររបស់អនីតិជន ប្រសិនបើអនីតិជនមិនត្រូវបានឃុំខ្លួនបណ្ដោះអាសន្នទេ ។

ក្នុងករណីអនីតិជនត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន ឬត្រូវអនុវត្តផែនការបង្វែរ គ្រឹះស្ថាន ឬនិយោជកអាចព្យួរការសិក្សា ឬព្យួរការងាររហូតដល់មានសេចក្ដីសម្រេចរបស់តុលាការជាស្ថាពរ ។ ក្នុងករណីតុលាការសម្រេចសេចក្ដីថាគ្មានទោសទេ នោះគ្រឹះស្ថានសិក្សា ឬនិយោជកត្រូវអនុញ្ញាតឲ្យអនីតិជនចូលសិក្សា ឬធ្វើការជាធម្មតាឡើងវិញ ។

## មាត្រា ៣៨.- អំណាចរបស់ចៅក្រមស៊ើបសួរក្នុងការបង្វែរ

ចៅក្រមស៊ើបសួរត្រូវពិចារណាជាបឋមទៅលើការបង្វែរ ដូចមានចែងក្នុងជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ចំពោះអនីតិជនដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទមជ្ឈិម ។ បទមជ្ឈិមដែលមានស្ថានទម្ងន់ទោស អាចត្រូវបានយកមកពិចារណាអំពីការបង្វែរផងដែរ ។ ករណីចៅក្រមស៊ើបសួរសម្រេចបង្វែរ បទប្បញ្ញត្តិក្នុងជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ត្រូវយកមកអនុវត្ត ។ ក្នុងករណីនេះចៅក្រមស៊ើបសួរត្រូវផ្អាកនីតិវិធីនៃការស៊ើបសួរដោយដីកាសម្រេច និងបង្គាប់ឲ្យដោះលែងអនីតិជនដែលត្រូវបានឃុំខ្លួន ប្រសិនបើអនីតិជននោះត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន ។ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីទទួលបានការគ្រប់គ្រងនិងថែទាំ ដើម្បីរង់ចាំអនុវត្តផែនការបង្វែរ ទោះបីផែនការបង្វែរត្រូវការពេលវេលារៀបចំក៏ដោយ ។

ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ ក្នុងករណីជនរងគ្រោះជាអនីតិជន និងមេធាវីរបស់អនីតិជន អំពីការសម្រេចផ្អាកនីតិវិធីនៃការស៊ើបសួរ ។ ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ អាចប្ដឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណី ។

ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់ ក្នុងករណីដែលការអនុវត្តផែនការបង្វែរទទួលបានជោគជ័យ ដោយផ្អែកលើលទ្ធផលរបាយការណ៍ដែលបញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ ។

ក្នុងករណីដែលអនីតិជនអនុវត្តផែនការបង្វែរមិនបានជោគជ័យ ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចបង្វែរជាថ្មីដោយពិចារណាទៅលើមូលហេតុដែលនាំឲ្យបរាជ័យក្នុងការអនុវត្តផែនការបង្វែរ ទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬចាត់វិធានការតាមនីតិវិធី ។

## មាត្រា ៣៩.- ការឃុំខ្លួនបណ្ដោះអាសន្ន

ការឃុំខ្លួនអនីតិជនបណ្ដោះអាសន្ន ជាវិធានការចុងក្រោយ ។

បន្ថែមលើបទប្បញ្ញត្តិស្តីពីលក្ខខណ្ឌ មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរមុននឹងសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន ត្រូវពិចារណាលើរបាយការណ៍ប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនផងដែរ ប្រសិនបើមាន ។

អនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មិនត្រូវបានឃុំខ្លួនបណ្តោះអាសន្នឡើយ ។ ក្នុងករណីអនីតិជនដែលកំពុងជាប់ឃុំត្រូវបានរកឃើញថាមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់ និងបង្គាប់ឲ្យដោះលែងអនីតិជននោះជាបន្ទាន់ ទោះបីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារ និងថែទាំ ចៅក្រមស៊ើបសួរត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារ និងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់ អាចដាក់ពាក្យប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណីបាន ។

## មាត្រា ៤០.- ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ចៅក្រមស៊ើបសួរអាចដាក់អនីតិជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលាជំនួសឲ្យការឃុំខ្លួនបណ្តោះអាសន្ន ប្រសិនបើអនីតិជនត្រូវចោទនោះ ត្រូវបានចោទប្រកាន់អំពីបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ។ បន្ថែមលើបទប្បញ្ញត្តិស្តីពីការត្រួតពិនិត្យតាមផ្លូវតុលាការនៃក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរអាចបង្គាប់អនីតិជនដែលនៅក្រៅឃុំឲ្យគោរពកាតព្វកិច្ចមួយ ឬច្រើនដូចតទៅ ៖

- ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ពីឪពុកម្តាយ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ឬក្រុមគ្រួសារណាមួយសមស្រប

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



៨១

**មាត្រា ៨៨.- មណ្ឌលឃុំឃាំងអនីតិជន**

ក្នុងករណីមិនទាន់មានមណ្ឌលឃុំឃាំងអនីតិជន វិធានការទាំងឡាយដែលកំពុងអនុវត្តទៅលើអនីតិជន ត្រូវបន្តអនុវត្តរហូតដល់មានមណ្ឌលឃុំឃាំងអនីតិជន ។

បែបបទ និងនីតិវិធីនៃការផ្ទេរ ការប្រគល់ និងការទទួលអនីតិជន ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

## ជំពូកទី ១៦

## អវសានប្បញ្ញត្តិ

**មាត្រា ៨៩.- ការអនុវត្តច្បាប់នេះ**

ក្រោយពីចូលជាធរមាននៅទូទាំងប្រទេស ច្បាប់នេះត្រូវផ្សព្វផ្សាយរយៈពេល ៦ (ប្រាំមួយ) ខែ ទើបអនុវត្ត ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០១៦

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

[illegible]

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**ហត្ថលេខា**

**វង សូត**

លេខ: ៧៦៩ ស.ណ

**សំណៅចំលងចេញពីច្បាប់ដើមសម្រាប់ចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**